# ព្រះ

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ២

# ចេតសិកសង្គហវិភាគ

រៀបរៀងដោយ
បណ្ឌិតធម្មាចារ្យ រស់ សុជាត

ព.ស ២៥៤១

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ២

## ចេតសិកសង្គហវិភាគ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

-------◎-------

# សង្គហគាថា

**ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា**
**ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកាមតា**

ធម៌ទាំងឡាយដែលប្រកបជាមួយនឹងចិត្ត តាមលក្ខណៈ ៤ គឺ កើតព្រមជាមួយនឹងចិត្ត ១ រលត់ព្រមជាមួយនឹងចិត្ត ១ មានអារម្មណ៍ដូចគ្នានឹងចិត្ត ១ មានទីកើតជាមួយនឹងចិត្ត ១ ឈ្មោះថា **ចេតសិក** មាន ៥២ ប្រភេទ ។

ចេតសិក ជាធម៌ដែលត្រូវអាស្រ័យចិត្តកើតឡើងនេះ មានសេចក្តីថា ប្រៀបដូចសិស្ស និង អាចារ្យ គឺ មានសិស្ស ក៏ត្រូវមាន

អាចារ្យ ឬ មានអាចារ្យ ក៏ត្រូវមានសិស្ស នឹងអត់ណាមួយមិនបាន សភាវៈទាំង ២ នេះ ប្រាកដព្រមគ្នា ដូចវចនត្ថៈដែលលោកពោលទុកថា :

**ចេតសិ ភវំ ចេតសិកំ វា ចេតសិ និយុត្តំ**

**ចេតសិកំ** = ធម្មជាតិកើតក្នុងចិត្ត ឬ ប្រកបក្នុងចិត្ត ឈ្មោះថា **ចេតសិក** ។

ម្យ៉ាងទៀត អាការដែលចេតសិកប្រកបនឹងចិត្តជានិច្ចនោះ ហៅថា **ចេតោយុត្តលក្ខណៈ** ដែលជាការប្រកបព្រមដោយលក្ខណៈ ៤ គឺ :

**១. ឯកុប្បាទៈ** កើតព្រមជាមួយនឹងចិត្ត ។
**២. ឯកនិរោធៈ** រលត់ព្រមជាមួយនឹងចិត្ត ។
**៣. ឯកាលម្ពណៈ** មានអារម្មណ៍ដូចគ្នានឹងចិត្ត ។
**៤. ឯកវត្ថុកៈ** អាស្រ័យវត្ថុដូចគ្នានឹងចិត្ត ។

# លក្ខណាទិចតុកៈរបស់ចេតសិក

**-ចិត្តនិស្សិត លក្ខណំ** មានការអាស្រ័យចិត្ត ជាលក្ខណៈ ។

**-អវិយោគុប្បាទន រសំ** មានការកើតរួម ជាមួយគ្នានឹង ចិត្ត ជាកិច្ច ។

**-ឯកាលម្ពណ បច្ចុប្បដ្ឋានំ** មានអារម្មណ៍ដូចគ្នានឹងចិត្ត ជាផល ។

**-ចិត្តុប្បាទ បទដ្ឋានំ** មានការកើតឡើងនៃចិត្ត ជាហេតុជិត ។

ចិត្តនិងចេតសិកទាំង ២ នេះជានាមធម៌ ទើបប្រកបជាមួយគ្នាបានជិតស្និទ្ធណាស់ ដូចភាពតែមួយ ប៉ុន្តែផ្សេងគ្នា គឺ ផ្សេងគ្នាតាមកិច្ច គឺ ចិត្តជាប្រធានក្នុងការដឹងអារម្មណ៍ ចំណែកចេតសិកមានការកើតរួមជាមួយនឹងចិត្ត ហើយតាក់តែងចិត្តឲ្យប្រព្រឹត្តទៅផ្សេងៗគ្នា ។

# អំពីចេតសិក ៥២ ដួង

ចេតសិក ៥២ ដួង ចែកជាប្រភេទធំៗ មាន ៣ ប្រភេទ គឺ :

**១. អញ្ញសមានាចេតសិក** ១៣ ។

**២. អកុសលចេតសិក** ១៤ ។

**៣. សោភណចេតសិក** ២៥ ។

# ១. អញ្ញសមានាចេតសិក ១៣

## សព្វចិត្តសាធារណចេតសិក ៧ គឺ :

១. ផស្ស មានការប៉ះខ្ទប់ ជាលក្ខណៈ ។
២. វេទនា មានការសោយអារម្មណ៍ ជាលក្ខណៈ ។
៣. សញ្ញា មានការចងចាំ ជាលក្ខណៈ ។
៤. ចេតនា មានការតាំងចិត្ត ជាលក្ខណៈ ។
៥. ឯកគ្គតា មានការមិនរវើរវាយ ជាលក្ខណៈ ។
៦. ជីវិតិន្ទ្រីយ៍ មានការអនុបាលសហជាតធម៌ ជាលក្ខណៈ ។
៧. មនសិការៈ មានការបង្រួបបង្រួម សហជាតធម៌ ជាលក្ខណៈ ។

## បកិណ្ណកចេតសិក ៦ គឺ :

១.វិតក្កៈ មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ ។

២.វិចារៈ មានការពិចារណាអារម្មណ៍ ជាលក្ខណៈ ។

**៣.អធិមោក្ខៈ** មានការសន្និដ្ឋានសម្រេចចិត្ត ជាលក្ខណៈ ។

**៤. វិរិយៈ** មានការឧស្សាហៈ ជាលក្ខណៈ ។

**៥. បីតិ** មានភាពពេញចិត្ត ជាលក្ខណៈ ។

**៦. ឆន្ទៈ** មានសេចក្ដីប៉ុនប៉ងប្រាថ្នានឹងធ្វើ ជាលក្ខណៈ ។

# ២. អកុសលចេតសិក ១៤

## មោចតុកៈ ៤ គឺ :

**១.មោហៈ** មានការមិនដឹងធម៌ តាមសេចក្ដីពិត ជាលក្ខណៈ ។

**២.អហិរិកៈ** មានការមិនខ្មើម មិនខ្មាសនូវទុច្ចរិត ជាលក្ខណៈ ។

**៣.អនោត្តប្បៈ** មានការមិនស្លុត មិនខ្លាចនូវទុច្ចរិត ជាលក្ខណៈ ។

**៤.ឧទ្ធច្ចៈ** មានការរវើរវាយ មិនស្ងប់ ជាលក្ខណៈ ។

# លោភិកៈ ៣ គឺ ៖

១. **លោភៈ** មានការជាប់ជំពាក់ក្នុងអារម្មណ៍ ជាលក្ខណៈ ។
២. **ទិដ្ឋិ** មានការប្រកាន់ទុកមិនត្រូវទំនង ជាលក្ខណៈ ។
៣. **មានះ** មានការលើកតម្កើងខ្លួន ជាលក្ខណៈ ។

# ទោចតុកៈ ៤ គឺ ៖

១.**ទោសៈ** មានសភាពកាចសាហាវ ជាលក្ខណៈ ។
២.**ឥស្សា** មានការច្រណែនសម្បត្តិអ្នកដទៃ ជាលក្ខណៈ ។
៣.**មច្ឆរិយៈ** មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានហើយ ឬដែលគួរនឹងបាន ជាលក្ខណៈ ។
៤.**កុក្កុច្ចៈ** មានការក្តៅក្រហាយចិត្តជាក្រោយ ជាលក្ខណៈ ។

# ថីទុកៈ ២ គឺ ៖

១. **ថីនៈ** មានការមិនឧស្សាហ៍ ជាលក្ខណៈ ។

២. **មិទ្ធៈ** មានការមិនគួរដល់ការងារ ជាលក្ខណៈ ។

# វិចិកិច្ឆា ១ គឺ ៖

១. វិចិកិច្ឆា មានការសង្ស័យ ជាលក្ខណៈ ។

# ៣. សោភណចេតសិក ២៥

# សោភណសាធារណចេតសិក ១៩ គឺ ៖

១. សទ្ធា មានការជឿ( កុសល ) ជាលក្ខណៈ។

២. សតិ មានការរលឹកបានមិនភ្លេចភ្លាំង ជាលក្ខណៈ។

៣. ហិរិ មានការខ្មើមខ្មាសបាប ជាលក្ខណៈ ។

៤. ឱត្តប្បៈ មានការស្ញុត ខ្លាចបាប ជាលក្ខណៈ ។

៥. អលោភៈ មានការមិនជាប់ជំពាក់ ក្នុងអារម្មណ៍ ជាលក្ខណៈ ។

៦. អទោសៈ មានការមិនកាចសាហាវ ជាលក្ខណៈ។

៧.តត្រមជ្ឈត្តតា មានការនាំចិត្តចេតសិក ទៅដោយស្មើ ជាលក្ខណៈ ។

**៨.កាយបស្សទ្ធិ** មានការស្ងប់នាមខន្ធ ៣ ជាលក្ខណៈ ។

**៩. ចិត្តបស្សទ្ធិ** មានការស្ងប់ចិត្ត ជាលក្ខណៈ ។

**១០.កាយលហុតា** មានការស្ងប់ភាពធ្ងន់នៃនាមខន្ធ ៣ ជាលក្ខណៈ ។

**១១.ចិត្តលហុតា** មានការស្ងប់ភាពធ្ងន់នៃចិត្ត ជាលក្ខណៈ ។

**១២.កាយមុទុតា** មានការស្ងប់ភាពរឹងនៃនាមខន្ធ ៣ ជាលក្ខណៈ ។

**១៣.ចិត្តមុទុតា** មានការស្ងប់ភាពរឹងនៃចិត្ត ជាលក្ខណៈ ។

**១៤.កាយកម្មញ្ញតា** មានការស្ងប់ភាពដែលមិនគួរដល់ការងារ នៃនាមខន្ធ ៣ ជាលក្ខណៈ ។

**១៥.ចិត្តកម្មញ្ញតា** មានការស្ងប់ភាពដែលមិនគួរដល់ការងារ នៃចិត្ត ជាលក្ខណៈ ។

**១៦.កាយបាគុញ្ញតា** មានការស្ងប់ភាពឈឺចាប់នៃនាមខន្ធ ៣ ជាលក្ខណៈ ។

**១៧.ចិត្តបាគុញ្ញតា** មានការស្ងប់ភាពឈឺចាប់នៃចិត្ត ជាលក្ខណៈ។

**១៨.កាយុជុកតា** មានភាពស្មោះត្រង់នៃនាមខន្ធ៣ ជាលក្ខណៈ។

**១៩.ចិត្តុជុកតា** មានការស្មោះត្រង់នៃចិត្ត ជាលក្ខណៈ។

# វិរតិចេតសិក ៣ គឺ :

១.សម្មាវាចា មានការមិនកន្លងល្មើសវត្ថុដែលជាទីតាំង នៃវចីទុច្ចរិត ជាលក្ខណៈ ។

២.សម្មាកម្មន្តៈ មានការមិនកន្លងល្មើសវត្ថុដែលជាទីតាំង នៃកាយទុច្ចរិត ជាលក្ខណៈ ។

៣.សម្មាអាជីវៈ មានការមិនកន្លងល្មើសវត្ថុ នៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាលក្ខណៈ ។

# អប្បមញ្ញាចេតសិក ២ គឺ :

១. ករុណា មានបំណងបំបាត់ទុក្ខអ្នកដទៃ ជាលក្ខណៈ ។

២. មុទិតា មានការស្ងើចសរសើរសម្បត្តិអ្នកដទៃ ជាលក្ខណៈ ។

# បញ្ញិន្ទ្រិយចេតសិក ១ គឺ :

១. បញ្ញា មានការចាក់ធ្លុះលក្ខណៈសភាវៈនៃធម៌ ជាលក្ខណៈ ។

# ចេតសិក ៥២ ដួង

## អញ្ញសមានាចេតសិក ១៣

ផស្ស. វេ. សញ្ញា. ចេ. ឯ. ជី. មន. — សព្វចិត្តសាធារណចេតសិក ៧

វិតក្ក វិចា. អធិ. វីរិ. បីតិ ឆន្ទ — បកិណ្ណកចេតសិក ៦

## អកុសលចេតសិក ១៤

មោ. អហិ. អនោ. ឧទ្ធ. — មោចតុកចេតសិក ៤

លោ. ទិដ្ឋិ. មានះ — លោតិកចេតសិក ៣

ទោ. ឥស្សា មច្ឆ. កុក្កុ. — ទោចតុកចេតសិក ៤

ថីនៈ មិទ្ធៈ — ថីទុកចេតសិក ២

វិចិ. — វិចិកិច្ឆាចេតសិក ១

## សោភណចេតសិក ២៥

សទ្ធា សតិ ហិរិ ឱត្ត. អលោ អទោ. តត្ត.
កាយប. ចិត្តប.
កាយល. ចិត្តល.
កាយមុ. ចិត្តមុ.
កាយក ចិត្តក
កាយបា ចិត្តបា.
កាយុ. ចិត្តុ.
— សោភណសាធារណចេតសិក ១៩

វាចា. កម្ម. អាជី. — វិរតិ៣

ករុ. មុទិ. — អប្បមញ្ញាចេតសិក២

បញ្ញ. — បញ្ញាចេតសិក១

ពាក្យថា **អញ្ញសមានា ( អញ្ញ + សមានា )** ប្រែថា ស្មើនឹង ធម៌ដទៃៗដែរ គឺ ចេតសិកនេះប្រកបនឹងចិត្តជាកុសល ក៏ជាកុសល បើប្រកបនឹងចិត្តជាអកុសល ក៏ជាអកុសល បើប្រកបនឹងចិត្តជាអព្យាកតៈ ក៏ជាអព្យាកតៈ ដោយហេតុនេះ ទើបហៅថា **អញ្ញ-សមានាចេតសិក**។

ពាក្យថា **សព្វចិត្តសាធារណៈ ( សព្វ + ចិត្ត + សា-ធារណំ )** ប្រែថា ទូទៅដល់ចិត្តទាំងពួង គឺ ប្រកបនឹងចិត្តគ្រប់ទាំងអស់ ។

ពាក្យថា **បកិណ្ណកៈ** គឺ ចេតសិកដែលច្រឡូកច្របល់បន្ទាប់បន្សំ មិនប្រកបនឹងចិត្តទាំងអស់ទេ គឺ ប្រកបបានចំពោះតែដួងខ្លះៗ ដែលគួរនឹងប្រកបប៉ុណ្ណោះ ។

ពាក្យថា **អកុសលចេតសិក** បានដល់ ចេតសិកមិនល្អ , ប្រកបនឹងចិត្តហើយក៏ធ្វើឲ្យចិត្តនោះទៅជាអកុសល សៅហ្មងជាដើម។

ពាក្យថា **សោភណចេតសិក** បានដល់ ចេតសិកដែលល្អ កាលណាប្រកបជាមួយចិត្តហើយ ក៏តែងធ្វើឲ្យចិត្តនោះ ឲ្យជាកាមា-

វចរសោភណចិត្តខ្លះ ជារូបាវចរចិត្តខ្លះ ជាអរូបាវចរចិត្តខ្លះ និងជាលោកុត្តរចិត្តខ្លះ ៕

# អធិប្បាយ
# សព្វចិត្តសាធារណចេតសិក ៧

## ១. ផស្សចេតសិក

មានវិគ្រោះថា **ផុសតីតិ ផស្សោ** = ធម៌ឈ្មោះថា **ផស្សះ** ព្រោះអត្ថថា ប៉ះខ្ទប់ ឬ ប៉ះត្រូវ ។ ផស្សះនេះ លោកហៅថា **ផស្សាហារ** ព្រោះជាអាហារ គឺ ជាបច្ច័យ ។

ម្យ៉ាងទៀត ផស្សចេតសិកនេះ ព្រះនាគសេនថេរៈ បានវិសជ្ជនាឲ្យស្តេចព្រះបាទមិលិន្ទជ្រាបថា ដូចជាពពែពីរជល់គ្នា ក្បាលពពែមួយ ប្រៀបដូចជាចក្ខុបសាទ ក្បាលពពែមួយទៀត ប្រៀបដូចជារូប ( វណ្ណៈ ) ។

## លក្ខណាទិចតុកៈរបស់ផស្សះ

**-ផុសន លក្ខណោ** មានការប៉ះខ្ទប់ ជាលក្ខណៈ ។

**-សង្ឃដ្ដន         រសោ**       មានការធ្វើឲ្យចិត្ត និងអារម្មណ៍ប៉ះខ្ទប់គ្នា ជាកិច្ច ។

**-សន្និបាត បច្ចុប្បដ្ឋានោ**       មានការប្រជុំនូវអារម្មណ៍ វត្ថុ និង ចិត្ត ជាផល ។

**-អាបាថគតវិសយ បទដ្ឋានោ**       មានអារម្មណ៍មកកាន់គន្លង ជាហេតុជិត ។

ផស្សចេតសិកនេះ មានអត្ថថា ប៉ះខ្ទប់អារម្មណ៍ ។ **កិច្ច** គឺនាទីរបស់ផស្សៈ គឺប៉ះខ្ទប់អារម្មណ៍ដែលចិត្តដឹង ។ **ផល** គឺអាការប្រាកដនោះ ជាបច្ច័យធ្វើឲ្យធម៌ ៣ យ៉ាង គឺ អារម្មណ៍ វត្ថុ និងវិញ្ញាណ ប្រជុំគ្នា ។ ម្យ៉ាងទៀត លោកពោលថា **ផស្សៈ** មានវេទនាជាផល ។ ហេតុដែលនឹងឲ្យផស្សៈកើតឡើងបាន ព្រោះមានអារម្មណ៍មកកាន់គន្លង បណ្ឌិតគប្បីឃើញផស្សៈ ដូចជាមេគោដែលត្រូវគេបកស្បែកហើយ ព្រោះជាទីតាំងនៃវេទនា ។

ការដែលផស្សៈប៉ះខ្ទប់នឹងអារម្មណ៍ មិនដូចរូបនិងរូបប៉ះខ្ទប់គ្នាទេ ព្រោះផស្សៈជានាមធម៌ មានគុណសម្បត្តិ អាចប៉ះខ្ទប់អារម្មណ៍ជារូបក៏បាន ឬជានាមក៏បាន ក្នុងខណៈចិត្តដែលដឹងអារម្មណ៍ ។ ផស្សៈនេះ រមែងធ្វើនាទីប៉ះខ្ទប់ ទោះជាអារម្មណ៍នោះ ជាអារម្មណ៍អ្វីក៏ដោយ ជាលោកិយអារម្មណ៍ លោកុត្តរអារម្មណ៍ ឬមានព្រះនិព្វាន

ជាអារម្មណ៍ក៏ដោយ ផស្សៈក៏ជាបច្ច័យសំខាន់ដល់សម្បយុត្តធម៌ទាំងនោះ ។

# ២. វេទនាចេតសិក

មានវិគ្រោះថា **វេទិយតិ អាលម្ពណរសំ អនុភវតីតិ វេទនា** ។ ដែលឈ្មោះថា **វេទនា** ព្រោះអត្ថថា ដឹងខ្លួន គឺសោយរសនៃអារម្មណ៍ ។ សម្បយុត្តធម៌ក្រៅពីវេទនា មានការសោយរសនៃអារម្មណ៍ដែរ ក៏សោយបានត្រឹមតែឯកទេស ប៉ុន្តែចំពោះវេទនានោះ តែងសោយរសនៃអារម្មណ៍ដោយត្រង់ ព្រោះជាធំក្នុងការសោយ ។ ក្នុងអត្ថសាលិនី ប្រៀបវេទនា ដូចជាព្រះរាជាអ្នកសោយព្រះក្រយាហារ ចំណែកចិត្ត និងចេតសិកដទៃៗដែលកើតរួមជាមួយ ប្រៀបដូចអ្នកដាំស្ងោរឲ្យព្រះរាជា មានសិទ្ធិត្រឹមតែភ្លក្សអាហារនោះតិចតួច តាមសមគួរប៉ុណ្ណោះ មិនដូចព្រះរាជាមានសិទ្ធិបរិបូណ៌ក្នុងការសោយទេ ។

ម្យ៉ាងទៀត វេទនានេះ បើចែកតាម **អារម្មណានុភវន-លក្ខណន័យ** គឺ ន័យ មានការសោយអារម្មណ៍ជាលក្ខណៈ បានវេទនា ៣ គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។

ប៉ុន្តែបើចែកទៅតាម **ឥន្ទ្រីយ៍** ក៏បានវេទនា ៥ គឺ សុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខា-វេទនា ១ ។

# លក្ខណាទិចតុកៈរបស់វេទនា

**-អនុភវន លក្ខណា** មានការសោយអារម្មណ៍ ជាលក្ខណៈ ។

**-វិសយរស សម្ភោគ រសា** មានការប្រសព្វនឹងរស នៃអារម្មណ៍ ជាកិច្ច ។

**-សុខទុក្ខ បច្ចុប្បដ្ឋានា** មានសុខ និង ទុក្ខ ជាផល ។

**-ផស្ស បទដ្ឋានា** មានផស្សៈ ជាហេតុជិត ។

# លក្ខណាទិចតុកៈរបស់សុខវេទនា

**-ឥដ្ឋផោដ្ឋព្វានុភវន លក្ខណា** មានការសោយផោដ្ឋព្វៈ គួរជាទីប្រាថ្នា ជាលក្ខណៈ ។

**-សម្បយុត្តានំព្រូហន រសា** មានការធ្វើសម្បយុត្តធម៌ ឲ្យចំរើន ជាកិច្ច ។

-កាយិកអស្សាទ បច្ចុប្បដ្ឋានា មានសេចក្តីសប្បាយកាយ ជាអាការប្រាកដ ។

-កាយិន្ទ្រិយ បទដ្ឋានា មានកាយបសាទជាហេតុជិត ។

## លក្ខណាទិចតុកៈរបស់ទុក្ខវេទនា

-អនិដ្ឋផោដ្ឋព្វានុភវន លក្ខណា មានការសោយផោដ្ឋព្វៈ មិនជាទីប្រាថ្នា ជាលក្ខណៈ ។

-សម្បយុត្តានំ មិលាបន រសា មានការធ្វើសម្បយុត្តធម៌ ឲ្យថយចុះ ឲ្យសៅហ្មង ជាកិច្ច ។

-កាយិកាពាធ បច្ចុប្បដ្ឋានា មានសេចក្តីអាពាធកាយ ជាអាការប្រាកដ ។

-កាយិន្ទ្រិយ បទដ្ឋានា មានកាយបសាទជាហេតុជិត ។

## លក្ខណាទិចតុកៈរបស់សោមនស្សវេទនា

-ឥដ្ឋារម្មណានុភវន លក្ខណា មានការសោយអារម្មណ៍ គាប់ចិត្ត ជាលក្ខណៈ ។

**-ឥដ្ឋាការសម្ភោគ រសា** មានការប្រសព្វនឹងអារម្មណ៍ជាទីប្រាថ្នា ជាកិច្ច ។

**-ចេតសិកអស្សាទ បច្ចុប្បដ្ឋានា** មានការសប្បាយចិត្ត ជាអាការប្រាកដ ។

**-បស្សទ្ធិ បទដ្ឋានា** មានការស្ងប់កាយ ស្ងប់ចិត្ត ជាហេតុជិត ។

# លក្ខណាទិចតុកៈរបស់ទោមនស្សវេទនា

**-អនិដ្ឋារម្មណានុភវន លក្ខណា** មានការសោយអារម្មណ៍ មិនគាប់ចិត្ត ជាលក្ខណៈ ។

**-អនិដ្ឋាការសម្ភោគ រសា** មានការប្រសព្វ នឹងអារម្មណ៍មិនជាទីប្រាថ្នា ជាកិច្ច ។

**-ចេតសិកាពាធ បច្ចុប្បដ្ឋានា** មានការអាពាធចិត្ត ជាអាការប្រាកដ ។

**-ឯកន្តេនេវ ហទយវត្ថុ បទដ្ឋានា** មានហទយវត្ថុ តែប៉ុណ្ណោះជាហេតុជិត ។

# លក្ខណាទិចតុកៈរបស់ឧបេក្ខាវេទនា

-មជ្ឈត្តវេទយិត លក្ខណា មានការសោយអារម្មណ៍ ជាកណ្តាល ជាលក្ខណៈ ។

-សម្បយុត្តានំ នាតិ ឧបព្រូហន មិលាបន រសា មានការរក្សាសម្បយុត្តធម៌ មិនឲ្យចំរើនឡើង និង មិនឲ្យសៅហ្មង វិនាស ជាកិច្ច ។

-សន្តភាវ បច្ចុប្បដ្ឋានា មានសេចក្តីស្ងប់ ជាផល ។

-និប្បិត្តិកចិត្ត បទដ្ឋានា មានចិត្ត ដែលមិនប្រកបដោយបីតិ ជាហេតុជិត ។

# អំពីឧបេក្ខា ១០ យ៉ាង

**១.ឧបេក្ខាណា** ជាធម៌បរិសុទ្ធជាប្រក្រតីក្នុងគន្លងនៃអារម្មណ៍ ៦ ដែលជាទីប្រាថ្នាក្តី ឬ មិនជាទីប្រាថ្នាក្តី ក្នុងទ្វារ ៦ របស់ព្រះខីណាស្រព ដូចពោលទុកក្នុងបាលីថា “ ភិក្ខុជាខីណាស្រពក្នុងធម្មវិន័យនេះ ឃើញរូបដោយភ្នែក ហើយមិនត្រេកអរ មិនអន់ចិត្ត មានសតិ មានសេចក្តីដឹងខ្លួន ព្រងើយកន្តើយ ” យ៉ាងនេះ ឧបេក្ខា

នេះ ឈ្មោះថា **ឆឡង្គុបេក្ខា** (បានដល់ តត្រមជ្ឈត្តតាចេតសិក) ។

**២. ឧបេក្ខាណា** មានអាការជាកណ្តាលក្នុងសត្វទាំងឡាយ ដែលមានក្នុងបាលីថា " ភិក្ខុមានចិត្តប្រកបដោយ ឧបេក្ខា ផ្សាយទៅកាន់ទិសមួយ " យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **ព្រហ្មវិហារុបេក្ខា** គឺ ឧបេក្ខាក្នុងព្រហ្មវិហារធម៌ ( បានដល់ តត្រមជ្ឈត្តតាចេតសិក ) ។

**៣. ឧបេក្ខាណា** មានសេចក្តីជាកណ្តាលក្នុងសហជាតធម៌ ដែលមានក្នុងបាលីថា " ភិក្ខុចំរើនឧបេក្ខាសម្ពោជ្ឈង្គៈ អាស្រ័យវិវេក " យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **ពោជ្ឈង្គុបេក្ខា** គឺ ឧបេក្ខាក្នុងសម្ពោជ្ឈង្គ ( បានដល់ តត្រមជ្ឈត្តតាចេតសិក ) ។

**៤. ឧបេក្ខាណា** ពោលគឺ សេចក្តីព្យាយាមមិនបន្ធូរបន្ថយ ព្យាយាមកើនឡើង ដែលមានក្នុងបាលីថា " ភិក្ខុ មនសិការនិមិត្ត ឧបេក្ខាសព្វកាល " យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **វិរិយុបេក្ខា** ឧបេក្ខា គឺ សេចក្តីព្យាយាម ( បានដល់ វីរិយចេតសិក ) ។

**៥.ឧបេក្ខាណា** មានអាការជាកណ្តាលដែលកំណត់ ពិចារណាធម៌ មាននីវរណៈជាដើម ដែលមានក្នុងបាលីថា " សង្ខារុបេក្ខាប៉ុន្មាន តែងកើតឡើងដោយសមាធិ សង្ខារុបេក្ខាប៉ុន្មាន តែង

កើត ឡើងដោយវិបស្សនា ( ឆ្លើយថា ) សង្ខារុបេក្ខា ៨ យ៉ាង តែង កើតឡើងដោយអំណាចសមាធិ , សង្ខារុបេក្ខា ១០ យ៉ាង តែងកើត ឡើង ដោយអំណាចវិបស្សនា ” យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **សង្ខារុបេក្ខា** ( បានដល់ បញ្ញា ) ។

**៦. ឧបេក្ខាណា** ដែលសំគាល់ដឹងក្នុងសេចក្ដីមិនមែនទុក្ខ មិនមែនសុខ ដែលមានក្នុងបាលីថា “ កាមាវចរកុសលចិត្ត រមែង កើតឡើងក្នុងសម័យនោះ ” យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **វេទនុបេក្ខា** ( បានដល់ ឧបេក្ខាវេទនា ) ។

**៧. ឧបេក្ខាណា** មានសេចក្ដីជាកណ្ដាល ក្នុងការសង្កេត ពិចារណា ដែលមានក្នុងបាលីថា “ សភាវៈណាមួយប្រាកដហើយ គេតែងលះសភាវៈនោះចេញ ភិក្ខុរមែងបានចំពោះនូវឧបេក្ខា ” យ៉ាង នេះ ឧបេក្ខានេះ ឈ្មោះថា **វិបស្សនុបេក្ខា** ( បានដល់ បញ្ញា ) ។

**៨. ឧបេក្ខាណា** ញុំាងសហជាតធម៌ឲ្យប្រព្រឹត្តទៅ ស្មោះ ស្មើជានិច្ច ដែលមានក្នុងយេវាបនកធម៌ មានឆន្ទៈជាដើម ឧបេក្ខា នេះ ឈ្មោះថា **តត្រមជ្ឈត្តុបេក្ខា** ( បានដល់ តត្រមជ្ឈត្តតា-ចេតសិក ) ។

**៩. ឧបេក្ខាណា** ជាធម្មជាតិចុះទៅក្នុងសេចក្ដីសុខនៃឈាន

នោះ ជាសុខដ៏ប្រសើរ ដែលមានក្នុងបាលីថា “ ជាអ្នកសម្លឹងនៅ ”

យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **ឈានុបេក្ខា** ( បានដល់ តត្រមជ្ឈត្តតាចេតសិក ) ។

**១០. ឧបេក្ខាណា** បរិសុទ្ធចាកបច្ចនិកធម៌ មិនខ្វល់ខ្វាយ ស្ងប់ក្នុងការស្ងប់បច្ចនិកធម៌ ដែលមាននៅក្នុងបាលី “ ឈានទី ៤ មានសតិបរិសុទ្ធព្រោះឧបេក្ខា ” យ៉ាងនេះ ឧបេក្ខានេះ ឈ្មោះថា **បារិសុទ្ធុបេក្ខា** ( បានដល់ តត្រមជ្ឈត្តចេតសិក ) ។

ក្នុងបណ្ដាឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា តត្រមជ្ឈត្តុបេក្ខា ឈានុបេក្ខា បារិសុទ្ធុបេក្ខា ឧបេក្ខា ៦ នេះ , ដោយអត្ថជា តត្រមជ្ឈត្តតាចេតសិក , ប៉ុន្តែខុសគ្នាដោយប្រភេទ ប្រៀបដូចបុគ្គលម្នាក់ គឺ កាលនៅជាកុមារ ជាកំលោះ ជាអ្នកធំ ជាសេនាបតី ជាព្រះរាជាជាដើម ។ ឧបេក្ខា ២ យ៉ាង គឺ សង្ខារុបេក្ខា ១ វិបស្សនុបេក្ខា ១ ជាបញ្ញាចេតសិក ប៉ុន្តែផ្សេងគ្នាដោយកិច្ច វិបស្សនុបេក្ខា ជាបច្ច័យឲ្យសង្ខារុបេក្ខាកើតឡើង ។

ចំណែកឧបេក្ខា ២ ទៀត គឺ វីរិយុបេក្ខា បានដល់ វីរិយ-ចេតសិក និង វេទនុបេក្ខា បានដល់ ឧបេក្ខាវេទនាចេតសិក ៕

# ៣. សញ្ញាចេតសិក

មានវចនត្ថៈថា :

**នីលាទិភេទារម្មណំ សញ្ជា នាតិ សញ្ញំ កត្វា ជានាតីតិ សញ្ញា ។**

ធម្មជាតិដែលឈ្មោះថា **សញ្ញា** ព្រោះអត្ថថា ចាំអារម្មណ៍ផ្សេងៗ ដូចអារម្មណ៍ មានពណ៌ខៀវជាដើម គឺ ធ្វើគ្រឿងចំណាំដឹង ។

## លក្ខណាទិចតុក:របស់សញ្ញា

| | |
|---|---|
| **-សញ្ជានន លក្ខណា** | មានការចងចាំ ការសម្គាល់ជាលក្ខណៈ ។ |
| **-បុនសញ្ជានន បច្ចយនិមិត្ត ករណ រសា** | មានការធ្វើគ្រឿង ចំណាំទុកដើម្បីចាំជាកិច្ច ដូចជាងឈើស្គាល់ឈើ ចំណាំឈើបានជាដើម ។ |
| **-យថាគហិត និមិត្តវសេន អភិនិវេសករណ បច្ចុប្បដ្ឋានា** | មានការចាំនិមិត្តបានតាមដែលកំណត់ទុក ជាអាការប្រាកដ ។ |

| | |
|---|---|
| **-យថាឧបដ្ឋិត វិសយ បទដ្ឋានា** | មាន អារម្មណ៍ តាមដែលប្រាកដ ជាហេតុជិត ។ |

# ៤. ចេតនាចេតសិក

ចេតនាចេតសិក ជាធម្មជាតិ តាំងចិត្ត គឺ ចាត់ចែង ជំរុញលើកស្ទួយ ដាស់តឿន សម្បយុត្តធម៌ដែលកើតជាមួយខ្លួន ឲ្យធ្វើកិច្ចរបស់ខ្លួនរៀងៗខ្លួន ។

មានវចនត្ថៈថា **ចេតេតិ អត្តនា សម្បយុត្តធម្មេ អារម្មណេ អភិសន្ទហតិ សង្ខតាភិសង្ខរណេ វា ព្យាបារ-មាបជ្ជតីតិ ចេតនា** ធម្មជាតិដែល ឈ្មោះថា **ចេតនា** ព្រោះអត្ថថា តាំងចិត្ត គឺ ញុំាងសម្បយុត្តធម៌ ឲ្យព្រមព្រៀងនឹងខ្លួន ក្នុងអារម្មណ៍ ។ ឬ ឈ្មោះថា **ចេតនា** ព្រោះអត្ថថា ដល់នូវសេចក្ដីខ្វល់ខ្វាយក្នុងការតាក់តែងធម៌ដែលជាសង្ខតៈ ។

ពិតមែន ព្រះដ៏មានព្រះភាគ កាលព្រះអង្គទ្រង់ចែកសង្ខារក្ខន្ធត្រាស់ថា **ចេតនា** ឈ្មោះថា **សង្ខារ** ព្រោះអត្ថថា តាក់តែងធម៌ជាសង្ខតៈ ( ក្នុងសំយុត្តនិកាយខន្ធវារវគ្គ ) ត្រាស់ថា ព្រោះជាប្រធានក្នុងការតាក់តែង ( ក្នុងអភិធម្មវិភង្គបករណៈ ) ។

# លក្ខណាទិចតុក:របស់ចេតនា

| | | |
|---|---|---|
| **-ចេតនាភាវ** | **លក្ខណា** | មានការតាំងចិត្ត ជាលក្ខណៈ ។ |
| **-អាយូហន** | **រសា** | មានការតាំងចិត្តប្រមូលមក ជាកិច្ច ។ |
| **-សំវិធាន** | **បច្ចុប្បដ្ឋានា** | មានការចាត់ចែងជាផល គឺ ញ៉ាំងកិច្ចរបស់ខ្លួន និង អ្នកដទៃឲ្យសម្រេចដូចជាងឈើធ្វើកិច្ចឲ្យសម្រេច ។ |
| **-សេសខន្ធត្តយ** | **បទដ្ឋានា** | មានខន្ធ៣ គឺ វេទនា សញ្ញា វិញ្ញាណ ជាហេតុជិត ។ |

# ៥. ឯកគ្គតាចេតសិក

ឯកគ្គតាចេតសិក ជាធម្មជាតិស្ងប់ និងធ្វើឲ្យសម្បយុត្តធម៌ ឲ្យតាំងនៅក្នុងអារម្មណ៍តែមួយជាមួយគ្នា ។

មានវចនត្ថៈថា **នានាលម្ពនវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមិស្សាតិ ឯកគ្គំ ចិត្តំ តស្សភាវោ ឯកគ្គតា។**

**ចិត្ត** ដែលឈ្មោះថា **ឯកគ្គៈ** ដោយអត្ថថា មានអារម្មណ៍

តែមួយ ព្រោះមិនមានសេចក្ដីរាយមាយទៅក្នុងអារម្មណ៍ដទៃផ្សេង ។ ភាវៈនៃចិត្តដែលមានអារម្មណ៍តែមួយនោះ ឈ្មោះថា **ឯកគ្គតា** ។

## លក្ខណាទិចតុកៈរបស់ឯកគ្គតា

| | |
|---|---|
| **-អវិក្ខេប លក្ខណា** | មានការមិនរវើរវាយ មិនឃ្លេងឃ្លោង ជាលក្ខណៈ ។ |
| **-សហជាតានំ សម្បិណ្ឌន រសា** | មានការប្រមូលសហជាតធម៌ មករួមគ្នា ជាកិច្ច ។ |
| **-ឧបសម បច្ចុប្បដ្ឋានា** | មានការចូលទៅស្ងប់ ជាផល។ |
| **-សុខ បទដ្ឋានា** | មានសុខវេទនា ជាហេតុជិត ។ |

## ៦. ជីវិតិន្ទ្រិយ

ជីវិតិន្ទ្រិយចេតសិក ជាធម៌រក្សានូវសម្បយុត្តធម៌ គឺ ឲ្យសម្បយុត្តធម៌តាំងនៅ និងប្រព្រឹត្តទៅបាន ។ ធម៌ឈ្មោះថា **ឥន្ទ្រីយ៍** ព្រោះជាធំក្នុងការអនុបាលធម៌ ដែលកើតរួមជាមួយ មានវចនត្ថៈថា **ជីវន្តិ តេន សម្បយុត្តធម្មាតិ ជីវតំ តទេវ សហជាតានុ-**

**បាលនេ អធិបច្ចយោគេន ឥន្ទ្រិយន្តិ ជីវិតិន្ទ្រិយំ ។**

ឈ្មោះថា **ជីវិត** ព្រោះអត្ថថា ជាគ្រឿងតម្រង់នៅនៃសម្បយុត្តធម៌ ឯជីវិតនោះឯងជាធំ ក្នុងការអនុបាលសហជាតធម៌ ព្រោះហេតុនោះ ទើបឈ្មោះថា **ជីវិតិន្ទ្រីយ៍** ។

# លក្ខណាទិចតុកៈរបស់ជីវិតិន្ទ្រីយ៍

| | |
|---|---|
| **-សហជាតានំ អនុបាលន លក្ខណំ** | មានការតាមរក្សាសហជាតិធម៌ ជាលក្ខណៈ ដូចទឹកចិញ្ចឹមផ្កា។ |
| **-តេសំ បវត្តន រសំ** | មានការញុំាងសម្បយុត្តធម៌ ឲ្យប្រព្រឹត្តទៅ ជាកិច្ច ។ |
| **-តេសញ្ញេវ ថបន បច្ចុប្បដ្ឋានំ** | មានការតាំងនៅបាននៃសហជាតធម៌នោះ ជាអាការប្រាកដ។ |
| **-សេសខន្ធត្តយ បទដ្ឋានំ** | មាននាមខន្ធ ៣ ដែលសល់ ( គឺ វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណខន្ធ ) ជាហេតុជិត ។ |

# ៧. មនសិការចេតសិក

មនសិការចេតសិក ជាធម៌នាំសម្បយុត្តធម៌សំដៅទៅកាន់អារម្មណ៍ មានវចនត្ថៈថា **ករណំ ការោ មនស្មឹ ការោ មនសិការោ** ។

**ការ** = ធ្វើ

**មនសិការ** = ការធ្វើទុកក្នុងចិត្ត ។

## លក្ខណាទិចតុកៈរបស់មនសិការៈ

| | |
|---|---|
| **-សារណ លក្ខណោ** | មានការធ្វើឲ្យសម្បយុត្តធម៌ស្ទុះទៅ ជាលក្ខណៈ ។ |
| **-សម្បយុត្តានំ អារម្មណេ សំយោជន រសោ** | មានការញ៉ាំងសម្បយុត្តធម៌ ឲ្យប្រកបក្នុងអារម្មណ៍ជាកិច្ច ។ |
| **-អារម្មណាភិមុខីភាវ បច្ចុប្បដ្ឋានោ** | មានការធ្វើឲ្យ សម្បយុត្តធម៌តម្រង់មុខឆ្ពោះទៅទល់អារម្មណ៍ជាផល ដូចសារថីញាក់សេះឲ្យទៅកាន់ទិសដែលខ្លួនប្រាថ្នា ។ |

**-អារម្មណ បទដ្ឋានោ** មានអារម្មណ៍ ជាហេតុជិត ។

មនសិការៈមានលក្ខណៈដូចជាសារថីញាក់សេះឲ្យស្ទុះទៅ ។

សតិ ដូចគ្នានឹង មនសិការៈ ដោយអាការប្រាកដ គឺ សតិទល់នឹងអារម្មណ៍ដោយអំណាចការមិនភ្លេច ឯមនសិការៈទល់នឹងអារម្មណ៍ ដោយការធ្វើទុក ការចងទុក ការប្រកប ។

# អំពីមនសិការៈ ៣ យ៉ាង

**១-វិថីបដិបាទកមនសិការ** បានដល់ មនសិការដែលធ្វើឲ្យវិថីចិត្តកើត គឺ បញ្ចទ្វារាវជ្ជនចិត្ត ជាអនន្តរប្បច្ច័យឲ្យចក្ខុវិញ្ញាណជាដើមកើតឡើង ។

**២-ជវនបដិបាទកមនសិការ** បានដល់ មនសិការដែលធ្វើឲ្យជវនចិត្តកើត គឺ មនោទ្វារាវជ្ជនចិត្ត ជាអនន្តរប្បច្ច័យឲ្យជវនចិត្តកើតឡើង ។

**៣-អារម្មណបដិបាទកមនសិការ** បានដល់ មនសិការ-ចេតសិក ដែលធ្វើឲ្យអារម្មណ៍ប្រាកដ បើគ្មានមនសិការចេតសិកទេ អារម្មណ៍ក៏រមែងមិនប្រាកដដែរ ។

ក្នុងសៀវភៅច្បាប់ខ្លះថា មនសិការ ខទី ១ និង ខទី ២ បាន

ដល់ យោនិសោមនសិការ ឬក៏ អយោនិសោមនសិការ ។

# អំពីចេតនា និង មនសិការចេតសិក

ចេតសិកទាំង ២ នេះមានសភាពប្រហែលគ្នា ប៉ុន្តែមិនដូចគ្នាទេ គឺ **ចេតនាចេតសិក** មាននាទីដាស់តឿននូវសម្បយុត្តធម៌ដែលកើតព្រមជាមួយខ្លួន ឲ្យធ្វើកិច្ចរបស់ខ្លួនដោយរៀងៗខ្លួន ចំណែក **មនសិការចេតសិក** មាននាទីនាំនូវសម្បយុត្តធម៌ ដែលកើតព្រមជាមួយខ្លួន ឲ្យតម្រង់ឆ្ពោះទៅ ។

ចេតសិកទាំង ៧ ដួងនេះ ប្រកបជាមួយនឹងចិត្តគ្រប់ដួងទាំងអស់ ពីព្រោះសភាពនៃចិត្តនេះ កើតឡើង គឺ ដើម្បីដឹងនូវអារម្មណ៍ ឯការដឹងនូវអារម្មណ៍បាននោះ ក៏ព្រោះមកអំពី **ផស្សៈ**ធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍ **វេទនា**ជាសភាពសោយរសអារម្មណ៍ **សញ្ញា**ធ្វើកិច្ចចាំអារម្មណ៍ **ចេតនា**ធ្វើកិច្ចចាត់ចែងឲ្យសម្រេច **ឯកគ្គតា**ដែលមានអារម្មណ៍តែមួយ ធ្វើឲ្យសម្បយុត្តធម៌ដែលកើតព្រម ឲ្យតាំងនៅក្នុងអារម្មណ៍នោះ **ជីវិតិន្ទ្រីយ៍**ជាសភាពរក្សាសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅ និង **មនសិការៈ** គឺ ការធ្វើអារម្មណ៍ទុកក្នុងចិត្តនោះឯង ប្រសិនបើចេតសិកទាំង ៧ នេះមិនកើតទេ ចិត្តក៏រមែងកើតមិនបាន ។ ដូច្នេះ

ចេតសិក ៧ ដួងនេះ ទើបជា **សព្វចិត្តសាធារណចេតសិក** យ៉ាងនេះឯង ៕

# ការចែកសព្វចិត្តសាធារណចេតសិក ដោយន័យផ្សេងៗ

**១.ដោយខន្ធ** វេទនាចេតសិក ជាវេទនាខន្ធ សញ្ញាចេតសិក ជាសញ្ញាខន្ធ ចេតសិក ៥ ដែលនៅសល់ ជាសង្ខារក្ខន្ធ ។

**២.ដោយជាតិ** - ចេតសិក ៦ វៀរវេទនាចេតសិក មាន ៤ ជាតិ ។

- សុខ ទុក្ខ មានជាតិ ជាវិបាក ។
- ទោមនស្ស មានជាតិ ជាអកុសល ។
- សោមនស្ស ឧបេក្ខា មាន ៤ ជាតិ ។

**៣.ដោយទ្វារ** ចេតសិក ៦ វៀរវេទនាចេតសិកកើតបាន ៦ ទ្វារ

- សុខ ទុក្ខ កើតតាមកាយទ្វារ ។
- ទោមនស្ស កើតបាន ៦ ទ្វារ ។
- សោមនស្ស ឧបេក្ខា កើតបាន ៦ ទ្វារ និង ទ្វារវិមុត្តិ ។

**៤.ដោយអារម្មណ៍** - ចេតសិក ៦ ដឹងបានអារម្មណ៍ ៦ ។
- សុខ ទុក្ខ ដឹងផោដ្ឋព្វារម្មណ៍ ។
- ទោមនស្ស សោមនស្ស និង ឧបេក្ខា ដឹងបានអារម្មណ៍ ៦ ។

**៥. ដោយភូមិ** - ចេតសិក ៦ កើតបាន ៣០ ភូមិ ( វៀរអសញ្ញសត្តាភូមិ ) ។
- សុខ ទុក្ខ កើតបានក្នុងកាមភូមិ ១១ ។
- ទោមនស្ស កើតបានក្នុងកាមភូមិ ១១ ។
- សោមនស្ស កើតបានក្នុងកាមភូមិ ១១ រូបភូមិ ១៥ និង កើតក្នុងលោកុត្តរភូមិ ។
- ឧបេក្ខា កើតបានក្នុងកាមភូមិ ១១ រូបភូមិ ១៥ អរូបភូមិ ៤ និង ក្នុងលោកុត្តរភូមិ ។

**៦. ដោយវត្ថុ** ចេតសិក ៦ អាស្រ័យបានវត្ថុ ៦

- សុខ ទុក្ខ អាស្រ័យបានតែកាយវត្ថុ
- ទោមនស្ស សោមនស្ស អាស្រ័យបានហទយវត្ថុ ។
- ឧបេក្ខាអាស្រ័យបានវត្ថុ ៥(វៀរកាយវត្ថុ)។

**៧.ដោយហេតុ** ចេតសិកទាំង ៧ ជានហេតុ ។

**៨.ដោយសោភណៈ** ចេតសិក ៦ ជាសោភណៈក៏មាន ជាអសោភណៈ ក៏មាន ។

- សុខ ទុក្ខ ទោមនស្ស ជាអសោភណៈ ។
- សោមនស្ស ឧបេក្ខា ជាសោភណៈក៏មាន ជាអសោភណៈ ក៏មាន ។

**៩.ដោយលោកិយៈ** - ចេតសិក ៦ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។

- សុខ ទុក្ខ ទោមនស្ស ជាលោកិយ ។
- សោមនស្ស ឧបេក្ខា ជាលោកិយក៏មាន ជាលោកុត្តរៈក៏មាន ។

# អធិប្បាយចេតសិក ៦

# វិតក្កចេតសិក

**វិតក្កៈ** មានវចនត្ថៈថា :

**អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ វិតក្កោ** ប្រែថា ធម៌ណាតែងត្រិះរិះ ( នឹកគិត ) ដល់អារម្មណ៍ គឺ លើក សម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វិតក្កៈ** ។

## លក្ខណាទិចតុកៈរបស់វិតក្កៈ

| | |
|---|---|
| **-អារម្មណេ ចិត្តស្ស អភិនិរោបន លក្ខណោ** | មានការលើកចិត្ត ឡើងកាន់អារម្មណ៍ ជាលក្ខណៈ ។ |
| **-អាហននបរិយាហន រសោ** | មានការធ្វើឲ្យចិត្ត ខ្ទប់អារម្មណ៍ ជារឿយ ៗ ជាកិច្ច ។ |
| **-អារម្មណេចិត្តស្ស អានយ** | មានចិត្តដែលនាំមក នៅក្នុង |

**បច្ចុប្បដ្ឋានោ** អារម្មណ៍ ជាផល ។

**-អាបាថវិសយ បទដ្ឋានោ** មានអារម្មណ៍ក្នុងវិថី ជាហេតុជិត ។

**-សេសខន្ធត្តយ បទដ្ឋានោ វា** ឬមានខន្ធដទៃសល់ ៣ ទៀត ( គឺ វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ ) ជាហេតុជិត ។

# ២. វិចារចេតសិក

**វិចារៈ** មានវចនត្ថៈថា :

**អារម្មណេ តេន ធម្មេន ចិត្តំ វិចរតីតិ វិចារោ** ប្រែថា ចិត្តរមែងផ្គងទៅក្នុងអារម្មណ៍ដោយធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វិចារៈ** ។

## លក្ខណាទិចតុកៈរបស់វិចារៈ

- **អារម្មណានុមជ្ជន លក្ខណោ** មានការចូលទៅ ប្រនៀល គឺ ពិចារណាអារម្មណ៍ជារឿយ ។

ជាលក្ខណៈ ។

- **តត្ថ សហជាតានុយោជនរសោ** មានការតាមប្រកបសហជាតធម៌ឲ្យនៅតែក្នុងអារម្មណ៍ ជាកិច្ច។
- **ចិត្តានុប្បពន្ធ បច្ចុប្បដ្ឋានោ** មានការចងចិត្តទុកក្នុងអារម្មណ៍ជាផល ។
- **អារម្មណ៍ បទដ្ឋានោ** មានអារម្មណ៍ ជាហេតុជិត ។
- **សេសខន្ធត្តយ បទដ្ឋានោ វា** ឬ មាននាមខន្ធដទៃសល់ ៣ ទៀត(គឺ វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

# ៣. អធិមោក្ខចេតសិក

**អធិមោក្ខៈ** មានវចនត្ថៈថា :

**អធិមុច្ចនំ អធិមោក្ខោ** ប្រែថា សេចក្តីបង្អោនចិត្តទៅ ( ជឿ ) ឈ្មោះថា **អធិមោក្ខៈ** ។

**អធិមោក្ខៈ** គប្បីឃើញថា ដូចជាសសរខឿន ព្រោះភាពនឹង

ផ្តល់ក្នុងអារម្មណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ។

ចំណែកឯ **អធិមោក្ខៈ** ដែលជា **បសាទាធិមោក្ខៈ** បង្អោន ចិត្តទៅជឿដោយអំណាចសេចក្តីជ្រះថ្លា គឺ ជាកុសល តែម្យ៉ាង ។

# លក្ខណាទិចតុក្កៈរបស់អធិមោក្ខៈ

- **សន្និដ្ឋាន លក្ខណោ** មានការចុះសម្រុងសម្រេច យល់ព្រម ជាលក្ខណៈ ។
- **អសំសប្បន រសោ** មានការមិនឃ្លេងឃ្លោង មិនសង្ស័យ ជាកិច្ច ។
- **វិនិច្ឆ័យ បច្ចុប្បដ្ឋានោ** មានការកាត់សេចក្តី ជាផល ។
- **សន្និដ្ឋេយ្យធម្ម បទដ្ឋានោ** មានធម៌ដែលគប្បី សម្រេចយល់ព្រម ជាហេតុជិត ។

# ៤. វិរិយចេតសិក

**វីរិយៈ** មានវចនត្ថៈថា :

**វិរានំ ភាវោ កម្មំវា វិធិនា ឥរយិតព្វំ បវត្តេតព្វន្តិ**

**វា វិរិយំ ឧស្សាហោ** ប្រែថា ភាវៈ ឬ អំពើនៃបុគ្គលអង់អាច ឈ្មោះថា **វីរិយៈ** ។

ម្យ៉ាងទៀត ធម្មជាតិណា ដែលបុគ្គលគប្បីប្រព្រឹត្តទៅ គប្បីឲ្យប្រព្រឹត្តទៅដោយវិធី( ការទ្រទ្រង់ទុកពិសេស ) ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **វីរិយៈ** បានដល់ សេចក្ដីអត់ធន់ ។

# លក្ខណាទិចតុកៈរបស់វីរិយៈ

- **ឧស្សាហន លក្ខណំ** មានការអង់អាច ហ៊ាន ប្រឹងប្រែង ព្យាយាម ជាលក្ខណៈ។
- **សហជាតានំ ឧបត្ថម្ភន រសំ** មានការឧបត្ថម្ភ ជ្រោមជ្រែងសហជាតធម៌ ជាកិច្ច ។
- **អសំសីទនភាវ បច្ចុប្បដ្ឋានំ** មានការមិនរាថយ ជាផល ។
- **សំវេគវត្ថុ បទដ្ឋានំ** មានសង្វេគវត្ថុ ជាហេតុជិត ។
- **វិរិយារម្ភវត្ថុ បទដ្ឋានំ វា** ឬមានវត្ថុដែលនឹងត្រូវព្យាយាមជាហេតុជិត ។

# សង្វេគវត្ថុ ៨

ហេតុជាទីតាំងនៃសេចក្ដីស្លុតចិត្ត ហៅថា **សង្វេគវត្ថុ** មាន ៨ យ៉ាង គឺ :

ការពិចារណាដល់ ជាតិទុក្ខ ១ ជរាទុក្ខ ១ ព្យាធិទុក្ខ ១ មរណទុក្ខ ១ អបាយិកទុក្ខ ១ អតីតវដ្ដមូលកទុក្ខ ១ អានាគតវដ្ដមូលកទុក្ខ ១ និង ការពិចារណាដល់ទុក្ខក្នុងការស្វែងរកអាហារក្នុងបច្ចុប្បន្ន ១ ។

# ៥. បីតិចេតសិក

**បីតិ** មានវចនត្ថៈថា :

**បិនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា បីតិ** ប្រែថា ធម្មជាតិដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ញុំាងកាយ និង ចិត្តឲ្យឆ្អែត ឲ្យរីករាយ ឬ ញុំាងកាយ និង ចិត្តឲ្យចម្រើន ។

# លក្ខណាទិចតុកៈរបស់បីតិ

**-សម្បិយាយន លក្ខណា** មានសេចក្ដីស្រស់ស្រាយសប្បាយ

ពេញចិត្ត ជាលក្ខណៈ ។

**-កាយចិត្តសម្បីណន រសា** មានការធ្វើឲ្យកាយនិងចិត្តឆ្អែតជាកិច្ច។

**-ឱទគ្យ បច្ចុប្បដ្ឋានា** មានការត្រេកអររីករាយ ជាផល ។

**-សេសខន្ធត្តយ បទដ្ឋានា** មាននាមខន្ធដទៃសល់ ៣ ទៀត ជាហេតុជិត ។

# បីតិមាន ៥ យ៉ាង

**១.ខុទ្ទកាបីតិ** ត្រេកអរចិត្តបន្តិចបន្តួច ( ព្រឺរោម ឬ ចេញទឹកភ្នែក ) ។

**២.ខណិកាបីតិ** ត្រេកអរចិត្តមួយជួរខណៈ ដូចផ្លេកបន្ទោរតែកើតញឹកញាប់ ។

**៣.ឱក្កន្តិកាបីតិ** ត្រេកអរចិត្តមួយស្របក់ៗ ហើយក៏បាត់ទៅ ដូចទឹករលកបោកច្រាំង ហើយក៏បែកទៅ ។

**៤.ឧព្វេង្គាបីតិ** ត្រេកអរចិត្តមានកម្លាំងខ្លាំង រហូតអណ្តែតខ្លួនឡើង ។

**៥.ផរណាបីតិ** ត្រេកអរចិត្តជ្រួតជ្រាប ពាសពេញសព្វសរីរង្គ-កាយ ដូចសំឡីជប់ទឹក ។

# ៦. ឆន្ទចេតសិក

**ឆន្ទះ** មានវចនត្ថៈថា ៖

**ឆន្ទនំ ឆន្ទោ** ប្រែថា សេចក្តីគាប់ចិត្ត ឈ្មោះថា **ឆន្ទះ** ។

**ឆន្ទះ** នេះ មានសេចក្តីប្រាថ្នារូបារម្មណ៍ជាដើម ។

## លក្ខណាទិចតុកៈរបស់ឆន្ទះ

| | |
|---|---|
| **-កត្តុកម្យតា លក្ខណោ** | មានការចូលចិត្ត ប៉ុនប៉ងនឹងធ្វើ ជាលក្ខណៈ ។ |
| **-អារម្មណ បរិយេសន រសោ** | មានការស្វែងរកអារម្មណ៍ ជាកិច្ច ។ |
| **-អារម្មណេន អត្ថិកតា បច្ចុប្បដ្ឋានោ** | មានសេចក្តីប្រាថ្នា ត្រូវការអារម្មណ៍ ជាផល ។ |
| **-អារម្មណ បទដ្ឋានោ** | មានអារម្មណ៍ ជាហេតុជិត ។ |

**ឆន្ទៈ** នេះ ក្នុងការនឹងកាន់យកនូវអារម្មណ៍ គប្បីឃើញថា ដូចចិត្តលូកដៃឈោងទៅដូច្នោះ ។

បកិណ្ណកចេតសិកទាំង ៦ នេះ ជាសង្ខារក្ខន្ធទាំងអស់ មិនចាំបាច់ចែកជាន័យផ្សេងៗទេ ព្រោះកាលណាប្រកបជាមួយនឹងចិត្តដោយន័យយ៉ាងណា ចេតសិកទាំង ៦ នេះក៏មានន័យ ដូចយ៉ាងនោះដែរ ៕

# អធិប្បាយអកុសលចេតសិក ១៤

អកុសលចេតសិកទាំង ១៤ នេះ ជាចេតសិកផ្នែកខាងអាក្រក់ ជាបាប កាលណាប្រកបជាមួយនឹងចិត្ត ក៏រមែងធ្វើឲ្យចិត្តសៅហ្មង ក្តៅក្រហាយ វង្វេងជាដើម ។ អកុសលចេតសិកទាំង ១៤ នេះ ប្រកបបានចំពោះតែចិត្តដែលជាអកុសល ១២ ដួង ប៉ុណ្ណោះ មិនប្រកបជាមួយនឹងអហេតុកចិត្ត ១៨ ដួង និងចិត្តដែលជាសោភណៈទាំងអស់នោះឡើយ ។

# អកុសលចេតសិក ១៤
# មាន ៥ ន័យ

**១. មោចតុកៈ** បានដល់ ចេតសិក ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ។

**២. លោតិកៈ** បានដល់ ចេតសិក ៣ គឺ លោភៈ ទិដ្ឋិ មានៈ ។

**៣. ទោចតុកៈ** បានដល់ ចេតសិក ៤ គឺ ទោសៈ ឥស្សា

មច្ឆរិយៈ កុក្កុច្ចៈ ។

**៤. ថីទុកៈ** បានដល់ ចេតសិក ២ គឺ ថីនៈ មិទ្ធៈ ។

**៥. វិចិកិច្ឆាចេតសិក ១ ។**

ចំពោះមោចតុកចេតសិក ៤ ដួង នេះ ប្រកបជាមួយនឹង អកុសលចិត្ត ១២ ដួង បានទាំងអស់ ដូច្នេះទើប មោចតុកចេតសិក ឈ្មោះថា **សព្វាកុសលសាធារណចេតសិក** ។

# ១. មោហចេតសិក

**មោហៈ** មានវចនត្ថៈថា :

**អារម្មណេ មុយ្ហតីតិ មោហោ អញ្ញាណំ** ប្រែថា ធម៌ដែល ឈ្មោះថា **មោហៈ** ព្រោះអត្ថថា វង្វេងក្នុងអារម្មណ៍ បានដល់ **អញ្ញាណ** ។

សត្វទាំងឡាយ រមែងវង្វេងដោយចេតសិកធម៌នេះ ហេតុនោះ ចេតសិកធម៌នេះ ទើបឈ្មោះថា **មោហៈ** គឺ ធម៌ជាហេតុវង្វេងនៃសត្វទាំងឡាយ ។ ន័យម្យ៉ាងទៀត **មោហៈ** ជាធម៌ដែលវង្វេង គឺ រមែងវង្វេងខ្លួនឯង ។ ន័យម្យ៉ាងទៀត **មោហៈ** គឺ ជា

សេចក្តីវង្វេង ។

# លក្ខណាទិចតុក:របស់មោហ:

-ចិត្តស្ស អន្ធភាវលក្ខណោ មានការងងឹតឈឹងនៃចិត្ត ជាលក្ខណ: ។

-អសម្បដិវេធ រសោ មានសេចក្តីមិនចាក់ធ្លុះ ជានិច្ចជាកិច្ច ។

-អសម្មាបដិបត្តិ បច្ចុប្បដ្ឋានោ មានការបដិបត្តិមិនត្រូវ មិនប្រពៃ ជាផល ។

-អយោនិសោមនសិការ បទដ្ឋានោ មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាហេតុជិត។

## ឬ ន័យម្យ៉ាងទៀត

- អញ្ញាណ លក្ខណោ មានការមិនដឹងធម៌តាមសេចក្តីពិត ជាលក្ខណ: ។

-អារម្មណ សភាវច្ឆាទន រសោ មានការបិទបាំង សភាវ:នៃអារម្មណ៍ ជាកិច្ច ។

**-អន្ធការ បច្ចុប្បដ្ឋានោ** មានការងងឹតងងល់ (ល្ងង់ខ្លៅ) ជាផល ។

**-អយោនិសោមនសិការ បទដ្ឋានោ** មានការមិនធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ជាហេតុជិត។

មោហៈ គប្បីឃើញថា ជាមូលនៃអកុសលទាំងពួង ។

មោហៈ គឺ អវិជ្ជា បានដល់ ការមិនដឹងតាមសេចក្តីពិត ។

ក្នុងទីនេះលោកសម្តែងដល់ការមិនដឹងនូវធម៌ ៨ ប្រការ គឺ :

**១.ទុក្ខេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងទុក្ខសច្ចៈ ។

**២.ទុក្ខសមុទយេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងសមុទយ-សច្ចៈ ។

**៣.ទុក្ខនិរោធេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងទុក្ខនិរោធ-សច្ចៈ ។

**៤.ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងមគ្គសច្ចៈ ។

**៥.បុព្វន្តេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងខន្ធ អាយតនៈ ធាតុដែលជាអតីត ។

**៦.អបរន្តេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងខន្ធ អាយតនៈ

ធាតុដែលជាអនាគត ។

**៧.បុព្វន្តាបរន្តេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងខន្ធ អាយតនៈ ធាតុ ទាំងអតីត ទាំងអនាគត ។

**៨.ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នា កើតឡើងថា ធម៌នេះជាបច្ច័យ ។

# ២. អហិរិកចេតសិក

**អហិរិកៈ** មានវចនត្ថៈថា :

**ន ហិរិយតិ ន លជ្ជិយតីតិ អហិរិកោ បុគ្គលោ ធម្មសមូហោ វា** ប្រែថា បុគ្គល ឬ ការប្រជុំនៃធម៌ ឈ្មោះថា **អហិរិកៈ** ព្រោះអត្ថថា មិនខ្មាស គឺ មិនខ្ពើមនូវបាប ៕

## លក្ខណាទិចតុកៈរបស់អហិរិកៈ

**-កាយទុច្ចរិតាទីហិ អជិគុច្ឆន** មានការមិនខ្ពើម ឬមិនខ្មាសនូវ

**លក្ខណំ អលជ្ជន លក្ខណំ វា** ទុច្ចរិត មានកាយទុច្ចរិតជាដើម ជាលក្ខណៈ ។

**-បាបានំ ករណ រសំ** មានការធ្វើបាប ជាកិច្ច ។

**-អសង្កោចន បច្ចុប្បដ្ឋានំ** មានការមិនត្រឡប់ ចាកបាប ជាផល ។

**-អត្តាគារវ បទដ្ឋានំ** មានការមិនគោរពខ្លួន គឺ មិនខ្មាសដល់ចិត្តខ្លួនឯង ជាហេតុជិត ។

ការមិនខ្មើម មិនខ្មាសនូវបាប រមែងមាន ព្រោះ **អហិរិកៈ** ដូចជាសត្វឆ្កែមិនខ្មើមគម្រង់ ។

# ៣. អនោត្តប្បចេតសិក

**អនោត្តប្បៈ** មានវចនត្ថៈថា :

**ន ឱត្តប្បតីតិ អនោត្តប្បំ** ឈ្មោះថា **អនោត្តប្បៈ** ព្រោះអត្ថថា មិនស្លុត មិនខ្លាច ចំពោះបាប ។

# លក្ខណាទិចតុក្ករបស់អនោត្តប្បៈ

**-អសារជ្ជ លក្ខណំ អនុត្តាស** មានសេចក្តីមិនខ្លាច មិនស្លុត
**លក្ខណំ វា** ជាលក្ខណៈ ។

**-បាបានំ ករណ រសំ** មានការធ្វើបាប ជាកិច្ច ។

**-អសង្កោចន បច្ចុប្បដ្ឋានំ** មានការមិនត្រឡប់ចាកអំពីបាប ជាផល ។

**-បរាគារវ បទដ្ឋានំ** មានការមិនគោរពអ្នកដទៃ គឺ មិនក្រែងរអែងដល់ចិត្តអ្នកដទៃ ជាហេតុជិត ។

ការមិនខ្លាច មិនស្លុតចំពោះបាប រមែងមាន ព្រោះ **អនោ-ត្តប្បៈ** ដូចសត្វមមាចមិនខ្លាចភ្លើង ។

# ៤. ឧទ្ធច្ចចេតសិក

**ឧទ្ធច្ចៈ** មានវចនត្ថៈថា ៖

**ឧទ្ធតស្ស ភាវោ ឧទ្ធច្ចំ** ភាវៈនៃចិត្តដែលរវើរវាយ មិនស្ងប់ ឈ្មោះថា **ឧទ្ធច្ចៈ** ។

**ឧទ្ធច្ចៈ** មានការឆ្វាទៅឆ្វាមកនៃចិត្តចំពោះអារម្មណ៍ គឺរាយមាយ ។

# លក្ខណាទិចតុកៈរបស់ឧទ្ធច្ចៈ

**-អវូបសមន លក្ខណំ** មានការមិនចូលទៅស្ងប់ ជាលក្ខណៈ ដូចទឹកត្រូវខ្យល់ផាត់ ។

**-អនវដ្ឋាន រសំ** មានការមិនតាំងនៅនឹង ក្នុងអារម្មណ៍តែមួយ ជាកិច្ច ដូចជាទង់ត្រូវខ្យល់ ។

**-ភន្តត្ត បច្ចុប្បដ្ឋានំ** មានការភ័ន្តភាំង អណ្តែតអណ្តូង នៃចិត្ត ជាផល ដូចជាពំនូកផេះត្រូវគេគប់នឹងដុំដី ។

**-អយោនិសោមនសិការ បទដ្ឋានំ** មានការធ្វើទុកក្នុងចិត្ត មិនត្រូវ មិនល្អក្នុងអារម្មណ៍នោះ ជាហេតុជិត ។

# ៥. លោភចេតសិក

**លោភៈ** មានវចនត្ថៈថា :

**លុព្ភតីតិ លោភោ** ឈ្មោះថា **លោភៈ** ព្រោះអត្ថថា ប្រាថ្នាចង់បាន ត្រូវការចង់បាន ។ លោភៈនេះ កើតជាមួយនឹង លោមូលចិត្ត ៨ ដួង ។

# លក្ខណាទិចតុកៈរបស់លោភៈ

**-អារម្មណគ្គហណ លក្ខណោ** មានការប្រកាន់មាំក្នុងអារម្មណ៍ ជាលក្ខណៈដូចស្វាជាប់តាំង ។

**-អភិសង្គ រសោ** មានការជាប់ជំពាក់ ក្នុងអារម្មណ៍ ជាកិច្ច ដូចដុំសាច់ដាក់ក្នុងអំបែងក្តៅ ។

**-អបរិច្ចាគ បច្ចុប្បដ្ឋានោ** មានការមិនលះចោល ជាផល ដូចសំពត់ប្រឡាក់ទឹកថ្នាំពណ៌។

**-សំយោជនីយ ធម្មេសុ អស្សាទ ទស្សន បទដ្ឋានោ** មានការមើលដោយសេចក្តីគាប់ចិត្ត ក្នុងធម៌ដែលជាអារម្មណ៍របស់សំយោជនៈ ជាហេតុជិត។

បរិយាយពាក្យវេវចនៈនៃ **លោភៈ** ក្នុងបរមត្ថទីបនី ពោលទុក ១០ យ៉ាង គឺ :

| | | | |
|---|---|---|---|
| **១.តណ្ហា** | សេចក្តីប្រាថ្នា | **២.រាគៈ** | ចំណង់តម្រេក |
| **៣.កាមៈ** | សេចក្តីស្រឡាញ់ | **៤.នន្ទិ** | សេចក្តីភ្លើតភ្លើន |
| **៥.អភិជ្ឈា** | ការសម្លឹងរំពៃ | **៦.ជនេត្តី** | ម្តាយអ្នកឲ្យកំណើត |
| **៧.បោនោព្ភវិកា** | អ្នកឲ្យកើតក្នុងភពថ្មី | **៨.ឥច្ឆា** | ការប្រាថ្នាលាមក |
| **៩.អាសា** | សេចក្តីសង្ឃឹម | **១០.សំយោជនៈ** | គ្រឿងចង |

-**តណ្ហា** មានវចនត្ថៈថា **បរិតសតីតិ តណ្ហា** ឈ្មោះថា **តណ្ហា** ព្រោះអត្ថថា ប្រាថ្នា ត្រូវការ។

-**កាមតណ្ហា** មានវចនត្ថៈថា **កាមោ ច សោ តណ្ហា ចាតិ កាមតណ្ហា** កាមនោះឯង ជាតណ្ហា ទើបឈ្មោះថា **កាមតណ្ហា** ។

-**ភវតណ្ហា** មានវចនត្ថៈថា **សស្សតទិដ្ឋិសហគតោ ហិ រាគោ ភវតណ្ហាតិ វុច្ចតិ** សេចក្តីត្រេកអរ កើតព្រមជាមួយនឹង សេចក្តីយល់ខុសថា ទៀង ហៅថា **ភវតណ្ហា** ។

-**វិភវតណ្ហា** មានវចនត្ថៈថា **ឧច្ឆេទទិដ្ឋិសហគតោ ហិ រាគោ វិភវតណ្ហាតិ វុច្ចតិ** សេចក្តីត្រេកអរ

កើតព្រមជាមួយនឹង សេចក្តីយល់ខុស
ថា ដាច់សូន្យ ហៅថា **វិភវតណ្ហា** ។

# ៦. ទិដ្ឋិចេតសិក

**ទិដ្ឋិ** មានវចនត្ថៈថា **ទស្សនំ ទិដ្ឋិ** សេចក្តីយល់ឃើញ ឈ្មោះថា **ទិដ្ឋិ** ។

ក្នុងអភិធម្មត្ថវិភាវិនីដីកា អធិប្បាយថា **ឥទមេវ សច្ចំ មោឃមញ្ញន្តិ មិច្ឆាភិនិវេស លក្ខណា ទិដ្ឋិ** ប្រែថា ទិដ្ឋិ មានលក្ខណៈប្រកាន់ក្នុងសភាវៈខុសថា “ សភាវៈនេះប៉ុណ្ណោះ ជាសច្ចៈពាក្យដទៃជាមោឃៈ ” ។ ឧទាហរណ៍ យល់ឃើញថា សុខ និង ទុក្ខ ជាធម្មជាតិទៀង ជាដើម ។

# អំពីទិដ្ឋិ ២

**១.សាមញ្ញទិដ្ឋិ** បានដល់ សក្កាយទិដ្ឋិ ដែលមានការយល់ឃើញខុសចាកពីបរមត្ថ ថាជាមនុស្ស ជាសត្វ ជាអត្តា...។ ទិដ្ឋិនេះ មានទូទៅចំពោះបុថុជ្ជនប៉ុណ្ណោះ វៀរព្រះអរិយបុគ្គល ទើបហៅថា

សាមញ្ញទិដ្ឋិ ។

**២.ទិដ្ឋិពិសេស** បានដល់ ទិដ្ឋិ ៦២ វៀរសក្កាយទិដ្ឋិ ព្រោះទិដ្ឋិនេះមានប្រាកដចំពោះបុគ្គលខ្លះៗ និងឱកាសខ្លះៗ ដូចជានិយត-មិច្ឆាទិដ្ឋិ ៣ គឺ នត្ថិកទិដ្ឋិ ១ អហេតុកទិដ្ឋិ ១ និងអកិរិយទិដ្ឋិ ១ ។

ក្នុងអដ្ឋសាលិនី អធិប្បាយថា :

**១.ទិដ្ឋិ** ឈ្មោះថា **ទិដ្ឋិគត** គឺ ដំណើរ ព្រោះធ្វើដំណើរប្រព្រឹត្តទៅក្នុងទិដ្ឋិ ៦២ យ៉ាង ។

**២.ទិដ្ឋិ** នោះឯង ឈ្មោះថា **ទិដ្ឋិគហន** គឺ ការប្រកាន់ ព្រោះឆ្លងកាត់ដោយលំបាកដូចព្រៃស្តុក ។

**៣.ទិដ្ឋិ** នោះឯង ឈ្មោះថា **ទិដ្ឋិកន្តារ** គឺ ផ្លូវកន្តារ ព្រោះជាផ្លូវប្រកបដោយគ្រោះថ្នាក់ ជាផ្លូវលំបាក ដូចផ្លូវកន្តារចោរ ផ្លូវកន្តារសត្វសាហាវ ផ្លូវកន្តារវាលខ្សាច់ ផ្លូវកន្តារទឹក ផ្លូវកន្តារ ទុរ្ភិក្សភ័យ ។

**៤.**ដែលឈ្មោះថា **ទិដ្ឋិវិសូកាយិក** គឺ ចម្រូង ព្រោះទំនាស់ដល់សម្មាទិដ្ឋិ ។

**៥.**ដែលឈ្មោះថា **ទិដ្ឋិវិប្ផន្ទិត** គឺ ការវិបត្តិព្រោះប្រែប្រួល គឺគ្រាខ្លះ ក៏ប្រកាន់ថា ទៀង គ្រា

ខ្លះក៏ប្រកាន់ថា ដាច់សូន្យ ។

**៦.**ដែលឈ្មោះថា **ទិដ្ឋិសំយោជន** ព្រោះជាគ្រឿងចងរួបរឹត ។

**៧.**ដែលឈ្មោះថា **គាហ** ព្រោះប្រកាន់មាំ ក្នុងអារម្មណ៍ទុក ។

**៨.**ដែលឈ្មោះថា **បតិដ្ឋវាហ** ព្រោះជាការបន្សាត់ទៅ ដ៏មានកម្លាំង ។

**៩.**ដែលឈ្មោះថា **អភិនិវេស** ព្រោះប្រកាន់ស្អិតក្នុងខ្លួន និងវត្ថុជារបស់ខ្លួនថា ជារបស់ទៀង ស្ថិតថេរ ។

**១០.**ដែលឈ្មោះថា **កុម្មគ្គ** ព្រោះជាផ្លូវអបាយដែលបណ្ឌិតតក់ស្លុត ហើយខ្ពើម ។

**១១.**ដែលឈ្មោះថា **បរាមាស** គឺ ការស្ទាបអង្អែល ព្រោះកន្លងនូវសភាវៈ កាន់យកតាមប្រការដទៃវិញ ដោយអំណាចនៃការទៀងជាដើម ។

**១២.**ដែលឈ្មោះថា **មិច្ឆាបថ** ព្រោះមិនមែនជាផ្លូវ នៃសេចក្តីពិត ។

**១៣.**ដែលឈ្មោះថា **មិច្ឆត្ត** ព្រោះជាសភាពខុស ដូចជាមនុស្សវង្វេងទិស ។

**១៤.**ដែលឈ្មោះថា **តិត្ថាយតន** ព្រោះជាអណ្តូងកើត និង ជាទីអាស្រ័យកើតឡើង នៃតិរ្ថិយ (និគ្រន្ថអ្នកមានទិដ្ឋិដូចជាកំពង់ទឹក)។

**១៥.**ដែលឈ្មោះថា **វិបរិយេសគ្គាហ** ព្រោះកាន់យកនូវសភាវៈ ដោយការពិចារណាខុសពីសេចក្តីពិត ។

**មិច្ឆាទិដ្ឋិ** ជា **បរមវជ្ជៈ** ( ជាទោសដ៏កំពូល ) ។

# លក្ខណាទិចតុកៈរបស់ទិដ្ឋិ

- **អយោនិសោ អភិនិវេស លក្ខណា** មានការប្រកាន់ស្អិតទុក ដោយមិនមែនជាឧបាយនៃប្រាជ្ញា ជាលក្ខណៈ ។
- **បរាមាស រសា** មានការស្ទាបអង្អែល ខុសពីសភាវៈ ជាកិច្ច ។
- **មិច្ឆាភិនិវេស បច្ចុប្បដ្ឋានា** មានការប្រកាន់មាំ ក្នុងសេចក្តី

យល់ឃើញខុស ជាអាការប្រាកដ ។

- **អរិយានំ អទស្សនកាមតាទិ** មានការមិនចង់ឃើញព្រះអរិយៈ
**បទដ្ឋានា** ជាដើម ជាហេតុជិត ។

# ៧. មានះចេតសិក

**មានះ** មានវចនត្ថៈថា :

**សេយ្យោ ហមស្មីតិ អាទិនា មញ្ញតីតិ មានោ** ឈ្មោះថា **មានះ** ព្រោះអត្ថថា ប្រកាន់ គឺ ក្រអឺតក្រអោង មានជាអាទិថា “ អញជាបុគ្គលប្រសើរជាង ” យ៉ាងនេះជាដើម ។

# អំពីមានះ ២ យ៉ាង

**១.មានះ** ដែលព្រះសោតាបន្នលះបានហៅថា **អយាថាវមានះ** មាន ៦ គឺ :

(១) ប្រសើរជាងគេ មានសេចក្ដីប្រកាន់ថា អញស្មើនឹងគេ។

(២) ប្រសើរជាងគេ មានសេចក្ដីប្រកាន់ថា អញថោកទាបជាងគេ ។

(៣) ស្មើនឹងគេ មានសេចក្តីប្រកាន់ថា អញប្រសើរជាងគេ។

(៤) ស្មើនឹងគេ មានសេចក្តីប្រកាន់ថា អញថោកទាបជាងគេ។

(៥) ថោកទាបជាងគេ មានសេចក្តីប្រកាន់ថា អញប្រសើរជាងគេ ។

(៦) ថោកទាបជាងគេ មានសេចក្តីប្រកាន់ថា អញស្មើនឹងគេ។

**២. មានះ** ដែលព្រះអរហន្តលះបាន ហៅថា **យាថាវ-មានះ** មាន ៣ យ៉ាង គឺ :

(១) ប្រសើរជាងគេ មានសេចក្តីប្រកាន់ថា អញប្រសើរជាងគេ ។

(២) ស្មើនឹងគេ មានសេចក្តីប្រកាន់ថា អញស្មើនឹងគេ ។

(៣) ថោកទាបជាងគេ មានសេចក្តីប្រកាន់ថា អញថោកទាបជាងគេ ។

វិភង្គ អភិធម្មបិដក ពោលនូវ **មានះ** ៣ យ៉ាង គឺ :-

**១.** ការប្រកាន់ថា ប្រសើរជាងគេ ។

**២.** ការប្រកាន់ថា ស្មើនឹងគេ ។

**៣.** ការប្រកាន់ថា ថោកទាបជាងគេ ។

បុគ្គលញ៉ាំងមានះណាមួយឲ្យកើត ព្រោះជាតិ មានជាតិក្សត្រ

ជាដើម ញ៉ាំងមានះឲ្យកើត ព្រោះគោត្រខ្ពង់ខ្ពស់ មានគោតមគោត្រ ជាដើម ព្រោះត្រកូលអ្នកធំ ព្រោះរូបរាង ព្រោះទ្រព្យ ព្រោះ អធិបតេយ្យ ព្រោះមុខងារកិច្ចការ ព្រោះសិល្បៈ ព្រោះការសិក្សា និង ព្រោះបដិភាណ ។

ម្យ៉ាងទៀត **មានះ** មានពាក្យវេវចនៈ លោកពោលទុកយ៉ាង នេះថា ៖

**១.**ឈ្មោះថា **អតិមានះ** សេចក្តីប្រកាន់ដោយ ការបន្តុះបង្អាប់ ការមើលងាយអ្នកដទៃ ។

**២.**ឈ្មោះថា **មានាតិមានះ** សេចក្តីប្រកាន់ គឺ ការក្រអឺតក្រអោង ថា ប្រសើរជាង ។

**៣.**ឈ្មោះថា **ឱមានះ** ការប្រកាន់ថា ថោកទាប ។

**៤.**ឈ្មោះថា **អធិមានះ** សេចក្តីប្រកាន់ថា មានគុណវិសេស ក្នុងខ្លួន ។

**៥.**ឈ្មោះថា **អស្មិមានះ** សេចក្តីប្រកាន់ថា មានអត្តា ថាអញ មានខន្ធគ្រប់គ្រាន់ ។

**៦.**ឈ្មោះថា **មិច្ឆាមានះ** សេចក្តីប្រកាន់ខុស ។

# លក្ខណាទិចតុក:របស់មានះ

| | |
|---|---|
| **-ឧណ្ណតិ លក្ខណោ** | មានការក្រអឺតក្រអោង តម្កើងខ្លួន ជាលក្ខណ: ។ |
| **-សម្បគ្គហ រសោ** | មានការប្រកាន់ឫកខ្ពស់ ជាកិច្ច ។ |
| **-កេតុកម្យតា បច្ចុប្បដ្ឋានោ** | មានការប្រាថ្នាខ្ពស់ដូចជាទង់ ជាអាការប្រាកដ ។ |
| **-ទិដ្ឋិវិប្បយុត្តលោភ បទដ្ឋានោ** | មានលោភ: មិនប្រកបដោយទិដ្ឋិ ជាហេតុជិត ។ |
| **មានះ** | ដូចជាការឆ្កួត ។ |

# ៨. ទោសចេតសិក

**ទោស:** មានវចនត្ថ:ថា :

**ទុស្សតីតិ ទោសោ** ឈ្មោះថា **ទោស:** ព្រោះអត្ថថាប្រទូស្ត ។

ក្នុងវិសុទ្ធិមគ្គ ពោលថា **ទុស្សន្តិ តេន សយ វា ទុស្សតិ**

**ទុស្សនមត្តមេវ វា តន្តិ ទោសោ** ប្រែថា ឈ្មោះថា **ទោសៈ** ព្រោះអត្ថថា ជាហេតុប្រទូស្តក្នុងសត្វ ឬឈ្មោះថា **ទោសៈ** ព្រោះអត្ថថា ប្រទូស្តខ្លួនឯង ឬ ត្រឹមតែការប្រទូស្តប៉ុណ្ណោះ ក៏ឈ្មោះថា **ទោសៈ** ។

**ទោសៈ** នេះគប្បីឃើញថា ដូចជាទឹកម្ជូត្រឆ្អែះ លាយថ្នាំពិស មិនគួរប៉ះពាល់ដោយប្រការទាំងពួង ។

# លក្ខណាទិចតុកៈរបស់ទោសៈ

**-ចណ្ឌិក្ក លក្ខណោ** មានភាពកាចជាលក្ខណៈ ដូចអសិរពិសដែលត្រូវគេវាយ ។

**-វិសប្បន រសោ** មានការក្រហល់ក្រហាយ ជាកិច្ច ដូចត្រូវថ្នាំពិសជ្រាប ។

**-អត្តនោ និស្សយ ទហន រសោ វា** ឬ មានការធ្វើឲ្យឆេះរោលរាលក្តៅខ្លោចផ្សានៃសន្តានរបស់ខ្លួនជាកិច្ច ដូចភ្លើងឆេះព្រៃ ។

**- ទុស្សន បច្ចុប្បដ្ឋានោ** មានការប្រទូស្ត បំផ្លាញ ខឹងក្រោធ ជាអាការប្រាកដ ដូច

សត្រូវបាននូវឱកាស ។

- **អាឃាតវត្ថុ បទដ្ឋានៅ** មានអាឃាតវត្ថុ(១០) ជាហេតុជិត ។

# អាឃាតវត្ថុ ១០ ( ហេតុនៃគំនុំ )

**១.** ចងគំនុំ ដោយគិតថា អ្នកនេះ បានធ្វើអំពើមិនជាប្រយោជន៍ដល់អញហើយ ។

**២.** ចងគំនុំ ដោយគិតថា អ្នកនេះ កំពុងធ្វើអំពើមិនជាប្រយោជន៍ដល់អញ ។

**៣.** ចងគំនុំ ដោយគិតថា អ្នកនេះ នឹងធ្វើអំពើមិនជាប្រយោជន៍ដល់អញ ។

**៤.** ចងគំនុំ ដោយគិតថា អ្នកនេះ បានធ្វើអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញហើយ ។

**៥.** ចងគំនុំ ដោយគិតថា អ្នកនេះ កំពុងធ្វើអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ។

៦. ចងគំនុំ ដោយគិតថា អ្នកនេះ នឹងធ្វើអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់អញ ។

៧. ចងគំនុំ ដោយគិតថា អ្នកនេះ បានធ្វើអំពើជាប្រយោជន៍ដល់ បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ ចិត្តរបស់អញហើយ ។

៨. ចងគំនុំ ដោយគិតថា អ្នកនេះ កំពុងធ្វើអំពើជាប្រយោជន៍ដល់ បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ ចិត្តរបស់អញ ។

៩. ចងគំនុំ ដោយគិតថា អ្នកនេះ នឹងធ្វើអំពើជាប្រយោជន៍ដល់ បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ ចិត្តរបស់អញ ។

១០. ក្រោធក្នុងទីដែលមិនគួរ ដូចជាដើរជំពប់ ឬជាន់បន្លាជាដើម ។

# ៩. ឥស្សាចេតសិក

**ឥស្សា** មានវចនត្ថៈថា :

**ឥស្សតីតិ ឥស្សា** ឈ្មោះថា **ឥស្សា** ព្រោះប្ចស្សា ឈ្នានិស

ប្រណែន ប្រច័ណ្ឌ ។ **ឥស្សា** នេះ ខារខាំងមិនឲ្យអ្នកដទៃបានទូវលាភ សក្ការៈ សេចក្តីគោរពរាប់អាន និងការបូជាជាដើម ។

**ឥស្សា** ជាសំយោជនៈ គ្រឿងចងសត្វទុកក្នុងវដ្តៈ ។

# លក្ខណាទិចតុកៈរបស់ឥស្សា

- **បរសម្បត្តីនំ ឧស្សូយន លក្ខណា** មានការប្រណែនសម្បត្តិ ( ឬសេចក្តីល្អ )របស់អ្នកដទៃ ជាលក្ខណៈ ។
- **តត្ថេវ អនភិរតិ រសា** មានការមិនត្រេកអរក្នុងសេចក្តីមានបានរបស់អ្នកដទៃ ជាកិច្ច ។
- **តតោ វិមុខភាវ បច្ចុប្បដ្ឋានា** មានការងាកមុខចេញពីសម្បត្តិអ្នកដទៃ ជាអាការប្រាកដ ។
- **បរសម្បត្តិ បទដ្ឋានា** មានសម្បត្តិអ្នកដទៃ ជាហេតុជិត។

# មច្ឆរិយចេតសិក

**មច្ឆរិយៈ** មានវចនត្ថៈថា :

**មច្ឆេរស្ស ភាវោ មច្ឆរិយំ** ភាវៈនៃបុគ្គលអ្នកកំណាញ់ ឈ្មោះថា **មច្ឆរិយៈ** ។ **យោជនា** អធិប្បាយថា ធម្មជាតិដែលប្រព្រឹត្តទៅដោយអាការថា “ សេចក្តីអស្ចារ្យនេះ ចូរមានដល់តែអាត្មាអញប៉ុណ្ណោះ ចូរកុំមានដល់ជនដទៃឡើយ ” យ៉ាងនេះ ឈ្មោះថា **មច្ឆរិយៈ** ។

បណ្ឌិតគប្បីឃើញនូវ**មច្ឆរិយៈ**នេះថា ជាការពិការរបស់ចិត្ត ។

# មច្ឆរិយៈ ៥

| | | | | |
|---|---|---|---|---|
| ១. | អាវាស | មច្ឆរិយំ | សេចក្តីកំណាញ់អាវាស | ។ |
| ២. | កុល | មច្ឆរិយំ | សេចក្តីកំណាញ់ត្រកូល | ។ |
| ៣. | លាភ | មច្ឆរិយំ | សេចក្តីកំណាញ់លាភ | ។ |
| ៤. | វណ្ណ | មច្ឆរិយំ | សេចក្តីកំណាញ់គុណ វណ្ណៈ | ។ |
| ៥. | ធម្ម | មច្ឆរិយំ | សេចក្តីកំណាញ់ធម៌ | ។ |

# លក្ខណាទិចតុកៈរបស់មច្ឆរិយៈ

- **អត្តនោសម្បត្តីនំ និគូហណ** មានការលាក់លៀម(កំណាញ់)

| | |
|---|---|
| **លក្ខណំ** | សម្បត្តិរបស់ខ្លួនដែលបានហើយក្តី ឬ ដែលនឹងគួរបានក្តី ជាលក្ខណៈ ។ |
| **- តាសំ យេវ បរេហិ សាធារណភាវ អក្ខមន រសំ** | មានការមិនពេញចិត្ត ឬ ទ្រាំមិនបានក្នុងសម្បត្តិរបស់ខ្លួន ឲ្យជារបស់សាធារណៈ ដល់ជនដទៃ ជាកិច្ច ។ |
| **- សំកោចន បច្ចុប្បដ្ឋានំ** | មានការធ្វើមុខក្រញ៉ូវស្នាក់ស្ទើរហ្មងហែង មិនអើពើ ជាអាការប្រាកដ ។ |
| **- អត្តសម្បត្តិ បទដ្ឋានំ** | មានសម្បត្តិខ្លួន ជាហេតុជិត។ |

# ១១. កុក្កុច្ចចេតសិក

**កុក្កុច្ចៈ** មានវចនត្ថៈថា :

**កុកតស្ស ភាវោ បវត្តនិមិត្តំ កុក្កុច្ចំ ។**

ប្រែថា ភាវៈ គឺ និមិត្តនៃការប្រព្រឹត្តទៅរបស់កម្ម ដែលបណ្ឌិតគប្បីខ្ពើមរអើម ឈ្មោះថា **កុក្កុច្ចៈ** ។

**កុក្កុច្ចៈ** នេះ ជាការកង្វល់ចិត្ត មកអំពីការកើតឡើងនៃចិត្តុប្បាទ ប្រារព្ធកម្ម គឺ ទុច្ចរិតដែលខ្លួនបានធ្វើហើយ និង សុចរិតដែលខ្លួនមិនទាន់បានធ្វើ កម្មនេះ ឈ្មោះថា កម្មដែលបណ្ឌិតស្អប់ ។ បណ្ឌិតគប្បីឃើញ**កុក្កុច្ចៈ**ដូចជាទាសៈ មិនអាចប្រព្រឹត្តតាមទំនើងចិត្តខ្លួន ។

# លក្ខណាទិចតុកៈរបស់កុក្កុច្ចៈ

- **បច្ឆានុតាបន លក្ខណំ** មានសេចក្ដីក្ដៅក្រហាយចិត្តជាខាងក្រោយ ជាលក្ខណៈ ។
- **កតាកតានុសោចន រសំ** មានការសោកសៅជារឿយ ៗ ក្នុងអំពើបាបកម្ម ដែលបានធ្វើហើយ និង កម្មដែលជាបុណ្យនៅមិនទាន់បានធ្វើ ជាកិច្ច ។
- **វិប្បដិសារ បច្ចុប្បដ្ឋានំ** មានការស្ដាយក្រោយ ជាអាការប្រាកដ ។
- **កតាកត បទដ្ឋានំ** មានបាបដែលធ្វើហើយ និង បុណ្យដែលមិនទាន់បានធ្វើ ជាហេតុជិត ។

# ១២. ថីនចេតសិក

**ថីនៈ** មានវចនត្ថៈថា **ថីនតា ថីនំ** សេចក្តីរួញរា សេចក្តីអស់សង្ឃឹម ឈ្មោះថា **ថីនៈ** ។ **ថីនៈ** នេះ មានសភាពមិនគួរដល់ការងារចំពោះចិត្ត និង គប្បីឃើញថា ជាធម៌បៀតបៀនចិត្តឲ្យរួញរាពីអារម្មណ៍ គឺ សេចក្តីរួញនៃចិត្ត ។

## លក្ខណាទិចតុកៈរបស់ថីនៈ

- **អនុស្សាហន លក្ខណំ** មានការមិនអង់អាច ឧស្សាហ៍ (ក្នុងកុសល) ជាលក្ខណៈ ។
- **វិរិយវិនោទន រសំ** មានការកម្ចាត់បង់នូវ សេចក្តីព្យាយាម ជាកិច្ច ។
- **សំសីទន បច្ចុប្បដ្ឋានំ** មានការរួញរានៃចិត្ត ជាអាការប្រាកដ ។
- **អរតី វិជម្ភិកាទីសុ អយោនិសោមនសិការ បទដ្ឋានំ** មានអយោនិសោមនសិការ ក្នុងការមិនត្រេកអរក្នុងកុសល និងការងោកងុយជាដើម ជាហេតុជិត។

# ១៣. មិទ្ធចេតសិក

**មិទ្ធៈ** មានវចនត្ថៈថា **មិជ្ឈនតា មិទ្ធំ** សេចក្ដីងោកងុយរាយមាយ ឈ្មោះថា **មិទ្ធៈ** ។ **មិទ្ធៈ** នេះ មានសភាពមិនគួរដល់ការងារចំពោះចេតសិក និងគប្បីឃើញថា ជាធម៌បៀតបៀនចេតសិក ឡូរញរា គឺ សេចក្ដីសុបសៅនៃកាយ ។

## លក្ខណាទិចតុកៈរបស់មិទ្ធៈ

- **អកម្មញ្ញតា លក្ខណំ** មានការមិនគួរដល់ការងារ មិនរហ័សរហួន ជាលក្ខណៈ ។
- **ឱនហន រសំ** មានការបិទបាំងសហជាតធម៌ ជាកិច្ច។
- **លីនតា បច្ចុប្បដ្ឋានំ** មានការងងុយងោកងក់ រួញរា ជាផល។
- **អរតី វិជម្ភិកាទីសុ អយោនិសោមនសិការ បទដ្ឋានំ** មានអយោនិសោមនសិការ ក្នុងអរតិ និង ការងោកងុយជាដើម ជាហេតុជិត ។

**ថីនៈ** និង **មិទ្ធៈ** ចេតសិកទាំង ២ នេះ ប្រកបនឹងចិត្តដែល

ជាសសង្ខារិក ៥ ដួង គឺ ក្នុងលោភមូលចិត្ត ៤ ដួង និង ទោសមូលចិត្ត ១ ដួង ។ ចេតសិកទាំង ២ នេះ កើតរួមជាមួយគ្នាជានិច្ច ។ **ថីនៈ** ប្រៀបដូចជាដួងភ្លើង **មិទ្ធៈ** ប្រៀបដូចជាពន្លឺរស្មី កាលបើដួងភ្លើងធំ ពន្លឺរស្មីក៏ច្បាស់ បើដួងភ្លើងតូច ពន្លឺរស្មីក៏អន់ថយចុះ ។

# ១៤. វិចិកិច្ឆាចេតសិក

**វិចិកិច្ឆាចេតសិក** ប្រែថា សេចក្តីសង្ស័យ បានដល់ សេចក្តីសង្ស័យ ៨ យ៉ាង គឺ : សង្ស័យក្នុងព្រះពុទ្ធ ១ ក្នុងព្រះធម៌ ១ ក្នុងព្រះសង្ឃ ១ ក្នុងសិក្ខា ១ ក្នុងធម៌ជាអតីត ១ ក្នុងធម៌ជាអនាគត ១ ក្នុងធម៌ជាអតីត និង អនាគត ១ ក្នុងបដិច្ចសមុប្បាទ ១ ។

**វិចិកិច្ឆា** មានវចនត្ថៈថា **វិគតា ចិកិច្ឆាតិ វិចិកិច្ឆា** ឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា សេចក្តីពិតប្រាកដប្រាសទៅហើយ។

## លក្ខណាទិចតុកៈរបស់វិចិកិច្ឆា

- **សំសយន លក្ខណា** មានការសង្ស័យជាលក្ខណៈ ។

**- កម្បន រសា** មានការឃ្លេងឃ្លោង ស្ទើរស្ទាក់ ក្នុងអារម្មណ៍ ជាកិច្ច ។

**- អនិច្ឆយ បច្ចុប្បដ្ឋានា អនេកសគាហ បច្ចុប្បដ្ឋានា វា** មានការមិនអាចអារកាត់សម្រេចចិត្ត វិនិច្ឆ័យបាន ជាផល ឬ មានការកាន់យកចំណែកតែម្យ៉ាង មិនបាន ជាផល ។

**- អយោនិសោមនសិការ បទដ្ឋានា** មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាហេតុជិត ។

**វិចិកិច្ឆា** នេះ គប្បីឃើញថា ជាធម្មជាតិដែលធ្វើនូវសេចក្ដីអន្តរាយដល់ការបដិបត្តិ ៕

# សោភណចេតសិក ២៥ ដួង

**សោភណចេតសិក** ជាចេតសិកផ្នែកខាងល្អ គឺ មិនប្រកប ជាមួយអកុសលចិត្ត ១២ ដួង និង អហេតុកចិត្ត ១៨ ដួង ទេ ប្រកបតែជាមួយសោភណចិត្ត ៥៩ ឬ ៩១ ដួង ដោយពិស្តារ តែប៉ុណ្ណោះ ។

សោភណចេតសិក ២៥ ដួងនេះ ចែកចេញជា ៤ ន័យ គឺ :

| | | | |
|---|---|---|---|
| ១. | សោភណសាធារណចេតសិក | ១៩ | ដួង |
| ២. | វិរតិចេតសិក | ៣ | ដួង |
| ៣. | អប្បមញ្ញាចេតសិក | ២ | ដួង |
| ៤. | បញ្ញាចេតសិក | ១ | ដួង |

# អធិប្បាយ

# សោភណសាធារណចេតសិក ១៩

# ១. សទ្ធាចេតសិក

**សទ្ធា** បានដល់ ការជឿ ការជ្រះថ្លាក្នុងព្រះពុទ្ធ ក្នុងព្រះធម៌

ក្នុងព្រះសង្ឃ ក្នុងកម្ម ក្នុងផលនៃកម្ម និង ក្នុងសេចក្ដីថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ។

**សទ្ធា** មានវចនត្ថៈថា **សទ្ទហតីតិ សទ្ធា ពុទ្ធាទិសុ បសាទោ** ធម្មជាតិណា តែងជឿ តែងជ្រះថ្លា ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **សទ្ធា** បានដល់ សេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធជាដើម ។

# លោកសន្និវាស ៤

**១.រូបប្បមាណោ** អ្នកដែលកាន់យករូបជាប្រមាណ ។
**២.ឃោសប្បមាណោ** អ្នកដែលកាន់យកសម្លេងជាប្រមាណ។
**៣.លូខប្បមាណោ** អ្នកដែលកាន់យកសេចក្ដីសៅហ្មង ជាប្រមាណ ។
**៤.ធម្មប្បមាណោ** អ្នកដែលកាន់យកធម៌ជាប្រមាណ ។

ព្រះពុទ្ធជាម្ចាស់ កាលមានព្រះជន្មនៅឡើយ តែងជាទីជ្រះថ្លាយ៉ាងក្រៃលែងរបស់លោកសន្និវាស ៤ នេះ ព្រោះថាអ្នកដែលនិយមក្នុងរូប ឃើញព្រះរូបដែលប្រកបដោយ មហាបុរិសលក្ខណៈ ៣២ ប្រការ របស់ព្រះអង្គហើយ រមែងជ្រះថ្លាយ៉ាងក្រៃលែង ។ អ្នកដែល

និយមក្នុងសម្លេង បានស្តាប់ព្រះសូរសៀងប្រកបដោយអង្គ ៨ ដូច សម្លេងមហាព្រហ្មហើយ រមែងជ្រះថ្លាក្រៃលែង ។ អ្នកដែលនិយម ក្នុងការគ្រប់ដណ្តប់សំពត់សៅហ្មង លុះឃើញសំពត់មហាបង្សុកូល ចីវររបស់ព្រះអង្គ ដែលបានមកពីសាកសពហើយ រមែងជ្រះថ្លា យ៉ាងក្រៃលែង ។ អ្នកដែលនិយមក្នុងគុណធម៌ទាំងឡាយ គុណធម៌ នៃអ្នកដទៃ មិនអាចបានស្មើដូចជាគុណសីលជាដើម របស់ព្រះពុទ្ធជា ម្ចាស់ឡើយ ។

# លក្ខណាទិចតុកៈរបស់សទ្ធា

**- សទ្ទហន លក្ខណា** មានការជឿ(កុសល) ជាលក្ខណៈ ។
**ឱកប្បន លក្ខណា វា** ឬ មានការជឿមុតមាំ ជាលក្ខណៈ ។
**សម្បក្ខន្ទន លក្ខណា វា** មានការស្ទុះទៅ ជាលក្ខណៈ ។

**- សម្បសាទន រសា** មានការធ្វើឲ្យ ផូរផង់ ជ្រះថ្លា ជាកិច្ច ដូចកែវមណីធ្វើទឹកឲ្យថ្លា ។

**-អកាលុស្សិយ បច្ចុប្បដ្ឋានា** មានការមិនកករល្អក់ ជាផល ។
**-សទ្ធេយ្យវត្ថុ បទដ្ឋានា** មានវត្ថុជាទីតាំង នៃការជឿ ជាហេតុ ជិត ។

**សោតាបត្តិយង្គ បទដ្ឋានា វា** ឬមានសោតាបត្តិយង្គ ៤ ជាហេតុជិត។

**-សទ្ធា** ដូចជាដៃ ក្នុងករណីកាន់យកនូវកុសលទាំងឡាយបាន ។

**-សទ្ធា** ដូចជាទ្រព្យ ក្នុងការញ៉ាំងសម្បត្តិទាំងឡាយឲ្យដល់ព្រម ។

**-សទ្ធា** ដូចជាពូជ ក្នុងករណីបានគ្រាប់កសិផលជាអមតៈ ។

# ២. សតិចេតសិក

**សតិ** មានវចនត្ថៈថា **សរណំ សតិ អសមោសោ** ប្រែថា សេចក្ដីរលឹក ឈ្មោះថា **សតិ** បានដល់ សេចក្ដីមិនវង្វេង មិនភ្លេចភ្លាំង ។

ម្យ៉ាងទៀត **សរន្តិ ឯតាយ សយំវា សរតិ សរណ-មត្តមេវ វា ឯសាតិ សតិ** ប្រែថា បុគ្គលតែងរលឹកបានដោយធម្មជាតិនោះ ដូច្នេះធម្មជាតិនោះ ឈ្មោះថា **សតិ** ឬធម្មជាតិនោះតែងរលឹកខ្លួនឯងបាន ដូច្នេះធម្មជាតិនោះ ឈ្មោះថា **សតិ** ឬធម្មជាតិនោះ ត្រឹមតែ ជាការរលឹកប៉ុណ្ណោះ ដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **សតិ** គឺ សេចក្ដីរលឹកបាន ។

# លក្ខណាទិចតុក:របស់សតិ

**-អបិលាបន លក្ខណា** មានការរឭកបាន ក្នុងអារម្មណ៍ ជារឿយៗ មិនភ្លេចស្មារតី គឺ មានសេចក្ដីមិនប្រមាទ ជាលក្ខណៈ ។

**-អសម្មោហ រសា** មានការមិនវង្វេងភ្លេច ជាកិច្ច ។

**-វិសយាភិមុខភាវ បច្ចុប្បដ្ឋានា** មានការតម្រង់មុខឆ្ពោះទៅទល់លក្ខណៈអារម្មណ៍ ជាផល ។

**អារក្ខ បច្ចុប្បដ្ឋានា វា** ឬ មានការរក្សានូវលក្ខណៈអារម្មណ៍ ជាផល ។

**-ថិរសញ្ញា បទដ្ឋានា** មានការចាំបានយ៉ាងមាំ ជាហេតុជិត។

**កាយាទិសតិ បទដ្ឋានា វា** ឬ មានសតិប្បដ្ឋាន មានកាយជាដើម ជាហេតុជិត ។

**សតិ** ដូចជាសសរ ព្រោះដោតយ៉ាងមាំទៅក្នុងអារម្មណ៍ ។ សតិនេះ ដូចអ្នកយាមល្បាតទ្វារ ព្រោះរក្សានូវទ្វារឥន្ទ្រីយ៍ទាំងឡាយ មានចក្ខុន្ទ្រីយ៍ជាដើម ។

# ៣. ហិរិចេតសិក

**ហិរិ** មានវចនត្ថៈថា :

**ហិរិយតិ កាយទុច្ចរិតាទិហិ ជិគុច្ឆតីតិ ហិរិ** ប្រែថា ធម្មជាតិ ដែលឈ្មោះថា **ហិរិ** ព្រោះអត្ថថា ខ្មាស គឺ ខ្ពើមចំពោះទុច្ចរិត មានកាយទុច្ចរិតជាដើម ។

## លក្ខណាទិចតុកៈរបស់ហិរិ

| | |
|---|---|
| **-បាបតោ ជិគុច្ឆន លក្ខណា** | មានការខ្ពើមបាប ជាលក្ខណៈ។ |
| **-បាបានំ អករណ រសា** | មានការមិនធ្វើបាប ជាកិច្ច ។ |
| **-បាបតោ សង្កោចន បច្ចុប្បដ្ឋា** | មានការត្រឡប់ចាកបាប ជាអាការប្រាកដ ។ |
| **-អត្ត គារវ បទដ្ឋានា** | មានការគោរពក្នុងខ្លួន ជាហេតុជិត គឺមានការខ្មាសដល់ចិត្តខ្លួនឯង ។ |

បុគ្គលធ្វើខ្លួនឲ្យជាទីគោរព ទើបលះបាបបានដោយសេចក្តី

ខ្មាស ដូចជាស្ត្រីក្រមុំមានត្រកូល រង្កៀសនឹងវត្ថុបដិកូល ។

# ៤. ឱត្តប្បចេតសិក

**ឱត្តប្បៈ** មានវចនត្ថៈថា :

**តេហិយេវ ឱត្តប្បតីតិ ឱត្តប្ប** ប្រែថា ធម្មជាតិណា រមែងស្លុត ខ្លាច ចំពោះទុច្ចរិតទាំងពួងនោះឯង ធម្មជាតិនោះ ឈ្មោះថា **ឱត្តប្បៈ** ។

## លក្ខណាទិចតុកៈរបស់ឱត្តប្បៈ

- **ឧត្តាសន លក្ខណំ** មានការតក់ស្លុត ខ្លាច ចំពោះបាប ជាលក្ខណៈ ។
- **បាបានំ អករណ រសំ** មានការមិនធ្វើបាប ជាកិច្ច ។
- **បាបតោ សង្កោចន បច្ចុប្បដ្ឋានំ** មានការត្រឡប់ចាកបាប ជាអាការប្រាកដ ។
- **បរ គារវ បទដ្ឋានំ** មានការគោរពអ្នកដទៃ គឺក្រែងរអែងដល់ចិត្តអ្នកដទៃ ជាហេតុជិត ។

**ឱត្តប្បៈ** មានការគោរពអ្នកដទៃ ទើបមិនហ៊ានធ្វើបាប ដូចជាស្ត្រីពេស្យា មានសេចក្តីខ្លាចក្រែងរអែងចិត្តអ្នកដទៃ ។

**ហិរិ** មានសភាពខ្ពើម ខ្មាស ដូចការមិនចាប់ដុំដែកត្រជាក់ដែលប្រឡាក់ទៅដោយលាមក ។ **ឱត្តប្បៈ** មានសភាពខ្លាចក្រែងរអែង ដូចការមិនចាប់ដុំដែកដែលក្តៅ ។

ក្នុង ខុទ្ទកនិកាយ ឥតិវុត្តកៈ ទុកនិបាត ទុតិយភាគ សូត្រទី ៥ បទទី ៤២ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ហិរិ ១ ឱត្តប្បៈ ១ ជាធម្មលោកបាល គឺធម៌រក្សានូវលោក និងជាធម៌នៅដោយស្ងប់។

# ៥. អលោភចេតសិក

**អលោភៈ** មានវចនត្ថៈថា :

**លោភបដិបក្ខោ អលោភោ** ប្រែថា ធម៌ដែលជាបដិបក្ខនឹងលោភៈ ឈ្មោះថា **អលោភៈ** ។

ម្យ៉ាងទៀត **នលុព្ភន្តិ តេន សយំ វា នលុព្ភតិ អលុព្ភនមត្តមេវ វា តន្តិ អលោភោ** ។

ប្រែថា សត្វទាំងឡាយមិនលោភដោយធម៌នោះ ដូច្នេះធម៌នោះ

ឈ្មោះថា **អលោភៈ** ឬធម៌ណាខ្លួនឯងមិនលោភ ធម៌នោះក៏ឈ្មោះថា **អលោភៈ** ឬធម៌នោះមិនលោភតែម្តង ប៉ុណ្ណោះក៏ ឈ្មោះថា **អលោភៈ** ។

# លក្ខណាទិចតុកៈរបស់អលោភៈ

- **អលគ្គភាវ លក្ខណោ** មានការមិនជាប់ មិនជំពាក់ក្នុងអារម្មណ៍ ជាលក្ខណៈ ដូចតំណក់ទឹកមិនជាប់ស្លឹកឈូក ។
- **អបរិគ្គហ រសោ** មានការមិនហួងហែង ជាកិច្ច ដូចភិក្ខុដែលមានចិត្តផុតស្រឡះពីឃរាវាស ។
- **អនល្លីនភាវ បច្ចុប្បដ្ឋានោ** មានការមិនត្រូវការប្រកាន់ក្នុងអារម្មណ៍ ជាផល ដូចបុគ្គលធ្លាក់ក្នុងរណ្តៅលាមក ។
- **យោនិសោមនសិការ បទដ្ឋានោ** មានការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញាជាហេតុជិត ។

# ៦. អទោសចេតសិក

**អទោសៈ** មានវិគ្រោះថា **បដិបក្ខោ អទោសោ** ប្រែថា ធម៌ដែលជាបដិបក្ខនឹងទោសៈ ឈ្មោះថា **អទោសៈ** ។

ន័យដទៃទៀត ដូចគ្នានឹង **អលោភៈ** ។

# លក្ខណាទិចតុកៈរបស់អទោសៈ

- **អចណ្ឌិក្ក លក្ខណោ** មានការមិនកាច មិនក្រោធ ជាលក្ខណៈ ដូចមិត្តសំឡាញ់អ្នកអនុគ្រោះប្រយោជន៍ ។
- **អាឃាត វិនយ រសោ** មានការកម្ចាត់បង់នូវគំនុំ គុំគួន ជាកិច្ច ។
- **សោមភាវ បច្ចុប្បដ្ឋានោ** មានភាពត្រជាក់ ជាផល ដូចរស្មីព្រះចន្ទពេញវង់ ។
- **យោនិសោមនសិការ បទដ្ឋានោ** ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ជាហេតុជិត ។

# ៧. តត្រមជ្ឈត្តតាចេតសិក

**តត្រមជ្ឈត្តតា** មានវិគ្រោះថា :

**តេសុ តេសុ ធម្មេសុ មជ្ឈត្តតា តត្រមជ្ឈត្តតា** ប្រែថា ភាពជាកណ្តាលក្នុងធម៌ទាំងឡាយនោះៗ ឈ្មោះថា **តត្រមជ្ឈត្តតា** ។

## លក្ខណាទិចតុកៈរបស់តត្រមជ្ឈត្តតា

| | |
|---|---|
| - **ចិត្តចេតសិកានំ សមវាហិត លក្ខណា** | មានការទ្រទ្រង់ចិត្តនិងចេតសិកឲ្យស្មើគ្នា ជាលក្ខណៈ ។ |
| - **ឩនាធិកតានិវារណ រសា** | មានការហាមឃាត់ នូវភាពលើសខ្វះគ្នា ជាកិច្ច ។ |
| - **មជ្ឈត្តតាភាវ បច្ចុប្បដ្ឋានា** | មានភាពជាកណ្តាល មិនលំអៀង ជាផល ។ |
| - **សម្បយុត្តានំ បទដ្ឋានា** | មានសម្បយុត្តធម៌ ជាហេតុជិត។ |

តត្រមជ្ឈត្តតាចេតសិកនេះ មានន័យច្រើនយ៉ាង បណ្ឌិតគប្បីឃើញ ជាភាពព្រងើយៗនៃចិត្តនិងចេតសិក ដូចជាសារថីមើលសេះ

អាជានេយ្យរត់ស្មើល្អហើយ ទើបធ្វើព្រងើយដូច្នោះ ។

ចេតសិកនេះ មានភាពព្រងើយ តែនាំសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅស្មើ ក្នុងកិច្ចនាទីរៀងៗខ្លួន ៕

# យុគលធម៌ ៦ គូ

# យុគលធម៌គូ ទី ១

## ៨.កាយបស្សទ្ធិ ៩.ចិត្តបស្សទ្ធិ

ពាក្យថា **កាយបស្សទ្ធិ** បានដល់ ស្ងប់នាមខន្ធ ៣ គឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ។

ចំណែក **ចិត្តបស្សទ្ធិ** បានដល់ ស្ងប់វិញ្ញាណក្ខន្ធ ។

មានវចនត្ថៈថា :

**កាយស្ស បស្សម្ភនំ កាយបស្សទ្ធិ** សេចក្ដីស្ងប់កាយ ឈ្មោះថា **កាយបស្សទ្ធិ** ។

**ចិត្តស្ស បស្សម្ភនំ ចិត្តបស្សទ្ធិ** សេចក្ដីស្ងប់ចិត្ត ឈ្មោះថា **ចិត្តបស្សទ្ធិ** ។

# លក្ខណាទិចតុក:របស់គូទី ១

| | |
|---|---|
| **-កាយចិត្តានំ ទរថ វូបសម លក្ខណា** | មានការស្ងប់នាមក្ខន្ធ ៣ និង ចិត្ត ជាលក្ខណៈ ។ |
| **-កាយចិត្ត ទរថ និម្មទ្ទន រសា** | មានការកម្ចាត់សេចក្តីក្តៅក្រហាយនៃចេតសិក និង ចិត្ត ជាកិច្ច។ |
| **-កាយចិត្តានំ អបរិប្ផន្ទនសីតិភាវ បច្ចុប្បដ្ឋានា** | មានការត្រជាក់ស្លូតបូតមិនប្រែប្រួលនៃចេតសិក និង ចិត្ត ជាផល ។ |
| **-កាយចិត្ត បទដ្ឋានា** | មានចេតសិក និង ចិត្ត ជាហេតុជិត ។ |

**បស្សទ្ធិ** បដិបក្ខនឹងឧទ្ធច្ចៈ ដែលមានការមិនស្ងប់នៃចិត្ត និងចេតសិក ។

# យុគលធម៌គូទី ២

# ១០.កាយលហុតា ១១.ចិត្តលហុតា

**លហុតា** ទាំង ២ នេះ មានវចនត្ថៈថា :

**កាយស្ស លហុភាវោ កាយលហុតា** សេចក្តីស្រាលនៃកាយ គឺ នាមខន្ធ ៣ ឈ្មោះថា **កាយលហុតា** ។

**ចិត្តស្ស លហុភាវោ ចិត្តលហុតា** សេចក្តីស្រាលនៃចិត្ត ឈ្មោះថា **ចិត្តលហុតា** ។

# លក្ខណាទិចតុកៈរបស់គូទី ២

| | |
|---|---|
| - **កាយចិត្ត គរុភាវ វូបសម លក្ខណា** | មានការស្ងប់ភាពធ្ងន់នៃចេតសិក និង ចិត្ត ជាលក្ខណៈ ។ |
| - **កាយចិត្ត គរុភាវ និម្មទ្ទន រសា** | មានការកម្ចាត់នូវភាពធ្ងន់ នៃ ចេតសិក និង ចិត្ត ជាកិច្ច ។ |
| - **កាយចិត្តានំ អទន្ធតា** | មានការរហ័សរហួនមិនចំអៀក |

**បច្ចុប្បដ្ឋានា**          នៃចេតសិក និង ចិត្ត ជាផល។

- **កាយចិត្ត     បទដ្ឋានា**     មាននាមខន្ធ ៤ ជាហេតុជិត ។

**លហុតា** បដិបក្ខនឹងថីនមិទ្ធៈ ដែលមិនរហ័សរហួន យឺត-យូរនៃចិត្ត និង ចេតសិក ។

# យុគលធម៌គូទី ៣

# ១២.កាយមុទុតា ១៣.ចិត្តមុទុតា

**មុទុតា** ទាំង ២ មានវចនត្ថៈថា :

**កាយស្ស មុទុភាវោ កាយមុទុតា** សេចក្តីទន់ភ្លន់នៃកាយ ឈ្មោះថា **កាយមុទុតា** ។

**ចិត្តស្ស មុទុភាវោ ចិត្តមុទុតា** សេចក្តីទន់ភ្លន់នៃចិត្ត ឈ្មោះ ថា **ចិត្តមុទុតា** ។

# លក្ខណាទិចតុកៈរបស់គូទី ៣

- **កាយចិត្ត ថម្ភ វូបសម**     មានការស្ងប់ភាពរឹងត្អឹងនៃកាយ

**លក្ខណា** និង ចិត្ត ជាលក្ខណៈ ។

**-កាយចិត្ត ថម្ភ និម្មទ្ទន រសា** មានការកម្ចាត់ នូវភាពរឹងត្អឹង នៃកាយ និង ចិត្ត ជាកិច្ច ។

**- អប្បដិឃាត បច្ចុប្បដ្ឋានា** មានការមិនចង្អៀតចង្អល់ មិនក្រោធ មិនអាឃាត ជាផល។

**- កាយចិត្ត បទដ្ឋានា** មាននាមខន្ធ ៤ ជាហេតុជិត។

**មុទុតា** បដិបក្ខនឹង ទិដ្ឋិ មានះ ដែលមិនមានភាពទន់ភ្លន់នៃចិត្ត និង ចេតសិក ។

# យុគលធម៌គូទី ៤

# ១៤.កាយកម្មញ្ញតា ១៥.ចិត្តកម្មញ្ញតា

**កម្មញ្ញតា** ទាំង ២ នេះមានវចនត្ថៈថា :

**កាយស្ស កម្មញ្ញភាវោ កាយកម្មញ្ញតា** ការគួរដល់ការងារនៃកាយ ឈ្មោះថា **កាយកម្មញ្ញតា** ។

**ចិត្តស្ស កម្មញ្ញភាវោ ចិត្តកម្មញ្ញតា** សេចក្ដីគួរដល់

ការងារនៃចិត្ត ឈ្មោះថា **ចិត្តកម្មញ្ញតា** ។

# លក្ខណាទិចតុក:របស់គូទី ៤

| | |
|---|---|
| **-កាយចិត្តានំ អកម្មញ្ញភាវ វូបសម លក្ខណា** | មានការស្ងប់នូវភាពមិនគួរដល់ការងារនៃកាយ និង ចិត្ត ជាលក្ខណ: ។ |
| **-កាយចិត្តា កម្មញ្ញភាវ និម្មទ្ទន រសា** | មានការកម្ចាត់ នូវភាពមិនគួរដល់ការងារនៃកាយ និង ចិត្ត ជាកិច្ច ។ |
| **-កាយចិត្តានំ អារម្មណករណ សម្បត្តិ បច្ចុប្បដ្ឋានា** | មានការដល់ព្រម ក្នុងការធ្វើកាយ និង ចិត្ត មានអារម្មណ៍សមគួរដល់ការងារ ជាផល ។ |
| **-កាយចិត្ត បទដ្ឋានា** | មាននាមខន្ធ ៤ ជាហេតុជិត ។ |

**កម្មញ្ញតា** បដិបក្ខនឹង នីវរណ: ដែលសល់ ដែលមិនគួរដល់ការងារនៃចិត្ត និង ចេតសិក ។

**កម្មញ្ញតា** ជាធម៌នាំមកនូវសេចក្តីជ្រះថ្លាក្នុងវត្ថុដែលជាទីតាំង

នៃសេចក្តីជ្រះថ្លា និងនាំមកនូវសេចក្តីក្សេម ដែលប្រព្រឹត្តទៅគួរដល់ការងារ ដូចសេចក្តីបរិសុទ្ធចាកមន្ទិលនៃមាស គួរដល់ការប្រកបជាអលង្ការផ្សេងៗ ។

# យុគលធម៌គូទី ៥

# ១៦.កាយបាគុញ្ញតា ១៧.ចិត្តបាគុញ្ញតា

**បាគុញ្ញតា** ទាំង ២ នេះ មានវចនត្ថៈថា :

**កាយស្ស បាគុញ្ញភាវោ កាយបាគុញ្ញតា** សេចក្តីឈ្លាសស្រួចស្រាលនៃកាយ ឈ្មោះថា **កាយបាគុញ្ញតា** ។

**ចិត្តស្ស បាគុញ្ញភាវោ ចិត្តបាគុញ្ញតា** សេចក្តីឈ្លាសស្រួចស្រាលនៃចិត្ត ឈ្មោះថា **ចិត្តបាគុញ្ញតា** ។

# លក្ខណាទិចតុកៈរបស់គូទី ៥

**-កាយចិត្តានំ គេលញ្ញ វូបសម** មានការស្ងប់នូវអាពាធនៃកាយ

**លក្ខណា** និង ចិត្ត ជាលក្ខណៈ ។

**-កាយចិត្ត គេលញ្ញ និម្មទ្ទន រសា** មានការកម្ចាត់នូវអាពាធកាយ និង អាពាធចិត្ត ជាកិច្ច ។

**-និរាទីនវ បច្ចុប្បដ្ឋានា** មានការប្រាសចាកនូវទោស ជាផល ។

**-កាយចិត្ត បទដ្ឋានា** មាននាមខន្ធ៤ ជាហេតុជិត ។

**បាគុញ្ញតា** បដិបក្ខនឹងការមិនមានសទ្ធា ដែលជាអាពាធនៃចិត្ត និង ចេតសិក ។

# យុគលធម៌គូទី ៦

# ១៨.កាយុជុកតា ១៩.ចិត្តុជុកតា

**ឧជុកតា** ទាំង ២ នេះមានវចនត្ថៈថា :

**កាយស្ស ឧជុកភាវោ កាយុជុកតា** សេចក្តីស្មោះត្រង់នៃកាយ ឈ្មោះថា **កាយុជុកតា** ។

**ចិត្តស្ស ឧជុកភាវោ ចិត្តុជុកតា** សេចក្តីស្មោះត្រង់នៃចិត្ត ឈ្មោះថា **ចិត្តុជុកតា** ។

# លក្ខណាទិចតុក:របស់គូទី ៦

| | |
|---|---|
| -កាយចិត្តានំ អជ្ជវ លក្ខណា | មានការស្មោះត្រង់នៃកាយ និង ចិត្ត ជាលក្ខណៈ ។ |
| -កាយចិត្ត កុដិលភាវ និម្មទ្ទន រសា | មានការកម្ចាត់ នូវការវៀចវេរ នៃកាយនិងចិត្ត ជាកិច្ច ។ |
| -អជិម្ហតា បច្ចុប្បដ្ឋានា | មានភាពត្រង់នៃកាយ និង ចិត្ត ជាផល ។ |
| -កាយចិត្ត បទដ្ឋានា | មាននាមខន្ធ ៤ ជាហេតុជិត ។ |

**ឧជុកតា** បដិបក្ខនឹង **មាយា សាថេយ្យ** ដែលមានការវៀចវេរ មិនស្មោះត្រង់នៃចិត្ត និង ចេតសិក ។

# អធិប្បាយវិរតិចេតសិក ៣

## ១. សម្មាវាចាចេតសិក

**សម្មាវាចា** មានវចនត្ថៈថា :

**សម្មាវាចា** ឯតាយាតិ **សម្មាវាចា** **វចីទុច្ចរិតវិរតិ** ប្រែថា **វិរតិ** ដែលឈ្មោះថា **សម្មាវាចា** ព្រោះអត្ថថា ជាគ្រឿងពោលដោយប្រពៃនៃសត្វទាំងឡាយ បានដល់ ចេតនាគ្រឿងវៀរចាកវចីទុច្ចរិត ។

# សម្មាវាចា ៤

១- ចេតនាវៀរចាកការពោលនូវពាក្យកុហក ។
២- ចេតនាវៀរចាកការនិយាយញុះញង់ ។
៣- ចេតនាវៀរចាកការនិយាយពាក្យអាក្រក់គ្រោតគ្រាត ។
៤- ចេតនាវៀរចាកការនិយាយឥតប្រយោជន៍ ។

# លក្ខណាទិចតុកៈរបស់សម្មាវាចា

| | |
|---|---|
| **-វចីទុច្ចរិតវត្ថុនំ អវីតិក្កមលក្ខណា** | មានការមិនល្មើស មិនកន្លងនូវវត្ថុដែលជាទីតាំង នៃវចីទុច្ចរិតជាលក្ខណៈ ។ |
| **-វចីទុច្ចរិតវត្ថុតោ សង្កោចនរសា** | មានការត្រឡប់ចាកពីវត្ថុ ដែលជាទីតាំងនៃវចីទុច្ចរិត ជាកិច្ច។ |

**-តស្ស អក្រិយ បច្ចុប្បដ្ឋានា** មានការមិនប្រព្រឹត្ត នូវទុច្ចរិតនោះ ជាផល ។

**-សទ្ធាហិរោត្តប្ប អប្បិច្ឆតាទិគុណបទដ្ឋានា** មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត ។

# ២. សម្មាកម្មន្តចេតសិក

**សម្មាកម្មន្តៈ** មានវចនត្ថៈថា :

**សម្មាបវត្តោ កម្មន្តោ សម្មាកម្មន្តោ កាយទុច្ចរិតវិរតិ** ប្រែថា **វិរតិ** ដែលឈ្មោះថា **សម្មាកម្មន្តៈ** ព្រោះអត្ថថា ជាការងារដែលប្រព្រឹត្តទៅដោយប្រពៃនៃសត្វទាំងឡាយ បានដល់ ចេតនាជាគ្រឿងវៀរចាកកាយទុច្ចរិត ។

# សម្មាកម្មន្តៈ ៣

១- ចេតនាវៀរចាកការសម្លាប់សត្វ ។

២- ចេតនាវៀរចាកការលួច ។

៣- ចេតនាវៀរចាកការប្រព្រឹត្តខុសក្នុងកាម ។

# លក្ខណាទិចតុកៈរបស់សម្មាកម្មន្តៈ

| | |
|---|---|
| -កាយទុច្ចរិតវត្ថុនំ អវីតិក្កម លក្ខណោ | មានការមិនល្មើស មិនកន្លងនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាលក្ខណៈ ។ |
| -កាយទុច្ចរិតវត្ថុតោ សង្កោចាន រសោ | មានការត្រឡប់ចាកពីវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាកិច្ច។ |
| -តស្ស អក្រិយ បច្ចុប្បដ្ឋានោ | មានការមិនប្រព្រឹត្តនូវទុច្ចរិតនោះ ជាផល ។ |
| -សទ្ធាហិរោត្តប្ប អប្បិច្ឆតាទិ-គុណ បទដ្ឋានោ | មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត ។ |

# ៣. សម្មាអាជីវចេតសិក

**សម្មាអាជីវៈ** មានវចនត្ថៈថា :

**សម្មាអាជីវន្តិ ឯតេនាតិ សម្មាអាជីវោ មិច្ឆាជីវវិរតិ** ប្រែថា **វិរតិ** ដែលឈ្មោះថា **សម្មាអាជីវៈ** ព្រោះអត្ថថា ជាគ្រឿងទ្រទ្រង់មុខរបរដោយប្រពៃនៃសត្វទាំងឡាយ បានដល់ ចេតនាជាគ្រឿងវៀរចាក មិច្ឆាជីព ។

## សម្មាអាជីវៈ មាន ៧ យ៉ាង

គឺវៀរចាកកាយទុច្ចរិត ៣ វៀរចាកវចីទុច្ចរិត ៤ ដែលមានអាជីពជាហេតុ ឬក៏មានច្រើនយ៉ាង ដោយអំណាចនៃការវៀរចាកការកុហក ល្បួងលួងលោម បោកបញ្ឆោត ប្រចុបប្រចែងជាដើម ។

## លក្ខណាទិចតុកៈរបស់សម្មាអាជីវៈ

| | |
|---|---|
| **-តិវិធកាយទុច្ចរិត ចតុព្វិធវចីទុច្ចរិត វត្ថូនំ អវីតិក្កម លក្ខណោ** | មានការមិនល្មើស មិនកន្លងនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាលក្ខណៈ ។ |
| **-តេសំ វត្ថុតោ សង្កោចនរសោ** | មានការត្រឡប់ចាកពីវត្ថុ ដែលជាទីតាំង នៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ទាំងនោះ ជាកិច្ច។ |

**-តេសំ ទុច្ចរិតានំ អក្រិយ បច្ចុប្បដ្ឋានោ** មានការមិនធ្វើនូវទុច្ចរិត ទាំងនោះ ជាផល ។

**-សទ្ធាហិរោត្តប្ប អប្បិច្ឆតា-ទិគុណ បទដ្ឋានោ** មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត ។

សេចក្តីអធិប្បាយថា ធម៌ដែល ឈ្មោះថា **វិរតិ** ព្រោះអត្ថថា ជាភាវៈនៃការវៀរចាកបាប មានបាណាតិបាតជាដើម ដោយធម៌នោះ ឬជាតួវៀរ ឬថាត្រឹមតែជាការវៀរប៉ុណ្ណោះ ព្រោះមានចេតនាវៀរចាកទុច្ចរិតជាប្រធាន ។ **វិរតិ** ការវៀរចាកបាប សម្បយុត្តដោយកុសលចិត្តនោះ មាន ៣ ប្រភេទ គឺ :-

**១- សម្បត្តវិរតិ**

**២- សមាទានវិរតិ**

**៣- សមុច្ឆេទវិរតិ**

**សម្បត្តវិរតិ** បានដល់ ការវៀរចាកបាបដោយអធ្យាស្រ័យរបស់ខ្លួន គឺជាអ្នកមិនបានសមាទានសិក្ខាបទទាំងឡាយទេ តែបានពិចារណាដល់ជាតិ ដល់សេចក្តីវិនាស និង ដល់ពាហុសច្ចៈរបស់ខ្លួនជាដើម ហើយក៏មិនកន្លងល្មើសវត្ថុដែលប្រាកដដល់ព្រមចំពោះមុខ ។

**សមាទានវិរតិ** បានដល់ ការវៀរចាកបាបដោយសមាទានសិក្ខាបទទាំងឡាយ ក្នុងវេលាសមាទាននោះ និង ក្នុងកាលអស់មួយជីវិតរបស់ខ្លួនតរៀងទៅ ដែលបញ្ញត្តិទុក មាន សីល ៥ សីល ៨ ជាដើម ក៏មិនកន្លងល្មើសឡើយ ។

**សមុច្ឆេទវិរតិ** បានដល់ ការវៀរចាកបាបដោយការកាត់ផ្តាច់ដោយអរិយមគ្គ គឺ **វិរតិ** ដែលសម្បយុត្តជាមួយអរិយមគ្គ ។

កាលណាសមុច្ឆេទវិរតិកើតឡើងហើយ ចិត្តរបស់ព្រះអរិយបុគ្គលទាំងឡាយមិនដែលគិតថា យើងនឹងសម្លាប់សត្វ យ៉ាងនេះឡើយ ។

# អធិប្បាយ
# អប្បមញ្ញាចេតសិក ២

**អប្បមញ្ញា** មានវិគ្រោះថា :

**អប្បមាណេសុ សត្តេសុ ភវតីតិ អប្បមញ្ញា** ប្រែថា ធម្មជាតិឈ្មោះថា **អប្បមញ្ញា** ព្រោះអត្ថថា រមែងផ្សាយលាតសន្ធឹងជានិច្ចកាល ប្រព្រឹត្តជាទូទៅក្នុងសត្វទាំងឡាយ មិនមានប្រមាណ មិនមានដែនកំណត់ ។

# ១. ករុណាចេតសិក

**ករុណា** មានវិគ្រោះថា :

**បរទុក្ខេ សតិសាធូនំ ហទយកម្បនំ ករោតីតិ ករុណា** ប្រែថា ធម្មជាតិណា រមែងធ្វើចិត្តសន្តានរបស់សប្បុរសទាំងឡាយ ឲ្យញាប់ញ័រ នៅស្ងៀមមិនបាន មានសេចក្ដីអាណិតអាសូរ នៅពេលសត្វដទៃបានទទួលនូវសេចក្ដីលំបាក ធម្មជាតិនោះ ឈ្មោះថា **ករុណា** ។

ឬថា **កិណាតិ បរទុក្ខំ ហឹសតិ វិនាសេតីតិ ករុណា** ប្រែថា ធម្មជាតិណា រមែងបៀតបៀន បំបាត់នូវសេចក្ដីទុក្ខរបស់អ្នកដទៃចេញ ធម្មជាតិនោះ ឈ្មោះថា **ករុណា** ។

- **ករុណា** មានសេចក្ដីទុក្ខិតសត្វបញ្ញត្តិ ជាអារម្មណ៍ ។

## លក្ខណាទិចតុកៈរបស់ករុណា

| | |
|---|---|
| **-បរទុក្ខា បនយ កាមតា លក្ខណា** | មានសេចក្ដីប្រាថ្នា ជួយបំបាត់ទុក្ខនៃសត្វដទៃ គឺ អាណិតអាសូរ ជាលក្ខណៈ ។ |

**-បរទុក្ខា សហន រសា** មានការអត់សង្កត់មិនបាន ក្នុងសេចក្តីទុក្ខនៃសត្វដទៃ ជាកិច្ច។

**-អវិហឹសា បច្ចុប្បដ្ឋានា** មានការមិនបៀតបៀន ជាផល។

**-ទុក្ខាភិភូតានំ អនាថភាវទស្សន បទដ្ឋានា** មានការឃើញសត្វ ដែលត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ មិនមានទីពឹង ជាហេតុជិត ។

**វិហឹសូបសមោ សម្បត្តិ** គឺថា **ករុណា** មានការចូលទៅស្ងប់នូវសេចក្តីបៀតបៀន ជាសម្បត្តិ ។

**សោកសម្ភវោ វិបត្តិ** គឺថា **ករុណា** មានការកើតឡើងនៃសេចក្តីសោក ជាវិបត្តិ ។

**គេហសិតំ ទោមនស្សំ អាសន្នបច្ចត្ថិកំ** គឺថា **ករុណា** មានទោមនស្សចិត្តដែលអាស្រ័យកាមគុណ ជាសត្រូវជិត ។

**វិហឹសា ទូរបច្ចត្ថិកា** គឺថា **ករុណា** មានការបៀតបៀនសត្វ ជាសត្រូវឆ្ងាយ ។

# ២. មុទិតាចេតសិក

**មុទិតា** មានវិគ្រោះថា :

**មោទន្តិ ឯតាយាតិ មុទិតា** ប្រែថា បុគ្គលរមែងត្រេកអរ រីករាយក្នុងសេចក្តីសុខ ក្នុងសម្បត្តិគ្រប់គ្រាន់នៃអ្នកដទៃ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **មុទិតា** ។

- **មុទិតា** មានសេចក្តីសុខិតសត្វប្បញ្ញត្តិជាអារម្មណ៍ ។

## លក្ខណាទិចតុកៈរបស់មុទិតា

- **បរសម្បត្តិ អនុមោទន លក្ខណា** មានកាត្រេកអររីករាយក្នុងគុណទ្រព្យ បរិវារ សេចក្តីសុខរបស់សត្វដទៃ ជាលក្ខណៈ ។
- **អនិស្សាយន រសា** មានការមិនច្រណែនក្នុងសម្បត្តិរបស់សត្វដទៃ ជាកិច្ច ។
- **អរតិ វិឃាត បច្ចុប្បដ្ឋានា** មានការកម្ចាត់ នូវសេចក្តីមិនត្រេកអរ ជាផល ។

- **បរសម្បត្តិទស្សន បទដ្ឋានា** មានការឃើញនូវ សេចក្ដីចំរើន
នៃសម្បត្តិ របស់សត្វទាំងឡាយ
ជាហេតុជិត ។

**អរតិវូបសមោ សម្បត្តិ** គឺថា **មុទិតា** មានការចូលទៅស្ងប់នូវសេចក្ដីមិនត្រេកអរ ជាសម្បត្តិ ។

**បហាសសម្ភវោ វិបត្តិ** គឺថា **មុទិតា** មានការសើចសប្បាយ ក្អាកក្អាយ បង្អួតបញ្ចើ ចំណង់ភ្លើតភ្លើន ជាវិបត្តិ ។

**គេហសិតំ សោមនស្សំ អាសន្នបច្ចត្ថិកំ** គឺថា **មុទិតា** មានសោមនស្សចិត្តដែលអាស្រ័យកាមគុណ ជាសត្រូវជិត ។

**អរតិ ទូរបច្ចត្ថិកា** គឺថា **មុទិតា** មានសេចក្ដីមិនត្រេកអរ មិនសប្បាយចិត្ត ក្នុងសេចក្ដីចំរើនរបស់អ្នកដទៃ ជាសត្រូវឆ្ងាយ ។

# អប្បមញ្ញា ៤

**អប្បមញ្ញា ៤** គឺ **មេត្តា ករុណា** មុទិតា **ឧបេក្ខា** ។
ក្នុងអធិការនេះ លោកសម្ដែងតែ **ករុណា** និង **មុទិតា** ។
ឯចំណែក **មេត្តា** ក៏គឺ អទោសចេតសិកនោះឯង និង ចំណែក
**ឧបេក្ខា** ក៏គឺ តត្រមជ្ឈត្តតាចេតសិកនោះឯង ។

# អំពីមេត្តា

**មេត្តា** មានវចនត្ថៈថា :

**មិជ្ជតិ សិនិយ្ហតីតិ មេត្តា** ប្រែថា ធម្មជាតិណា តែងរាប់អានប្រណីដល់សត្វទាំងឡាយ ដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **មេត្តា** អង្គធម៌បានដល់ **អទោសចេតសិក** ដែលមានសេចក្តីចូលចិត្តរាប់អាន ។

**មេត្តា** មានបិយមនាបសត្វបញ្ញត្តិ ជាអារម្មណ៍ ។

# លក្ខណាទិចតុកៈរបស់មេត្តា

**-ហិតាការ បវត្តិ លក្ខណា** មានការប្រព្រឹត្តទៅ នៃកាយ វាចា ចិត្ត ក្នុងការផ្តល់នូវប្រយោជន៍ និង សេចក្តីសុខ ឲ្យដល់សត្វទាំងឡាយ ជាលក្ខណៈ ។

**-ហិតូបសំហារ រសា** មានការនាំនូវប្រយោជន៍ និង សេចក្តីសុខ មកឲ្យដល់សត្វ

ទាំងឡាយយ៉ាងជិតស្និទ្ធ ជាកិច្ច ។

**-អាឃាតវិនយ បច្ចុប្បដ្ឋានា** មានការកម្ចាត់បង់ នូវគំនុំគុំគួន ជាផល ។

**-មនាបភាវ ទស្សន បទដ្ឋានា** មានការឃើញនូវសេចក្ដីត្រេកអរ ពេញចិត្ត របស់សត្វទាំងឡាយ ដោយមិនមានការនឹកដល់ នូវសេចក្ដីអាក្រក់មិនសមរម្យ ជាហេតុជិត ។

**ព្យាបាទូបសមោ សម្បត្តិ** គឺ **មេត្តា** មានការចូលទៅស្ងប់នូវសេចក្ដីព្យាបាទអស់កាលដ៏យូរ ជាសម្បត្តិ ។

**សិនេហ សម្ភវោ វិបត្តិ** គឺថា **មេត្តា** មានការស្រឡាញ់ជាប់ជំពាក់ តណ្ហាក្រាស់ ជាវិបត្តិ ។

**រាគោ អាសន្នបច្ចត្ថិកោ** គឺថា **មេត្តា** មានរាគៈ ជាសត្រូវជិត ។

**ព្យាបាទោ ទូរបច្ចត្ថិកោ** គឺថា **មេត្តា** មានព្យាបាទ ជាសត្រូវឆ្ងាយ ៕

# អំពីឧបេក្ខា

**ឧបេក្ខា** មានវចនត្ថៈថា :

**ព្យាបារប្បហានេន មជ្ឈត្ត ភាវូប គមនេន ច ឧបេក្ខតីតិ ឧបេក្ខា** ប្រែថា ធម្មជាតិណា តែងពិចារណាក្នុងសត្វទាំងឡាយ ប្រមាណល្មម ដោយការមិនស្រឡាញ់ មិនស្អប់ គឺលះបង់នូវសេចក្ដីខ្វល់ខ្វាយ និងមានសភាពជាកណ្ដាល ដូច្នេះធម្មជាតិនោះ ឈ្មោះថា **ឧបេក្ខា** អង្គធម៌បានដល់ **តត្រមជ្ឈត្តតាចេតសិក** ដែលមានសភាពជាកណ្ដាល ។

**ឧបេក្ខា** មានមជ្ឈត្តសត្វបញ្ញត្តិ ជាអារម្មណ៍ ។

# លក្ខណាទិចតុកៈរបស់ឧបេក្ខា

| | |
|---|---|
| **-សត្តេសុ មជ្ឈត្តាការ បវត្តិ លក្ខណា** | មានការប្រព្រឹត្តិទៅជាកណ្ដាល ក្នុងសត្វទាំងឡាយ ជាលក្ខណៈ។ |
| **-សត្តេសុ សមភាវ ទស្សន រសា** | មានការប្រមើល ស្មើភាពគ្នា ក្នុងសត្វទាំងឡាយ ជាកិច្ច ។ |

| | |
|---|---|
| **-បដិយានុនយ រូបសម បច្ចុប្បដ្ឋានា** | មានការស្ងប់នូវសេចក្តីស្អប់ និង មិនមានសេចក្តីស្រឡាញ់ ក្នុងសត្វទាំងឡាយ ជាផល ។ |
| **-បវត្ត កម្មស្សកតា ទស្សន បទដ្ឋានា** | មានការពិចារណា ឃើញថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ជាហេតុជិត ។ |

**បដិឃានុនយ វូបសមោ សម្បត្តិ** គឺ **ឧបេក្ខា** មានសេចក្តីស្ងប់ចាកការស្អប់ និងមិនមានសេចក្តីស្រឡាញ់ ជាសម្បត្តិ ។

**គេហសិតាយ អញ្ញាណុបេក្ខាយ សម្ភវោ វិបត្តិ** គឺថា **ឧបេក្ខា** មានការកើតឡើងនៃអញ្ញាណុបេក្ខា ដែលអាស្រ័យកាមគុណារម្មណ៍ ជាវិបត្តិ ។

**អញ្ញាណុបេក្ខា អាសន្នបច្ចត្ថិកា** គឺថា **ឧបេក្ខា** មានសភាពព្រងើយ ដោយអំណាចនៃមោហៈ ជាសត្រូវជិត ។

**រាគបដិឃ ទូរបច្ចត្ថិកា** គឺថា **ឧបេក្ខា** មានរាគៈ និងទោសៈ ជាសត្រូវឆ្ងាយ ។

# អធិប្បាយ
# បញ្ញិន្ទ្រិយចេតសិក

**បញ្ញា** មានវិគ្រោះថា :

**បធានាតីតិ បញ្ញា** ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា សេចក្ដីដឹងទូទៅ ការដឹងច្បាស់នូវសេចក្ដីពិត គឺ រមែងដឹងទូទៅនូវអរិយសច្ចទាំងឡាយ ដោយន័យថា នេះទុក្ខជាដើម ។

**បញ្ញា** ព្រោះអត្ថថា រមែងឲ្យដឹង គឺ ឲ្យដឹង អនិច្ចំ ទុក្ខំ អនត្តា ។

ម៉្យាងទៀត **បញ្ញា** កាលណាកើតឡើង ក៏រមែងដឹងទូទៅនូវធម៌ទាំងឡាយដែលជាកុសល និងអកុសល ជាធម៌គួរសេព និងមិនគួរសេព ជាធម៌ថោកទាប និងធម៌ប្រណីត និងធម៌ដែលចូលគ្នាបាន និងចូលគ្នាមិនបាន ដូចគ្រូពេទ្យដែលឈ្លាស តែងដឹងនូវថ្នាំដែលជាទីសប្បាយ និង ថ្នាំដែលមិនជាទីសប្បាយដល់អ្នកជម្ងឺ ដូច្នោះ ។

## លក្ខណាទិចតុកៈរបស់បញ្ញា

**-ធម្មសភាវ បដិវេធ លក្ខណា** មានការចាក់ធ្លុះនូវសភាវៈ ជា

| | |
|---|---|
| | លក្ខណៈ ។ |
| **-សភាវ បដិច្ឆាទក មោហន្ធការ វិទ្ធំសន រសា** | មានការកម្ចាត់បង់នូវភាពងងឹត គឺ មោហៈចេញ ដែលបិទបាំងនូវសភាវៈលក្ខណៈ នៃធម៌ទាំងឡាយ ជាកិច្ច ។ |
| **-អសម្មោហ បច្ចុប្បដ្ឋានា** | មានការមិនវង្វេង ជាផល ដូចអ្នកបង្ហាញផ្លូវដល់អ្នកធ្វើដំណើរ។ |
| **-សមាធិ បទដ្ឋានា** | មានសមាធិ ជាហេតុជិត ។ |

# ន័យម្យ៉ាងទៀត

| | |
|---|---|
| **-យថាភូត បដិវេធ លក្ខណា** | មានការដឹងច្បាស់នូវសភាវធម៌តាមសេចក្តីពិត ជាលក្ខណៈ ។ |
| **-វិសយោភាសន រសា** | មានការឆ្លុះបញ្ចាំងនូវ អារម្មណ៍ឲ្យភ្លឺច្បាស់ ជាកិច្ច ដូចប្រទីប។ |
| **-អសម្មោហ បច្ចុប្បដ្ឋានា** | មានការមិនវង្វេង ជាផល ។ |
| **-យោនិសោមនសិការ បទដ្ឋានា** | មានការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ជាហេតុជិត។ |

**-ឥន្ទ្រិយ បរិបាកតា បទដ្ឋានា វា** ឬមានឥន្ទ្រិយចាស់ក្លា ជាហេតុជិត ។

**-កិលេស ទូរិភាវ បទដ្ឋានា វា** ឬ មានការឆ្ងាយពី កិលេសទាំងឡាយ ជាហេតុជិត ។

**-តិហេតុក បដិសន្ធិកតា បទដ្ឋានា វា** ឬមានបដិសន្ធិ ចិត្តជាត្រៃហេតុ ជាហេតុជិត ។

# កម្មស្សកតាបញ្ញា ១០ យ៉ាង

**កម្មស្សកតាបញ្ញា** បានដល់ បញ្ញាដឹងថា សត្វមានកម្មជារបស់ខ្លួន លោកហៅថា **ទសវត្ថុសម្មាទិដ្ឋិ** ប្រែថា សម្មាទិដ្ឋិមាន ១០ យ៉ាង គឺ :

**១.អត្ថិ ទិន្នំ** ឃើញថា ទានដែលគេឲ្យហើយ មានផល ។

**២.អត្ថិ យិដ្ឋំ** ឃើញថា ការបូជាព្រះរតនត្រ័យមានផល ។

**៣.អត្ថិ ហុតំ** ឃើញថា ការបូជាទេវតា មានផល ។

**៤.អត្ថិ សុកតទុក្កតានំ** ឃើញថា ផលនៃកម្មល្អ កម្មអាក្រក់

| | |
|---|---|
| **កម្មានំ ផលំវិបាកោ** | ផលវិបាក មាន ។ |
| **៥.អត្ថិ មាតា** | ឃើញថា គុណរបស់មាតាមាន ។ |
| **៦.អត្ថិ បិតា** | ឃើញថា គុណរបស់បិតាមាន ។ |
| **៧.អត្ថិ អយំលោកោ** | ឃើញថា លោកនេះ គឺ ជាតិនេះ មាន ។ |
| **៨.អត្ថិ បរលោកោ** | ឃើញថា លោកខាងមុខ គឺ ជាតិខាងមុខ មាន ។ |
| **៩.អត្ថិ សត្តាឱបបាតិកា** | ឃើញថា ឱបបាតិកសត្វ គឺ ទេវតា ព្រហ្ម ប្រេត អសុរកាយ និង សត្វនរក មាន ។ |
| **១០.អត្ថិ សមណ-ព្រាហ្មណា សម្មគ្គតា** | ឃើញថា សមណៈព្រាហ្មណ៍ អ្នកមានសីល មានដំណើរល្អ ជាអ្នកប្រតិបត្តិប្រពៃ ហើយប្រកាសនូវលោកនេះ និងលោកខាងមុខឲ្យឃើញច្បាស់ ដោយប្រាជ្ញាខ្លួនឯង ដ៏ក្រៃលែង មាន ។ |

ចេតសិកធម៌ ៥២ ដួង បណ្ឌិតបានពោលទុកជា ៣ ប្រភេទ មាន អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៤ និង

សោភណចេតសិក ២៥ ដោយប្រការយ៉ាងនេះឯង ៕

# អំពីសម្បយោគន័យ

អំពីនេះទៅ នឹងពោលនូវសម្បយោគន័យ គឺ ការប្រកបនៃចេតសិកទាំងនោះ ដែលមិនដាច់គ្នាពីចិត្ត តាមដែលប្រកបបានក្នុងចិត្តុប្បាទទាំងឡាយ នៃដួងនីមួយ ៗ ។

ចេតសិកដែលមិនដាច់គ្នាពីចិត្ត ឈ្មោះថា **ចិត្តាវិយុត្តា** ឯចំពោះចិត្តព្រមទាំងសម្បយុត្តធម៌ ហៅថា **ចិត្តុប្បាទ** ។

**សម្បយុត្តៈ សម្បយោគៈ** និង **សង្គហៈ** មានសេចក្ដីផ្សេងគ្នា ដូចម្ដេច ?

- **សម្បយុត្តៈ** ប្រែថា ប្រកបហើយ បានដល់ ចិត្តប្រកបជាមួយចេតសិក ដូចពាក្យថា **ទិដ្ឋិគតសម្បយុត្តំ** ប្រែថា ចិត្តប្រកបជាមួយនឹងសេចក្ដីយល់ខុស ជាដើម ។

- **សម្បយោគៈ** ប្រែថា ការប្រកបរួមគ្នា បានដល់ ការប្រកបរួមគ្នានៃចេតសិកទាំងឡាយ ដែលមិនដាច់គ្នាពីចិត្ត ។

- **សង្គហៈ** ប្រែថា ការរួបរួម ឬ ការសង្គ្រោះ ក្នុងទីនេះ

សំដៅយកការរាប់ចំនួនចេតសិកក្នុងចិត្ត ៨៩ ដួង ឬ ១២១ ដួង ។

# សម្បយោគ

# សម្បយោគដោយសង្ខេប

សម្បយោគដោយសង្ខេប មាន ៤ ន័យ គឺ :-

**-ន័យទី ១** សព្វចិត្តសាធារណចេតសិក ៧ ដួង ប្រកបបាន ក្នុងចិត្តគ្រប់ដួងទាំងអស់ ។

**-ន័យទី ២** បកិណ្ណកចេតសិក ៦ ដួង ប្រកបបានក្នុងចិត្ត តាមសមគួរ ។

**-ន័យទី ៣** អកុសលចេតសិក ១៤ ដួង ប្រកបបានចំពោះតែ ក្នុងអកុសលចិត្ត ១២ ដួង ។

**-ន័យទី ៤** សោភណចេតសិក ២៥ ដួង ប្រកបបានចំពោះតែ ក្នុងសោភណចិត្ត ៥៩ ឬ ៩១ ដួង ប៉ុណ្ណោះ ។

# សម្បយោគដោយពិស្តារ

សម្បយោគដោយពិស្តារ មាន ១៦ ន័យ គឺ :-

- សព្វចិត្តសាធារណចេតសិក ៧ ដួង មាន ១ ន័យ ។

- បកិណ្ណកចេតសិក ៦ ដួង មាន ៦ ន័យ គឺ :

វិតក្កៈ១ន័យ វិចារៈ១ន័យ អធិមោក្ខៈ១ន័យ វីរិយៈ១ន័យ បីតិ១ន័យ ឆន្ទៈ១ន័យ ។

- អកុសលចេតសិក ១៤ ដួង មាន ៥ ន័យ គឺ :

មោចតុកៈ១ន័យ លោតិកៈ១ន័យ ទោចតុកៈ១ន័យ ថីទុកៈ១ន័យ វិចិកិច្ឆា១ន័យ ។

- សោភណចេតសិក ២៥ ដួង មាន ៤ ន័យ គឺ :

សោភណសាធារណចេតសិក១ន័យ វិរតិ១ន័យ អប្បមញ្ញា១ន័យ បញ្ញា១ន័យ ។

# អធិប្បាយសម្បយោគ

# សម្បយោគន័យ

# សព្វចិត្តសាធារណចេតសិក

**ន័យទី ១ សព្វចិត្តសាធារណចេតសិក ៧ ដួង** មាន ផស្សៈ ជាដើម ប្រកបជាមួយចិត្តបានទាំងអស់ ៨៩ ដួង ឬ ១២១ ដួង ។

# សម្បយោគន័យបកិណ្ណកចេតសិក

- **ន័យទី ១ វិតក្កចេតសិក** ប្រកបជាមួយចិត្ត **៥៥ ដួង** ក្នុងចិត្តពិស្តារ គឺ :-

-កាមាវចរចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណ ១០)

-បឋមជ្ឈានចិត្ត ១១

មិនប្រកបជាមួយចិត្ត **៦៦ ដួង** គឺ:-

-ទ្វិបញ្ចវិញ្ញាណចិត្ត ១០

-ទុតិយជ្ឈានចិត្ត ១១

-តតិយជ្ឈាន ចិត្ត ១១

-ចតុត្ថជ្ឈានចិត្ត ១១

-បញ្ចមជ្ឈានចិត្ត ២៣

- **ន័យទី ២ វិចារចេតសិក** ប្រកបជាមួយចិត្ត **៦៦ ដួង** ក្នុងចិត្តពិស្តារ គឺ:-

-កាមាវចរចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណ ១០)

-បឋមជ្ឈានចិត្ត ១១

-ទុតិយជ្ឈានចិត្ត ១១

មិនប្រកបជាមួយ ចិត្ត **៥៥ ដួង** គឺ:-

-វៀវទ្វិបញ្ចវិញ្ញាណ ១០
-តតិយជ្ឈានចិត្ត ១១
-ចតុត្ថជ្ឈានចិត្ត ១១
-បញ្ចមជ្ឈានចិត្ត ២៣

**- ន័យទី ៣ អធិមោក្ខចេតសិក** ប្រកបជាមួយចិត្ត **៧៨ ឬ ១១០ ដួង** គឺៈ-

-កាមាវចរចិត្ត ៤៣ ( វៀវទ្វិបញ្ចវិញ្ញាណ ១០ វិចិកិច្ឆាសម្បយុត្តចិត្ត ១ )
-មហគ្គតចិត្ត ២៧
-លោកុត្តរចិត្ត ៨ ឬ ៤០ដួង ។

មិនប្រកបជាមួយចិត្ត **១១ ដួង** គឺៈ-

-វៀវទ្វិបញ្ចវិញ្ញាណ ១០
-វិចិកិច្ឆាសម្បយុត្តចិត្ត ១

**ន័យទី ៤ វីរិយចេតសិក** ប្រកបជាមួយចិត្ត **៧៣ ឬ ១០៥ ដួង** គឺៈ

-កាមាវចរចិត្ត ៣៨ (វៀវទ្វិបញ្ចវិញ្ញាណ ១០ សន្តីរណចិត្ត ៣ និងមនោធាតុចិត្ត ៣ )

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត ៨ ឬ ៤០ ដួង ។

មិនប្រកបជាមួយចិត្ត **១៦ ដួង** គឺ:-

-ទ្វិបញ្ចវិញ្ញាណ ១០

-សន្តីរណចិត្ត ៣

-មនោធាតុ ៣

**ន័យទី ៥ បីតិចេតសិក** ប្រកបជាមួយចិត្ត **៥១ ដួង** ក្នុងចិត្តពិស្តារ គឺ:-

-កាមាវចរសោមនស្សសហគតចិត្ត ១៨ ( គឺ លោភសោមនស្សចិត្ត ៤ សោមនស្សសន្តីរណចិត្ត ១ ហសិតុប្បាទចិត្ត ១ និង សោមនស្សកាមាវចរសោភណចិត្ត ១២ )

-បឋមជ្ឈានចិត្ត ១១

-ទុតិយជ្ឈានចិត្ត ១១

-តតិយជ្ឈានចិត្ត ១១

មិនប្រកបជាមួយ ចិត្ត **៧០ ដួង** គឺ:-

-ឧបេក្ខាលោភមូលចិត្ត ៤

-ទោសមូលចិត្ត ២

| | |
|---|---|
| -មោហមូលចិត្ត | ២ |
| -ទ្វិបញ្ចវិញ្ញាណចិត្ត | ១០ |
| -ឧបេក្ខាសន្តីរណចិត្ត | ២ |
| -មនោធាតុចិត្ត | ៣ |
| -មនោទ្វារាវជ្ជនចិត្ត | ១ |
| -ឧបេក្ខាកាមាវចរសោភណចិត្ត | ១២ |
| -ចតុត្ថជ្ឈានចិត្ត | ១១ |
| -បញ្ចមជ្ឈានចិត្ត | ២៣ |

**ន័យទី ៦ ឆន្ទចេតសិក** ប្រកបជាមួយចិត្ត **៦៩ ឬ ១០១ ដួង** គឺ:-

| | |
|---|---|
| -កាមាវចរចិត្ត | ៣៤ ដួង ( វៀរមោហមូល-ចិត្ត ២ និង អហេតុកចិត្ត ១៨ ) |
| -មហគ្គតចិត្ត | ២៧ |
| -លោកុត្តរចិត្ត | ៨ ឬ ៤០ ដួង |

មិនប្រកបជាមួយចិត្ត **២០ ដួង** គឺ:-

| | |
|---|---|
| -មោហមូលចិត្ត | ២ |
| -អហេតុកចិត្ត | ១៨ |

# ចិត្តដែលបកិណ្ណកចេតសិក
# ប្រកប និង មិនប្រកប

| ចេតសិក | ប្រកបក្នុងចិត្ត | មិនប្រកបក្នុងចិត្ត |
|---|---|---|
| វិតក្កចេតសិក | ៥៥ | ៦៦ |
| វិចារចេតសិក | ៦៦ | ៥៥ |
| អធិមោក្ខចេតសិក | ៧៨ ឬ ១១០ | ១១ |
| វីរិយចេតសិក | ៧៣ ឬ ១០៥ | ១៦ |
| បីតិចេតសិក | ៥១ | ៧០ |
| ឆន្ទចេតសិក | ៦៩ ឬ ១០១ | ២០ |

## ចំណាំ

ការសម្តែងចំនួនចិត្ត ដែលប្រកបជាមួយបកិណ្ណកចេតសិកនេះ មាន ២ ន័យ គឺ រាប់ចំនួនចិត្តដោយសង្ខេបខ្លះ និងដោយពិស្តារខ្លះ ពោលគឺ បើចេតសិកណា ប្រកបជាមួយលោកុត្តរចិត្តបានទាំងអស់ ចិត្តដែលប្រកបនោះ គឺ រាប់ដោយសង្ខេប ដូចក្នុងន័យទី៣ ទី៤ ទី៦ តែបើចេតសិកណា ប្រកបជាមួយលោកុត្តរចិត្ត មិនបានទាំងអស់ទេ ចិត្តដែលប្រកបនោះ ក៏រាប់ដោយពិស្តារ ដូចក្នុង

ន័យ ទី១ ទី២ ទី៥ ។

ឬក៏ បើបកិណ្ណកចេតសិកដួងណា មិនមែនជាអង្គឈាន រាប់ចិត្តដែលប្រកបនោះដោយសង្ខេប តែបើជាអង្គឈានវិញ ក៏រាប់ដោយពិស្តារ ។

ប្រការមួយទៀត ចំពោះវិតក្កៈ និង វិចារចេតសិក ដែលប្រកបជាមួយលោកុត្តរចិត្ត ដែលបានសម្តែងមកហើយនោះ សំដៅយកលោកុត្តរចិត្តរបស់ព្រះអរិយបុគ្គល ដែលជាឈានលាភីប៉ុណ្ណោះ ប៉ុន្តែបើព្រះ អរិយបុគ្គលនោះជាសុក្ខវិបស្សកៈ **វិតក្កៈ វិចារចេតសិក** រមែង ប្រកបបានទាំងអស់ ។

ចំណែកឯ **បីតិចេតសិក** វិញ រមែងកើតបានដោយអាស្រ័យលោកុត្តរចិត្តដែលកើតឡើង ពោលគឺ បើលោកុត្តរចិត្តនោះកើតព្រមជាមួយសោមនស្សវេទនា **បីតិចេតសិក** ក៏ប្រកបជាមួយបាន បើលោកុត្តរចិត្តនោះ កើតព្រមជាមួយឧបេក្ខាវេទនា **បីតិចេតសិក** ក៏ប្រកបមិនបាន ។

# សម្បយោគន័យអកុសលចេតសិក

**ន័យទី ១ មោចតុកចេតសិក** គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ៤ ដួងនេះ ប្រកបជាមួយអកុសលចិត្តទាំង ១២ ដួង គឺ៖

-លោភមូលចិត្ត ៨
-ទោសមូលចិត្ត ២
-មោហមូលចិត្ត ២

**ន័យទី ២ លោតិកចេតសិក** គឺ លោភៈ ទិដ្ឋិ មានៈ ៣ ដួងនេះ ប្រកបជាមួយលោភមូលចិត្តទាំង ៨ ដួង ។

**-លោភចេតសិក** ប្រកបក្នុងលោភមូលចិត្ត **៨ ដួង** ។
**-ទិដ្ឋិចេតសិក** ប្រកបនឹងទិដ្ឋិគតសម្បយុត្តចិត្ត **៤ ដួង**។
**-មានចេតសិក** ប្រកបនឹងទិដ្ឋិគតវិប្បយុត្តចិត្ត **៤ ដួង** ។

**ន័យទី ៣ ទោចតុកចេតសិក** គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ៤ ដួង នេះ ប្រកបជាមួយទោសមូលចិត្តទាំង ២ ដួង ។

**ន័យទី ៤ ថីទុកចេតសិក** គឺ ថីនៈ មិទ្ធៈ ២ ដួង នេះ ប្រកបជាមួយអកុសលសសង្ខារិកចិត្ត ៥ ដួង គឺ:

-លោភមូលសសង្ខារិកចិត្ត ៤
-ទោសមូលសសង្ខារិកចិត្ត ១

**ន័យទី ៥ វិចិកិច្ឆាចេតសិក** ១ ដួង នេះ ប្រកបជាមួយតែ

វិចិកិច្ឆាសម្បយុត្តចិត្ត **១ ដួង** ប៉ុណ្ណោះ ។

## សម្បយោគន័យសោភណចេតសិក

**ន័យទី ១ សោភណសាធារណចេតសិក** ១៩ ដួង ប្រកបជាមួយសោភណចិត្តបានទាំង ៥៩ ឬ ៩១ ដួង គឺ:

-កាមាវចរសោភណចិត្ត ២៤

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត ៨ ឬ ៤០ ដួង

**ន័យទី ២ វិរតិចេតសិក** គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ៣ ដួង នេះ ប្រកបជាមួយសោភណចិត្តបាន **១៦ ឬ ៤៨ ដួង** គឺ:

-មហាកុសលចិត្ត ៨

-លោកុត្តរចិត្ត ៨ ឬ ៤០ ដួង

មិនប្រកបជាមួយសោភណចិត្ត ៤៣ ដួង គឺ:

-មហាវិបាកចិត្ត ៨

-មហាកិរិយាចិត្ត ៨

-មហគ្គតចិត្ត ២៧

- **វិរតិចេតសិក** ទាំង ៣ ដួងនេះ កាលណាប្រកបក្នុងលោកុត្តរចិត្ត រមែងប្រកបបានពិតប្រាកដ ហើយព្រមគ្នាទាំង ៣ ក្នុងឋានៈជាអ្នកប្រហារ មិច្ឆាវាចា មិច្ឆាកម្មន្តៈ និង មិច្ឆាអាជីវៈជាសមុច្ឆេទ ។ ប៉ុន្តែកាលណាប្រកបក្នុងមហាកុសលវិញ រមែងប្រកបបានមួយដងមួយកាល គឺ មិនប្រាកដទេ ហើយមិនព្រមគ្នាទៀត មួយដួងៗ ព្រោះមានអារម្មណ៍ផ្សេងគ្នា ។

ហេតុផលដែល **វិរតិចេតសិក ៣** នេះមិនកើតក្នុងមហាវិបាកចិត្ត និងក្នុងមហាកិរិយាចិត្តនោះ ពីព្រោះវិរតិចេតសិកនេះ គឺកើតឡើងដោយការវៀរចាកនូវទុច្ចរិតដែលជាតទង្គៈ ( គឺ ដែលជាអង្គនោះ ) ក្នុងលោកិយៈនោះ រមែងជាកុសលជាតិជានិច្ច និងជាវិបាកជាតិ ឬ កិរិយាជាតិមិនបាន ។ ម្យ៉ាងទៀត ព្រោះមហាវិបាកចិត្តមិនមានវិរមិតព្វវត្ថុ ( គឺ វត្ថុដែលគប្បីវៀរដែលកំពុងប្រាកដចំពោះមុខ ) ហើយនិងព្រោះមហាកិរិយាចិត្តនោះ ជាចិត្តរបស់ព្រះអរហន្ត ដែលលោកបានប្រហារទុច្ចរិតកម្មដោយសមុច្ឆេទប្បហានស្រេចហើយ ។

ហេតុផលដែល **វិរតិចេតសិក ៣** នេះ មិនកើតក្នុងមហគ្គតចិត្ត ពីព្រោះមហគ្គតកុសល និងកិរិយានេះ រមែងកើតឡើងអាស្រ័យដោយ បរិកម្មសមាធិ ឧបចារសមាធិ កើតឡើងពីភាវនាដែលមានកម្មដ្ឋានជាអារម្មណ៍ មិនមែនកើតឡើង ដោយអាស្រ័យការ

វៀរទុច្ចរិតដែលមានវិរមិតព្វវត្ថុជាអារម្មណ៍ ប្រការណាមួយឡើយ ។

ម្យ៉ាងទៀត កាលណា ជាមហគ្គតចិត្តហើយ ក៏មិនចាំបាច់និយាយថា វក្សាវិរតិទៀតនោះដែរ ។

**ន័យទី ៣ អប្បមញ្ញាចេតសិក** គឺ ករុណា និង មុទិតា ២ ដួង នេះ ប្រកបជាមួយសោភណចិត្តបាន ២៨ ដួង គឺ:

| | |
|---|---|
| -មហាកុសលចិត្ត | ៨ |
| -មហាកិរិយាចិត្ត | ៨ |
| -រូបាវចរចិត្ត | ១២ ( វៀររូបាវចរ-បញ្ចមជ្ឈានចិត្ត ៣ )។ |

មិនប្រកបជាមួយសោភណចិត្ត ៣១ ឬ ៦៣ ដួង គឺ:

| | |
|---|---|
| -មហាវិបាកចិត្ត | ៨ |
| -រូបាវចរបញ្ចមជ្ឈានចិត្ត | ៣ |
| -អរូបាវចរឈានចិត្ត | ១២ |
| -លោកុត្តរចិត្ត | ៨ ឬ ៤០ |

**អប្បមញ្ញាចេតសិក** ទាំង២ ដួងនេះ ប្រកបក្នុងសោភណចិត្ត ២៨ ដួងនោះ គឺ អ្នកដែលចំរើន ករុណា មុទិតាកម្មដ្ឋាន ក្នុងកាលដំបូងដែលនៅជាបរិកម្មភាវនា និង ជាបរិកម្មនិមិត្ត មិនទាន់ដល់

ឧគ្គហនិមិត្តទេនោះ ករុណា មុទិតា នឹងកើតឡើងបាន គឺ ចិត្តនោះជាសោមនស្សពិតៗ បើពុំដូច្នោះទេ ក៏នឹងមិនអាចកើតបាន ។ ប៉ុន្តែដល់បានចំរើនកម្មដ្ឋាននោះ តទៅ រហូតដល់បានឧគ្គហនិមិត្ត កើតជំនាញល្អហើយ ករុណា និង មុទិតា រមែងអាចកើតជាមួយសោមនស្សចិត្តក៏បាន ឬ ជាមួយឧបេក្ខាចិត្តក៏បាន យ៉ាងនេះ ។

ហេតុផលដែលអប្បមញ្ញាចេតសិក ២ ដួងនេះ មិនកើតក្នុងមហាវិបាក ៨ ដួង ក្នុងរូបាវចរបញ្ចមជ្ឈានចិត្ត ៣ ដួង ក្នុងអរូបាវចរចិត្ត ១២ ដួង និង ក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ ដួងនោះ ពីព្រោះ ធម្មតាអប្បមញ្ញាចេតសិក ២ នេះ មាន ទុក្ខិតសត្វបញ្ញត្តិ និង សុខិតសត្វបញ្ញត្តិជាអារម្មណ៍ ប៉ុណ្ណោះ ចំណែកឯមហាវិបាកចិត្ត ៨ នឹងអាចកើតឡើង ត្រូវអាស្រ័យកាមារម្មណ៍ដែលជាបរមត្ថអារម្មណ៍ ។

ឯចំណែករូបាវចរបញ្ចមជ្ឈានចិត្ត ៣ ដួង តែងមានមជ្ឈត្ត-សត្វបញ្ញត្តិជាអារម្មណ៍ ចំពោះអរូបាវចចិត្ត ១២ ដួងនោះ កាន់តែមានអារម្មណ៍ប្រណីតជាងទៅទៀត ។ ចំណែក លោកុត្តរចិត្ត ៨ ឬ ៤០ ដួងនោះ គឺ ជាចិត្តមានតែព្រះនិព្វានជាអារម្មណ៍ម្យ៉ាងប៉ុណ្ណោះ ដូច្នេះហើយទើបពោលថា អប្បមញ្ញាចេតសិកនេះ មិនប្រកបក្នុងចិត្ត ៣១ ឬ ៦៣ ដួងនោះ យ៉ាងនេះឯង ។

**ន័យទី ៤ បញ្ញាចេតសិក** ប្រកបជាមួយសោភណចិត្ត បាន

៤៧ ឬ ៧៩ ដួង គឺ:

-កាមាវចរសោភណញាណសម្បយុត្តចិត្ត ១២

-មហគ្គតចិត្ត ២៧

-លោកុត្តរចិត្ត ៨ ឬ ៤០ ដួង

មិនប្រកបជាមួយចិត្ត ១២ ដួង ដែលជាកាមាវចរសោភណ-ញាណវិប្បយុត្តចិត្ត ។

# និយតយោគីចេតសិក និង អនិយតយោគីចេតសិក

ក្នុងបណ្តាចេតសិកទាំង ៥២ ដួងនោះ ចែកចេញជា ២ ពួក គឺ **អនិយតយោគីចេតសិក** មួយពួក និង **និយតយោគីចេតសិក** មួយពួក ។

ពួកចេតសិកទាំងឡាយណា តែងកើតឡើងប្រកបក្នុងចិត្តមិនទៀងទាត់ មិនប្រាកដ មិនកំណត់ គឺថា ជួនកាលកើតឡើងប្រកប ជួនកាលមិនកើតឡើងប្រកប ពួកចេតសិកទាំងនោះ ហៅថា **អនិ-យតយោគីចេតសិក** បានដល់ ចេតសិក ១១ ដួង គឺ:

-ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ

-លោកិយវិរតិ ៣

-អប្បមញ្ញា ២

-មានះ

-ថីនះ មិទ្ធះ

**អនិយតយោគីចេតសិក ១១ ដួង** នេះ ចែកចេញជា ៣ ប្រភេទ គឺ :

**១.** នានាកទាចិចេតសិក

**២.** កទាចិចេតសិក

**៣.** សហាកទាចិចេតសិក

ចេតសិកទាំង ៨ នេះ គឺ **ឥស្សា មច្ឆរិយះ កុក្កុច្ចះ លោកិយវិរតិ ៣** និង **អប្បមញ្ញា ២** ជាចេតសិកប្រកបជាមួយចិត្តមិនទៀងទាត់ គ្រាខ្លះក៏ប្រកប គ្រាខ្លះក៏មិនប្រកប ហើយគ្រាដែលប្រកបក្នុងចិត្តនោះទៀត គឺ ប្រកបបានមួយ ៗ ប៉ុណ្ណោះ មិនប្រកប ២ ឬ ៣ តែម្តងនោះទេ ព្រោះដូច្នោះហើយ ទើបហៅថា **នានាកទាចិចេតសិក** ។

ដូច ឥស្សា មច្ឆរិយះ កុក្កុច្ចះ ទាំង ៣ ដួងនេះ ប្រកបមិន

ទៀងទាត់ គឺថា៖

វេលាណា ទោសចិត្តកើតឡើង ដោយមិនមាន អាការឫស្យាលាក់លៀម កំណាញ់ ឬ ក្តៅក្រហាយស្តាយក្រោយ ជាអារម្មណ៍ណាមួយទេ គឺ កើតឡើងដោយអារម្មណ៍ដទៃ វេលានោះ ទោសចិត្តនោះកើតឡើង មិនមានចេតសិក ៣ នេះប្រកបទេ មានតែទោស-ចេតសិកប្រកបតែឯងប៉ុណ្ណោះ ។

វេលាណា ទោសចិត្តកើតឡើង ដោយមានសេចក្តីឫស្យាច្រណែននូវគុណសេចក្តីល្អរបស់អ្នកដទៃ វេលានោះ ទោសចិត្តក៏មានឥស្សាចេតសិកប្រកប តែមិនមាន មច្ឆរិយៈ កុក្កុច្ចៈ ប្រកបជាមួយទេ។

វេលាណា ទោសចិត្តកើតឡើង ដោយមានសេចក្តីកំណាញ់ក្នុងគុណសេចក្តីល្អរបស់ខ្លួន វេលានោះ ទោសចិត្តក៏មាន មច្ឆរិយ-ចេតសិកប្រកប ឥស្សា និង កុក្កុច្ចៈ ក៏មិនមានប្រកបឡើយ ។

វេលាណា ទោសចិត្តកើតឡើង ដោយមានសេចក្តីក្តៅក្រហាយស្តាយក្រោយក្នុងទុច្ចរិតដែល បានធ្វើរួចហើយ ឬក្នុងសុចរិតដែលមិនទាន់បានធ្វើ វេលានោះ ទោសចិត្តក៏មាន កុក្កុច្ចចេតសិកប្រកប ឥស្សា និង មច្ឆរិយៈ មិនប្រកបជាមួយឡើយ ។

ដូចលោកិយវិរតិ ៣ ដួង នេះ គឺថា៖

វេលាណា មហាកុសលចិត្ត កើតឡើងដោយអាស្រ័យ សទ្ធា

សតិ បញ្ញា មេត្តា ករុណា មុទិតា មិនមានការទាក់ទងនឹងការវៀរចាកនូវទុច្ចរិតតាម កាយ វាចា និង អាជីវៈទេ វេលានោះ មហាកុសលចិត្តនោះ ក៏មិនមានវិរតិចេតសិកប្រកបជាមួយ ។

វេលាណា មហាកុសលចិត្ត កើតឡើងដោយការវៀរចាកនូវវចីទុច្ចរិត ៤ ដែលមិនទាក់ទងនឹងអាជីព វេលានោះ មហាកុសលចិត្តនោះ ក៏មានសម្មាវាចាចេតសិកប្រកប សម្មាកម្មន្តចេតសិក និង សម្មាអាជីវចេតសិក មិនប្រកបជាមួយឡើយ ។

វេលាណា មហាកុសលចិត្ត កើតឡើងដោយការវៀរចាកនូវកាយទុច្ចរិត ៣ ដែលមិនទាក់ទងនឹងអាជីព វេលានោះ សម្មា-កម្មន្តចេតសិក ក៏ចូលប្រកប សម្មាវាចា សម្មាអាជីវៈ មិនប្រកបឡើយ ។

វេលាណា មហាកុសលចិត្ត កើតឡើងដោយការវៀរចាកនូវកាយទុច្ចរិត ឬវចីទុច្ចរិតដែលមាន អាជីពជាប្រធាន វេលានោះ សម្មាអាជីវៈក៏ចូលប្រកប សម្មាវាចា សម្មាកម្មន្តៈ ក៏មិនចូលប្រកបឡើយ ។

ដូចអប្បមញ្ញាចេតសិក ២ ដួង នេះ គឺថាៈ

វេលាណា មហាកុសលចិត្ត ឬមហាកិរិយាចិត្តកើតឡើងដោយអាស្រ័យ សទ្ធា សតិ បញ្ញា ជាដើម មិនបានអាស្រ័យករុណា ឬ

មុទិតាទេ វេលានោះ មហាកុសលចិត្ត ឬ មហាកិរិយាចិត្តនោះ ក៏មិនមានអប្បមញ្ញាចេតសិកចូលប្រកប ។

វេលាណា ដែលរូបាវចរឈានចិត្ត កើតឡើងដោយអាស្រ័យការចំរើនកម្មដ្ឋានដទៃ ៗ មានកសិណជាដើម មិនបានអាស្រ័យការចំរើនអប្បមញ្ញាកម្មដ្ឋានទេ វេលានោះ រូបាវចរឈានចិត្តនោះ អប្បមញ្ញាចេតសិក ក៏មិនចូលប្រកបជាមួយឡើយ ។ សូម្បីខណៈដែលមានឱកាសចូលរួមប្រកបជាមួយចិត្ត ២៨ ដួង ក៏ដោយ ក៏មិនប្រកបព្រមជាមួយគ្នាដែរ

វេលាណា ចិត្ត ២៨ ដួង ទាំងនេះ កើតឡើងដោយអាស្រ័យទុក្ខិតសត្វប្បញ្ញត្តិជាអារម្មណ៍ ឬជាកម្មដ្ឋាន វេលានោះ ករុណាចេតសិក ក៏ចូលប្រកប ចំណែកមុទិតាចេតសិកមិនបានចូលប្រកបទេ ។

វេលាណា ចិត្ត ២៨ ដួង ទាំងនេះ កើតឡើងដោយអាស្រ័យសុខិតសត្វប្បញ្ញត្តិជាអារម្មណ៍ ឬជាកម្មដ្ឋាន វេលានោះ មុទិតាចេតសិក ក៏ចូលប្រកប ចំណែកករុណាចេតសិកមិនបានចូលប្រកបទេ ។

**មានះចេតសិក ១ ដួង** កាលកើតឡើង រមែងប្រកបជាមួយនឹងទិដ្ឋិវិប្បយុត្តលោភចិត្ត ៤ ដួង ណាមួយ តែប្រកបមិនទៀងទាត់ដែរ គឺថា៖

វេលាណា ទិដ្ឋិវិប្បយុត្តលោភចិត្តកើតឡើង ដោយអាស្រ័យការ

ប្រកាន់ ឬកពាក្រអើត តម្កើងខ្លួន វេលានោះ មានះចេតសិក ក៏ប្រកបជាមួយចិត្តនោះ ។

វេលាណា ទិដ្ឋិវិប្បយុត្តលោភចិត្តកើតឡើង ដោយមិនមានការប្រកាន់ឬកពាក្រអើត តម្កើងខ្លួនទេ វេលានោះ មានះចេតសិក ក៏មិនបានប្រកប , ដូច្នេះហើយ ទើបហៅចេតសិកនេះ ថា **កទាចិ-ចេតសិក** ។

**ថីនៈ និង មិទ្ធចេតសិក** ទាំង ២ ដួងនេះ កើតរួមជាមួយគ្នាជានិច្ច មិនដែលប្រាសចាកពីគ្នាទេ តែក៏ចាត់ថា ជាចេតសិកមិនទៀងទាត់នោះ ពីព្រោះ ជួនកាលក៏ប្រកប ជួនកាលក៏មិនប្រកប។

វេលាណា អកុសលសសង្ខារិកចិត្តកើតឡើង តែចិត្តនោះជាចិត្តស្វាហាប់មានកម្លាំង មិនរួញរាទេ វេលានោះ ថីនៈ និង មិទ្ធៈក៏មិនចូលប្រកប ។

ប៉ុន្តែវេលាណា បើអកុសលសសង្ខារិកចិត្តដែលកើតឡើងនោះមានការរួញរា មិនស្វាហាប់ទេ វេលានោះ ថីនៈ និង មិទ្ធៈ ក៏ចូលប្រកបជាមួយ , ព្រោះដូច្នេះហើយ ទើបចេតសិកទាំង ២ នេះហៅថា **សហកទាចិចេតសិក** ។

ចំណែកពួកចេតសិកទាំងឡាយណា តែងកើតឡើងប្រកបក្នុង

ចិត្តទៀងទាត់ប្រាកដជានិច្ច ពួកចេតសិកនោះ ហៅថា **និយតយោគី-ចេតសិក** បានដល់ ចេតសិក ៤១ ដួង គឺ:

-សព្វចិត្តសាធារណចេតសិក ៧
-បកិណ្ណកចេតសិក ៦
-មោចតុកចេតសិក ៤
-លោភចេតសិក ១
-ទិដ្ឋិចេតសិក ១
-ទោសចេតសិក ១
-វិចិកិច្ឆាចេតសិក ១
-សោភណសាធារណចេតសិក ១៩
-បញ្ញាចេតសិក ១

**និយតយោគីចេតសិក ៤១ ដួងនេះ** មានសេចក្តីអធិប្បាយថា :

ក្នុងវេលាណាចិត្ត ៨៩ ឬ ១២១ ដួង កើតឡើង វេលានោះ **សព្វចិត្តសាធារណចេតសិក ៧** រមែងកើតឡើងជាមួយផងជានិច្ច ។

ក្នុងវេលាណាចិត្ត ៥៥ , ចិត្ត ៦៦ , ចិត្ត ៧៨ ឬ ១១០ , ចិត្ត ៧៣ ឬ ១០៥ , ចិត្ត ៥១ , ចិត្ត ៦៩ ឬ ១០១ ដួងកើត

ឡើង វេលានោះ **បកិណ្ណកចេតសិកទាំង** ៦ គឺ វិតក្កៈ វិចារៈ អធិមោក្ខ វីរិយៈ បីតិ ឆន្ទៈ ក៏កើតរួមជាមួយនឹងចិត្តនោះ ៗ តាមលំដាប់ជានិច្ច ។

ក្នុងវេលាណា អកុសលចិត្ត ១២ ដួង កើតឡើង វេលានោះ **មោចតុកចេតសិក ៤** រមែងកើតរួមជាមួយជានិច្ច ។

ក្នុងវេលាណា លោភមូលចិត្ត ៨ ដួងកើតឡើង វេលានោះ **លោភចេតសិក** រមែងកើតរួមជាមួយជានិច្ច ។

វេលាណា ទិដ្ឋិគតសម្បយុត្តលោភចិត្ត ៤ ដួង កើតឡើង វេលានោះ **ទិដ្ឋិចេតសិក** រមែងកើតរួមជាមួយជានិច្ច ។

វេលាណា វិចិកិច្ឆាសម្បយុត្តចិត្តកើតឡើង វេលានោះ **វិចិកិច្ឆាចេតសិក** រមែងកើតរួមជាមួយជានិច្ច ។

វេលាណា សោភណចិត្ត ៥៩ ឬ ៩១ ដួង កើតឡើង វេលានោះ សោភណសាធារណចេតសិក ១៩ រមែងកើតរួមជាមួយគ្រប់ដួងជានិច្ច ។

ក្នុងវេលាណា ញាណសម្បយុត្តចិត្ត ៤៧ ឬ ៧៩ ដួង កើតឡើង វេលានោះ **បញ្ញាចេតសិក** រមែងកើតរួមជាមួយចិត្តនោះជានិច្ច ។ ម្យ៉ាងទៀត វិរតិចេតសិក ៣ ដួង កាលណា កើតក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ ដួង ក៏គឺជា និយតយោគីចេតសិក ប៉ុន្តែ ហៅថា

**និយតឯកតោចេតសិក** ព្រោះជាអង្គមគ្គ ៕

# អំពីសង្គហន័យ

**សង្គហៈ** ប្រែថា ការរួបរួម ឬ ការសង្គ្រោះ តាមន័យនេះ សំដៅដល់ការរួបរួម គឺ ការរាប់ចិត្តដួងនីមួយៗ ដែលមានចេតសិកកើតរួមជាមួយ តើមានចេតសិកអ្វីខ្លះ ឬការរាប់ចេតសិកទាំងឡាយ ដែលកើតរួមជាមួយនឹងចិត្តមួយដួងៗ ដែលកើតឡើង ។

# សង្គហន័យដោយសង្ខេប

**សង្គហន័យ** គឺ ការរាប់ដោយសង្ខេប ចំនួនចេតសិកក្នុងចិត្ត ៨៩ ឬ ១២១ ដួង នោះមាន ៥ ន័យ តាមសមគួរដល់ការប្រកបបាន គឺ :

**ន័យទី ១ លោកុត្តរចិត្ត ៨ ដួង** មានចេតសិកកើតរួម ៣៦ ដួង បានដល់:-

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក ២)

**ន័យទី ២ មហគ្គតចិត្ត ២៧ ដួង** មានចេតសិកកើត រួម ៣៥ ដួង បានដល់:-

-អញ្ញសមានាចេតសិក ១៣
-សោភណចេតសិក ២២ ( វៀរវិរតិចេតសិក ៣ )

**ន័យទី ៣ កាមាវចរសោភណចិត្ត ២៤ ដួង** មានចេតសិកកើត រួម ៣៨ ដួង បានដល់:-

-អញ្ញសមានាចេតសិក ១៣
-សោភណចេតសិក ២៥

**ន័យទី ៤ អកុសលចិត្ត ១២ ដួង** មានចេតសិកកើត រួម ២៧ ដួង បានដល់:-

-អញ្ញសមានាចេតសិក ១៣
-អកុសលចេតសិក ១៤

**ន័យទី ៥ អហេតុកចិត្ត ១៨ ដួង** មានចេតសិកកើត រួម ១២ ដួង បានដល់:-

-អញ្ញសមានាចេតសិក ១២ (វៀរឆន្ទចេតសិក ១) ។

# សង្គហដោយន័យពិស្ដារ

**សង្គហន័យ** គឺ ការរាប់ចំនួនចេតសិក ក្នុងចិត្តដោយពិស្ដារ មាន ៣៣ ន័យ គឺ :

| | | | |
|---|---|---|---|
| - លោកុត្តរចិត្ត | ៤០ ដួង | មាន ៥ | ន័យ |
| - មហគ្គតចិត្ត | ២៧ ដួង | មាន ៥ | ន័យ |
| - កាមាវចរសោភណចិត្ត | ២៤ ដួង | មាន ១២ | ន័យ |
| - អកុសលចិត្ត | ១២ ដួង | មាន ៧ | ន័យ |
| - អហេតុកចិត្ត | ១៨ ដួង | មាន ៤ | ន័យ |

រួមចិត្ត ១២១ ដួង ទាំងអស់ មាន ៣៣ ន័យ ៕

# អធិប្បាយសង្គហន័យ
# សង្គហន័យនៃលោកុត្តរចិត្ត ៥ ន័យ

**លោកុត្តរចិត្ត ៨ ដួង** ដោយសង្ខេប គឺ មគ្គចិត្ត ៤ ផលចិត្ត ៤ នេះ មានចេតសិកកើតរួម **៣៦ ដួង** ស្មើគ្នាទាំងអស់គ្រប់ដួង ។ តែកាលណារាប់**លោកុត្តរចិត្ត**ដោយពិស្តារ **៤០ ដួង** ទើបមានសង្គហៈ ៥ ន័យ ដោយអំណាចនៃអង្គឈាន ដូចតទៅនេះ :

**ន័យទី ១ លោកុត្តរបឋមជ្ឈានចិត្ត ៨ ដួង** មានចេតសិកកើតរួម **៣៦ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣
-សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក២)

**ន័យទី ២ លោកុត្តរទុតិយជ្ឈានចិត្ត ៨ ដួង** មានចេតសិកកើតរួម **៣៥ ដួង** គឺ :

-អញ្ញសមានាចេតសិក ១២ (វៀរវិតក្កៈ)
-សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក២)

**ន័យទី ៣ លោកុត្តរតតិយជ្ឈានចិត្ត ៨ ដួង** មាន ចេតសិកកើតរួម **៣៤ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១១ (វៀរវិតក្កៈ វិចារៈ)

-សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក២)

**ន័យទី ៤ លោកុត្តរចតុត្ថជ្ឈានចិត្ត ៨ ដួង** មាន ចេតសិកកើតរួម **៣៣ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក២)

**ន័យទី ៥ លោកុត្តរបញ្ចមជ្ឈានចិត្ត ៨ ដួង** មាន ចេតសិកកើតរួម **៣៣ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២៣ (វៀរអប្បមញ្ញាចេតសិក២)

# សង្គហន័យ
# នៃមហគ្គតចិត្ត ៥ ន័យ

មហគ្គតចិត្ត ២៧ ដួង គឺ រូបាវចរចិត្ត ១៥ ដួង អរូបាវចរចិត្ត ១២ ដួង មានសង្គហន័យដោយអំណាចនៃអង្គឈាន ទើបធ្វើឲ្យ

ចេតសិកកើតរួមមិនស្មើគ្នា គឺ :-

**ន័យទី ១ រូបាវចរបឋមជ្ឈានចិត្ត ៣ ដួង** មាន ចេតសិកកើតរួម **៣៥ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២២ (វៀរវិរតិចេតសិក ៣)។

**ន័យទី ២ រូបាវចរទុតិយជ្ឈានចិត្ត ៣ ដួង** មាន ចេតសិកកើតរួម **៣៤ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ (វៀរវិតក្កៈ)

-សោភណចេតសិក ២២ (វៀរវិរតិចេតសិក ៣)។

**ន័យទី ៣ រូបាវចរតតិយជ្ឈានចិត្ត ៣ ដួង** មាន ចេតសិកកើតរួម **៣៣ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១១ (វៀរវិតក្កៈ វិចារៈ)

-សោភណចេតសិក ២២ (វៀរវិរតិចេតសិក ៣)។

**ន័យទី ៤ រូបាវចរចតុត្ថជ្ឈានចិត្ត ៣ ដួង** មាន ចេតសិកកើតរួម ៣២ ដួង គឺ :

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)

-សោភណចេតសិក ២២ (វៀរវិរតិចេតសិក ៣)។

**ន័យទី ៥ រូបាវចរបញ្ចមជ្ឈានចិត្ត ៣ ដួង និង អរូបាវចរចិត្ត ១២ ដួង** មានចេតសិកកើតរួម **៣០ ដួង** គឺ :

-អញ្ញសមានាចេតសិក ១០ (វៀរវិតក្កៈ វិចារៈ បីតិ)
-សោភណចេតសិក ២០ ( វៀរវិរតិចេតសិក ៣ អប្បមញ្ញាចេតសិក ២) ។

# សង្គហន័យ នៃ
# កាមាវចរសោភណចិត្ត ១២ ន័យ

កាមាវចរសោភណចិត្ត ២៤ ដួង ចាត់ជាគូបាន ១២ គូ ទើបជាសង្គហៈ ១២ ន័យ គឺ :-

-ក្នុងមហាកុសលចិត្ត ៨ ដួង ចាត់ជាគូបាន ៤ គូ មានសង្គហៈ ៤ ន័យ
-ក្នុងមហាកិរិយាចិត្ត ៨ ដួង ក៏មានសង្គហៈ ៤ ន័យ
-ក្នុងមហាវិបាកចិត្ត ៨ ដួង ក៏មានសង្គហៈ ៤ ន័យដែរ

រួមទាំងអស់ ជាសង្គហៈ ១២ ន័យ ។

# មហាកុសលសង្គហៈ ៤ ន័យ

**ន័យទី ១ មហាកុសលចិត្តដួងទី ១ និង ទី ២** គឺ សោមនស្សសហគតញាណសម្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ នីមួយ ៗ មានចេតសិកកើតរួម **៣៨ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣ ដួង

-សោភណចេតសិក ២៥ ដួង

**ន័យទី ២ មហាកុសលចិត្តដួងទី ៣ និង ទី ៤** គឺ សោមនស្សសហគតញាណវិប្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ នីមួយៗ មានចេតសិកកើតរួម **៣៧ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣ ដួង

-សោភណចេតសិក ២៥ ដួង (វៀរបញ្ញា)

**ន័យទី ៣ មហាកុសលចិត្តដួងទី ៥ និង ទី ៦** គឺ ឧបេក្ខាសហគតញាណសម្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ នីមួយៗ មានចេតសិកកើតរួម **៣៧ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ ដួង (វៀរបីតិ)

-សោភណចេតសិក ២៥ ដួង

**ន័យទី ៤ មហាកុសលចិត្តដួងទី ៧ និង ទី ៨** គឺ ឧបេក្ខាសហគតញាណវិប្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ នីមួយៗ មានចេតសិកកើតរួម **៣៦ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ ដួង (វៀរបីតិ)

-សោភណចេតសិក ២៤ ដួង (វៀរបញ្ញា)

កាលណា រាប់ចំនួនចេតសិកដែលប្រកបក្នុងមហាកុសលចិត្តទាំងអស់ មាន ៣៨ ដួង ។

# មហាកិរិយាសង្គហៈ ៤ ន័យ

**ន័យទី ១ មហាកិរិយាចិត្តដួងទី ១ និង ទី ២** នីមួយ ៗ មានចេតសិកកើតរួម **៣៥ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣ ដួង

-សោភណចេតសិក ២២ ដួង (វៀរវិរតិចេតសិក៣)

**ន័យទី ២ មហាកិរិយាចិត្តដួងទី ៣ និង ទី ៤** នីមួយ ៗ មានចេតសិកកើតរួម **៣៤ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣ ដួង

-សោភណចេតសិក ២១ ដួង ( វៀរវិរតិចេតសិក ៣ បញ្ញា ១ )

**ន័យទី ៣ មហាកិរិយាចិត្តដួងទី ៥ និង ទី ៦**

នីមួយ ៗ មានចេតសិកកើតរួម **៣៤ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ ដួង (វៀរបីតិ)

-សោភណចេតសិក ២២ ដួង (វៀរវិរតិចេតសិក៣)

**ន័យទី ៤ មហាកិរិយាចិត្តដួងទី ៧ និង ទី ៨**

នីមួយ ៗ មានចេតសិកកើតរួម ៣៣ ដួង គឺ :-

-អញ្ញសមានាចេតសិក ១២ ដួង (វៀរបីតិ)

-សោភណចេតសិក ២១ ដួង ( វៀរវិរតិចេតសិក ៣ បញ្ញា ១ )

កាលណា រាប់ចំនួនចេតសិកដែលប្រកបក្នុងមហាកិរិយាចិត្ត ទាំងអស់មាន ៣៥ ដួង ។

# មហាវិបាកសង្គហៈ ៤ ន័យ

**ន័យទី ១ មហាវិបាកចិត្តដួងទី ១ និង ទី ២**

នីមួយ ៗ មានចេតសិកកើតរួម **៣៣ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣ ដួង
-សោភណចេតសិក ២០ ដួង (វៀរវិរតិចេតសិក ៣ អប្បមញ្ញា ២ )

**ន័យទី ២ មហាវិបាកចិត្តដួងទី ៣ និង ទី ៤**

នីមួយ ៗ មានចេតសិកកើតរួម **៣២ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣ ដួង
-សោភណចេតសិក ១៩ ដួង (វៀរវិរតិចេតសិក ៣ អប្បមញ្ញា ២ បញ្ញា ១)

**ន័យទី ៣ មហាវិបាកចិត្តដួងទី ៥ និង ទី ៦**

នីមួយៗ មានចេតសិកកើតរួម **៣២ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ ដួង (វៀរបីតិ)
-សោភណចេតសិក ២០ ដួង (វៀរវិរតិចេតសិក ៣ អប្បមញ្ញា ២)

**ន័យទី ៤ មហាវិបាកចិត្តដួងទី ៧ និង ទី ៨**

នីមួយៗ មានចេតសិកកើតរួម **៣១ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ ដួង (វៀរបីតិ)
-សោភណចេតសិក ១៩ ដួង (វៀរវិរតិចេតសិក ៣ អប្បមញ្ញា ២ បញ្ញា ១)

កាលណា រាប់ចំនួនចេតសិកដែលប្រកបក្នុងមហាវិបាកចិត្ត ទាំងអស់ មាន ៣៣ ដួង ។

# សង្គហន័យ
# នៃអកុសលចិត្ត ៧ ន័យ

អកុសលចិត្ត ១២ ដួង កាលបើពោលដោយសង្ខេប មាន ចេតសិកប្រកបបាន ២៧ ប៉ុន្តែបើចែកដោយពិស្តារ នឹងបានចេតសិក ប្រកបផ្សេងគ្នា ជាសង្គហៈ ៧ ន័យ គឺ :-

- លោភមូលចិត្ត ៨ ដួង មាន ៤ ន័យ
- ទោសមូលចិត្ត ២ ដួង មាន ២ ន័យ
- មោហមូលចិត្ត ២ ដួង មាន ១ ន័យ

រួមទាំងអស់ ជាសង្គហៈ ៧ ន័យ ។

# លោភមូលសង្គហៈ ៤ ន័យ

## ន័យទី ១ លោភមូលចិត្តដួង ទី ១ និង ទី ៣

គឺ សោមនស្សសហគតទិដ្ឋិគតសម្បយុត្តអសង្ខារិក ១ ទិដ្ឋិគតវិប្បយុត្ត

អសង្ខារិក ១ នីមួយៗ មានចេតសិកប្រកប **១៩ ដួង** គឺ :-

**-លោភមូលចិត្តដួងទី ១** មាន

-អញ្ញសមានចេតសិក ១៣

-មោចតុកចេតសិក ៤

-លោភិកចេតសិក ១

-ទិដ្ឋិចេតសិក ១

**-លោភមូលចិត្តដួងទី ៣** មាន

-អញ្ញសមានាចេតសិក ១៣

-មោចតុកចេតសិក ៤

-លោភិកចេតសិក ១

-មានះចេតសិក ១

**ន័យទី ២ លោភមូលចិត្តដួងទី ៥ និង ទី ៧** គឺ ឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក ១ ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក ១ នីមួយៗ មានចេតសិកប្រកប **១៨ ដួង** គឺ :-

**-លោភមូលចិត្តដួងទី ៥** មាន

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-មោចតុកចេតសិក ៤

-លោភចេតសិក ១

-ទិដ្ឋិចេតសិក ១

**-លោភមូលចិត្តដួងទី ៧** មាន

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-មោចតុកចេតសិក ៤

-លោតិកចេតសិក ១

-មានះចេតសិក ១

**ន័យទី ៣ លោភមូលចិត្តដួងទី ២ និង ទី ៤** គឺ សោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក ១ ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក ១ នីមួយៗ មានចេតសិកប្រកប **២១ ដួង** គឺ :-

**-លោភមូលចិត្តដួងទី ២** មាន

-អញ្ញសមានាចេតសិក ១៣

-មោចតុកចេតសិក ៤

-លោភចេតសិក ១

-ទិដ្ឋិចេតសិក ១

-ថីទុកចេតសិក ២

**-លោភមូលចិត្តដួងទី ៤** មាន

-អញ្ញសមានាចេតសិក ១៣

-មោចតុកចេតសិក ៤
-លោតិកចេតសិក ១
-មានះចេតសិក ១
-ថីទុកចេតសិក ២

**ន័យទី ៤ លោភមូលចិត្តដួងទី ៦ និង ទី ៨** គឺ ឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក ១ ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក ១ នីមួយៗ មានចេតសិកប្រកប **២០ ដួង** គឺ :-

**-លោភមូលចិត្តដួងទី ៦** មាន
-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
-មោចតុកចេតសិក ៤
-លោភចេតសិក ១
-ទិដ្ឋិចេតសិក ១
-ថីទុកចេតសិក ២

**-លោភមូលចិត្តដួងទី ៨** មាន
-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
-មោចតុកចេតសិក ៤
-លោតិកចេតសិក ១
-មានះចេតសិក ១

-ថីទុកចេតសិក                    ២

# ទោសមូលសង្គហៈ ២ ន័យ

**ន័យទី ១ ទោសមូលចិត្តដួងទី ១** គឺ ទោមនស្សសហគត បដិឃសម្បយុត្ត អសង្ខារិក មានចេតសិកប្រកប **២០ ដួង** គឺ :-

-អញ្ញសមានាចេតសិក                    ១២ (វៀរបីតិ)

-មោចតុកចេតសិក                    ៤

-ទោចតុកចេតសិក                    ៤

**ន័យទី ២ ទោសមូលចិត្តដួងទី ២** គឺ ទោមនស្សសហគត បដិឃសម្បយុត្ត សសង្ខារិក មានចេតសិកប្រកប **២២ ដួង** គឺ :-

-អញ្ញសមានាចេតសិក                    ១២ (វៀរបីតិ)

-មោចតុកចេតសិក                    ៤

-ទោចតុកចេតសិក                    ៤

-ថីទុកចេតសិក                    ២

# មោហមូលសង្គហៈ ១ ន័យ

**ន័យ ១ នោះ** គឺ មោហមូលចិត្តទាំង ២ ដួង នីមួយ ៗ មានចេតសិកប្រកប **១៥ ដួង** គឺ :-

**-ឧបេក្ខាសហគតវិចិកិច្ឆាសម្បយុត្ត** មាន

-អញ្ញសមានាចេតសិក ១០ (វៀរអធិមោក្ខៈ បីតិ ឆន្ទៈ )

-មោចតុកចេតសិក ៤

-វិចិកិច្ឆាចេតសិក ១

**-ឧបេក្ខាសហគតឧទ្ធច្ចសម្បយុត្ត** មាន

-អញ្ញសមានាចេតសិក ១១ (វៀរបីតិ ឆន្ទៈ)

-មោចតុកចេតសិក ៤

# សព្វាកុសលយោគីចេតសិក

សព្វាកុសលសាធារណចេតសិក គឺ មោចតុកៈ ៤ សព្វចិត្ត-សាធារណចេតសិក ៧ និង បកិណ្ណកចេតសិក៣ គឺ វិតក្កៈ វិចារៈ វីរិយៈ (វៀរអធិមោក្ខៈ បីតិ ឆន្ទៈ) រួមទាំង ១៤ ដួងនេះ ហៅថា

សព្វាកុសលយោគីចេតសិក គឺ ចេតសិកដែលប្រកបក្នុងអកុសលចិត្ត ១២ ដួង បានទាំងអស់ ។

# សង្គហន័យ
# នៃអហេតុកចិត្ត ៤ ន័យ

អហេតុកចិត្ត ១៨ ដួង មានសង្គហៈ ៤ ន័យ គឺ :-

**ន័យទី ១ ហសិតុប្បាទចិត្ត ១** មានចេតសិកកើតរួម **១២ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ)

**ន័យទី ២ មនោទ្វារាវជ្ជនចិត្ត ១ ដួង និង សោ-មនស្សសន្តីរណចិត្ត ១ ដួង** នីមួយៗ មានចេតសិកកើតរួម **១១ ដួង** គឺ :-

**-មនោទ្វារាវជ្ជនចិត្ត** មាន

-អញ្ញសមានាចេតសិក ១១ (វៀរឆន្ទៈ បីតិ)

**-សោមនស្សសន្តីរណចិត្ត** មាន

-អញ្ញសមានាចេតសិក ១១ (វៀរឆន្ទៈ វិរិយៈ)

**ន័យទី ៣ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង សម្បដិច្ឆន្នចិត្ត ២ ដួង និង ឧបេក្ខាសន្តីរណចិត្ត ២ ដួង** មានចេតសិកកើតរួម **១០ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១០ (វៀរឆន្ទៈ វិរិយៈ បីតិ)

**ន័យទី ៤ ទ្វិបញ្ចវិញ្ញាណចិត្ត ១០** មានចេតសិកកើតរួម **៧ ដួង** គឺ :-

-សព្វចិត្តសាធារណចេតសិក ៧ ។

ការដែលឆន្ទចេតសិក មិនកើតរួមជាមួយនឹងអហេតុកចិត្ត ១៨ ដួងនោះ ព្រោះឆន្ទៈ ជាធម្មជាតិចូលចិត្តប៉ុនប៉ង ប្រាថ្នាត្រូវការនឹងធ្វើកិច្ចការណាមួយ ( កត្តុកម្យតា ) ចំណែកអហេតុកចិត្តទាំងនោះកើតឡើងព្រោះការប្រជុំព្រមនៃបច្ច័យធម៌ប៉ុណ្ណោះ មិនបានអាស្រ័យឆន្ទៈ គឺ សេចក្តីប៉ុនប៉ងប្រាថ្នា ត្រូវការទេ ព្រោះដូច្នោះហើយ ទើបមិនកើតរួមជាមួយនឹងអហេតុកចិត្ត ១៨ ដួង ៕

# ចេតសិកដែលធ្វើឲ្យចិត្តផ្សេងគ្នា

ក្នុង **លោកុត្តរចិត្ត** អង្គឈានទាំង ៥ ធ្វើឲ្យចិត្តផ្សេងគ្នា គឺ **វិតក្កចេតសិក** ធ្វើឲ្យបឋមជ្ឈានចិត្តផ្សេងគ្នាពីឈានចិត្តដទៃ ៤ ទៀត ។ **វិចារចេតសិក** ធ្វើឲ្យទុតិយជ្ឈានចិត្តផ្សេងពី តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈានចិត្ត ។ **បីតិចេតសិក** ធ្វើឲ្យតតិយជ្ឈានចិត្ត ផ្សេងគ្នាពី ចតុត្ថជ្ឈានចិត្ត និង បញ្ចមជ្ឈានចិត្ត , **សុខ** ( សោមនស្សវេទនា ) ធ្វើឲ្យចតុត្ថជ្ឈានចិត្ត ផ្សេងគ្នាពីបញ្ចមជ្ឈានចិត្ត ។ **ឧបេក្ខាវេទនា** ធ្វើឲ្យបញ្ចមជ្ឈានចិត្ត ផ្សេងគ្នាពីឈានចិត្តដទៃ ៤ ទៀត ។

ក្នុង **មហគ្គតចិត្ត អប្បមញ្ញាចេតសិក ២ ដួង** ធ្វើឲ្យបឋមជ្ឈានចិត្ត រហូតដល់ចតុត្ថជ្ឈានចិត្ត ផ្សេងគ្នាពីបញ្ចមជ្ឈានចិត្ត ១៥ ។ ចំណែកអង្គឈានទាំង ៥ ក៏ធ្វើឲ្យមហគ្គតចិត្តផ្សេងគ្នា ដូចសេចក្ដីផ្សេងគ្នាក្នុងលោកុត្តរចិត្តដែរ ។

ក្នុង **កាមាវចរសោភណចិត្ត វិរតិចេតសិក ៣** ធ្វើឲ្យមហាកុសលចិត្តផ្សេងគ្នាពីមហាវិបាក និង មហាកិរិយាចិត្ត ។

**បញ្ញាចេតសិក** ធ្វើឲ្យញាណសម្បយុត្តចិត្តផ្សេងគ្នាពីញាណ-វិប្បយុត្តចិត្ត ។ **បីតិចេតសិក** ធ្វើឲ្យសោមនស្សសហគតចិត្ត ផ្សេងគ្នាពីឧបេក្ខាសហគតចិត្ត ។ **អប្បមញ្ញាចេតសិក ២** ធ្វើឲ្យមហា-កុសល និងមហាកិរិយាចិត្តផ្សេងគ្នាពីមហាវិបាកចិត្ត ៕

# តទុភយមិស្សកន័យ

កាលបើយល់សម្បយោគន័យ ( ន័យនៃការប្រកបរួមគ្នានៃចេតសិកទាំងឡាយដែលមិនដាច់គ្នាពីចិត្ត ) ដោយវិធី ១៦ ន័យ និងសង្គហន័យ ( ន័យនៃការរាប់ចិត្តមួយដួង ។ ដែលមានចេតសិកប្រកប ) ដោយវិធី ៣៣ ន័យហើយ ក៏សមគួរសម្តែងនូវ **តទុភ-យមិស្សកន័យ** គឺន័យនៃការចម្រុះនូវសម្បយោគន័យ និងសង្គហន័យរួមចូលគ្នា ក៏គឺជាការរាប់ចំនួនចេតសិកទាំងឡាយដែលប្រកបរួមក្នុងចេតសិក ៥២ ដួងនោះ ។

# អញ្ញសមានាចេតសិក

- **ផស្សៈ** មានចេតសិកប្រកប ៥១ ( វៀរខ្លួនឯង ) ព្រោះ

ផស្សៈនេះ តាមសម្បយោគន័យ ប្រកបបានក្នុងចិត្តទាំងអស់ ហើយក្នុងចិត្តទាំងអស់នេះ តាមសង្គហន័យ រមែងមានចេតសិកប្រកប ៥២ ដួង តាមសមគួរ ដូច្នេះ ចេតសិកដែលប្រកបនឹងផស្សៈ ទើបមាន ៥១ ដួង ( វៀរខ្លួនឯង ) ។

សព្វចិត្តសាធារណចេតសិកដទៃផ្សេងទៀត ក៏មានសេចក្ដីដូចគ្នា គឺ :-

**-វេទនា** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។
**-សញ្ញា** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។
**-ចេតនា** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។
**-ឯកគ្គតា** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។
**-ជីវិតិន្ទ្រិយ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។
**-មនសិការ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។
**-វិតក្កៈ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

ព្រោះតាមសម្បយោគន័យ វិតក្កៈនេះប្រកបបានក្នុងចិត្ត ៥៥ ដួង ក្នុងចិត្ត ៥៥ ដួងនេះ តាមសង្គហន័យ រមែងមានចេតសិកប្រកប ៥២ ដួង តាមសមគួរ ដូច្នេះ ចេតសិកដែលប្រកបនឹងវិតក្កៈ ទើបមាន ៥១ ដួង ( វៀរខ្លួនឯង ) ។

បកិណ្ណកចេតសិកដទៃទៀត ក៏មានសេចក្ដីដូចន័យនេះដែរ ។

**-វិចារៈ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

**-អធិមោក្ខៈ** មានចេតសិកប្រកប ៥០ ( វៀរវិចិកិច្ឆា និង វៀរខ្លួនឯង ) ។

**-វីរិយៈ** មានចេតសិកប្រកប ៥១ (វៀរខ្លួនឯង) ។

**-បីតិ** មានចេតសិកប្រកប ៤៦ ( វៀរទោចតុកៈ ៤ វិចិកិច្ឆា ១ ខ្លួនឯង ១ ) ។

**-ឆន្ទៈ** មានចេតសិកប្រកប ៥០ ( វៀរ វិចិកិច្ឆា ១ ខ្លួនឯង ១ ) ។

# អកុសលចេតសិក

**- មោហៈ** មានចេតសិកប្រកប ២៦ គឺ អញ្ញសមានា-ចេតសិក ១៣ អកុសលចេតសិក ១៣ (វៀរខ្លួនឯង) ព្រោះតាមសម្បយោគន័យ មោហៈនេះ ប្រកបបានក្នុងអកុសលចិត្តទាំងអស់ ហើយអកុសលចិត្តទាំងអស់ តាមសង្គហន័យ រមែងមានចេតសិកប្រកប ២៧ ដួង តាមសមគួរ ដូច្នេះចេតសិកដែលប្រកបនឹងមោហៈ ទើបមាន ២៦ ដួង (វៀរខ្លួនឯង) ។ មោចតុកចេតសិក ដែលនៅ

សល់ ៣ ទៀត ក៏មានសេចក្ដីដូចគ្នា គឺ :

- **អហិរិកៈ** មានចេតសិកប្រកប ២៦ (វៀរខ្លួនឯង) ។
- **អនោត្តប្បៈ** មានចេតសិកប្រកប ២៦ (វៀរខ្លួនឯង) ។
- **ឧទ្ធច្ចៈ** មានចេតសិកប្រកប ២៦ (វៀរខ្លួនឯង) ។
- **លោភៈ** មានចេតសិកប្រកប ២១ គឺ អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ៨ ( វៀរទោចតុក ៤ វិចិកិច្ឆា ១ ខ្លួនឯង១ ) ព្រោះតាមសម្បយោគន័យ លោភៈនេះ ប្រកបបានក្នុងលោភមូលចិត្ត ៨ ហើយលោភមូលចិត្ត ៨ នេះ តាមសង្គហន័យ រមែងមានចេតសិកប្រកប ២២ ដួង តាមសមគួរ ដូច្នេះចេតសិកដែលប្រកបនឹងលោភៈ ទើបមាន ២១ ដួង ( វៀរខ្លួនឯង ) ។

**លោតិកចេតសិក** ដែលនៅសល់ ២ ទៀត ក៏មានសេចក្ដីដូចគ្នា គឺ :-

**-ទិដ្ឋិ** មានចេតសិកប្រកប ២០ (វៀរមានះនិងខ្លួនឯង) ។

**-មានះ** មានចេតសិកប្រកប ២០ (វៀរទិដ្ឋិនិងខ្លួនឯង) ។

**-ទោសៈ** មានចេតសិកប្រកប ២១ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ) អកុសលចេតសិក ៩ (វៀរលោតិក ៣ វិចិកិច្ឆា ១ ខ្លួនឯង ១) ព្រោះតាមសម្បយោគន័យ ទោសៈនេះ ប្រកបបានក្នុងទោសមូលចិត្ត ២ ហើយទោសមូលចិត្ត ២ នេះ តាមសង្គហន័យ រមែងមានចេតសិកប្រកប ២២ ដួង តាមសមគួរ ដូច្នេះចេតសិកដែលប្រកបនឹងទោសៈ ទើបមាន ២១ ដួង ( វៀរខ្លួនឯង ) ។

**-ឥស្សា** មានចេតសិកប្រកប ១៩ ដួង (វៀរបីតិ ១ លោតិកៈ ៣ វិចិកិច្ឆា ១ មច្ឆរិយៈ ១ កុក្កុច្ចៈ ១ ខ្លួនឯង ១) ។

**-មច្ឆរិយៈ** មានចេតសិកប្រកប ១៩ ( វៀរបីតិ ១ លោតិកៈ ៣ វិចិកិច្ឆា ១ ឥស្សា ១ កុក្កុច្ចៈ ១ និងខ្លួនឯង ១ ) ។

**-កុក្កុច្ចៈ** មានចេតសិកប្រកប ១៩ (វៀរបីតិ ១ លោតិកៈ ៣ វិចិកិច្ឆា ១ ឥស្សា ១ មច្ឆរិយៈ ១ និងខ្លួនឯង ១)។

**-ថីទុកៈ ២** មានចេតសិកប្រកប ក្នុងមួយដួង ៗ មាន ២៥ គឺ អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១២ (វៀរវិចិកិច្ឆា និងខ្លួនឯង) ព្រោះតាមសម្បយោគន័យ ថីទុកៈ ចេតសិកប្រកបបាន ក្នុងអកុសលសសង្ខារិក

៥ ដួង ហើយអកុសលចិត្ត ៥ នេះ តាមសង្គហន័យ រមែងមានចេតសិកប្រកប ២៦ ដួង ដូច្នេះចេតសិកដែលប្រកបនឹង **ថីទុកៈ** ចេតសិកក្នុងមួយដួងៗ ទើបមាន ២៥ ដួង ( វៀរខ្លួនឯង ) ។

**-វិចិកិច្ឆាចេតសិក** មានចេតសិកប្រកប ១៤ ដួង គឺ អញ្ញ-សមានាចេតសិក ១០ ( វៀរ អធិមោក្ខ បីតិ ឆន្ទៈ ) និង មោចតុកចេតសិក ៤ ។

# សោភណចេតសិក

**-សោភណសាធារណចេតសិក ១៩ ដួង** មានចេតសិកប្រកបក្នុងមួយដួងៗ **៣៧ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣
-សោភណចេតសិក ២៥ (វៀរខ្លួនឯង)

**-លោកិយវិរតិចេតសិក ៣** មួយដួងៗ មានចេតសិកប្រកប ៣៣ ដួង គឺ :-

-អញ្ញសមានាចេតសិក ១៣
-សោភណសាធារណចេតសិក ១៩

-បញ្ញា　　　　　　　　　១ ( ព្រោះវិរតិ ៣ និង អប្បមញ្ញា ២ រួម ៥ ដួងនេះ កើតរួមគ្នាមិនបាន ) ។

**-លោកុត្តរវិរតិចេតសិក ៣** មួយដួងៗ មានចេតសិកប្រកប **៣៥ ដួង** គឺ :-

-អញ្ញសមានាចេតសិក　　　១៣

-សោភណសាធារណចេតសិក ១៩　វិរតិ ២ (វៀរខ្លួនឯង)

-បញ្ញា　　　　　　　　　១　(ព្រោះ លោកុត្តរវិរតិជាអង្គមគ្គ ជានិយត-ឯកតោចេតសិក) ។

**- អប្បមញ្ញាចេតសិក ២** មួយដួងៗ មានចេតសិកប្រកប **៣៣ ដួង** គឺ :-

-អញ្ញសមានាចេតសិក　　　១៣

-សោភណសាធារណចេតសិក ១៩

-បញ្ញា　　　　　　　　　១ ( ព្រោះ វិរតិ ៣ និង អប្បមញ្ញា ២ រួម ៥ ដួង នេះ កើតរួមគ្នាមិនបាន)

**-បញ្ញាចេតសិក** មានចេតសិកប្រកប **៣៧ ដួង** គឺ :-

-អញ្ញសមានាចេតសិក ១៣
-សោភណចេតសិក ២៤ (វៀរខ្លួនឯង)

ព្រោះបញ្ញានេះ តាមសម្បយោគន័យ ប្រកបបានក្នុងចិត្តដែលជាញាណសម្បយុត្ត ៤៧ ឬ ៧៩ ដួង ហើយ ញាណសម្បយុត្តចិត្តនេះ តាមសង្គហន័យ រមែងមានចេតសិកប្រកប ៣៨ ដួង ដូច្នេះ ចេតសិកដែលប្រកបនឹងបញ្ញាចេតសិក ទើបមាន ៣៧ ដួង (វៀរខ្លួនឯង) ៕

# ចំនួនចេតសិក
# ដោយពិស្តារ ៣.៤២៦ ដួង

កាលណាយល់សម្បយោគន័យ និង សង្គហន័យនៃចេតសិកដែលប្រកបជាមួយនឹងចិត្តជានិច្ច ដោយន័យដែលពោលរួចមកហើយនោះ រមែងឃើញនូវចំនួនចេតសិក ស្មើនឹងចំនួនចិត្តតាមសមគួរដែលប្រកប គឺថា ចេតសិកណាប្រកបនឹងចិត្តបានប៉ុន្មានដួង ក៏រាប់ថា ចេតសិកនោះ មានចំនួនស្មើនឹងចំនួនចិត្ត ដែលចេតសិកនោះប្រកប គឺ :-

**១. សព្វចិត្តសាធារណចេតសិក ៧ ដួង** គឺ ដួងនីមួយៗ ប្រកបនឹងចិត្តបានទាំងអស់ បញ្ជាក់ថា មួយដួងៗមានផស្សៈជាដើម មានចំនួន ១២១ ដួង ដូច្នេះ សព្វចិត្តសាធារណចេតសិករួមទាំងអស់មាន ៧ × ចិត្ត ១២១ ដួង = **៨៤៧ ដួង** ៕

## ២. បកិណ្ណកចេតសិក ៦ ដួង គឺ :-

| | | | | | |
|---|---|---|---|---|---|
| **វិតក្កៈ** | មានចំនួន ១ × | ចិត្ត ៥៥ | ដួង | = ៥៥ | ដួង |
| **វិចារៈ** | មានចំនួន ១ × | ចិត្ត ៦៦ | ដួង | = ៦៦ | ដួង |
| **អធិមោក្ខៈ** | មានចំនួន ១ × | ចិត្ត ១១០ | ដួង | = ១១០ | ដួង |
| **វីរិយៈ** | មានចំនួន ១ × | ចិត្ត ១០៥ | ដួង | = ១០៥ | ដួង |
| **បីតិ** | មានចំនួន ១ × | ចិត្ត ៥១ | ដួង | = ៥១ | ដួង |
| **ឆន្ទៈ** | មានចំនួន ១ × | ចិត្ត ១០១ | ដួង | = ១០១ | ដួង |

ដូច្នេះ **បកិណ្ណកចេតសិក** រួមទាំងអស់មាន **៤៨៨ ដួង** ៕

## ៣. អកុសលចេតសិក ១៤ ដួង គឺ :-

| | | | | | |
|---|---|---|---|---|---|
| **មោចតុក: ៤** | មានចំនួន ៤ × | ចិត្ត ១២ | ដួង | = ៤៨ | ដួង |
| **លោភៈ** | មានចំនួន ១ × | ចិត្ត ៨ | ដួង | = ៨ | ដួង |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ទិដ្ឋិ** | មានចំនួន | ១ | × | ចិត្ត | ៤ | ដួង | = ៤ | ដួង |
| **មានះ** | មានចំនួន | ១ | × | ចិត្ត | ៤ | ដួង | = ៤ | ដួង |
| **ទោចតុកៈ ៤** | មានចំនួន | ៤ | × | ចិត្ត | ២ | ដួង | = ៨ | ដួង |
| **ថីទុកៈ ២** | មានចំនួន | ២ | × | ចិត្ត | ៥ | ដួង | = ១០ | ដួង |
| **វិចិកិច្ឆា** | មានចំនួន | ១ | × | ចិត្ត | ១ | ដួង | = ១ | ដួង |

ដូច្នេះ **អកុសលចេតសិក** រួមទាំងអស់មាន **៨៣ ដួង** ៕

# ៤. សោភណចេតសិក ២៥ ដួង គឺ :

## សោភណសាធារណចេតសិក ១៩

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | មានចំនួន | ១៩ | × | ចិត្ត | ៩១ | ដួង | = ១៧២៩ | ដួង |
| **វិរតិ ៣** | មានចំនួន | ៣ | × | ចិត្ត | ៤៨ | ដួង | = ១៤៤ | ដួង |
| **អប្បមញ្ញា ២** | មានចំនួន | ២ | × | ចិត្ត | ២៨ | ដួង | = ៥៦ | ដួង |
| **បញ្ញា** | មានចំនួន | ១ | × | ចិត្ត | ៧៩ | ដួង | = ៧៩ | ដួង |

ដូច្នេះ **សោភណចេតសិក** ទាំងអស់មាន **២០០៨** ដួង ។

ដូច្នេះបើ **រួមចេតសិកដែលមានទាំងអស់** គឺ :-

៨៤៧ ដួង + ៤៨៨ ដួង + ៨៣ ដួង + ២០០៨ ដួង = ៣៤២៦ ដួង ។

# អវសានគាថា

## ឥច្ចានុរុទ្ធ រចិតេ អភិធម្មត្ថសង្គហេ
## ទុតិយោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ

បរិច្ឆេទទី ២

ឈ្មោះថា ចេតសិកសង្គហវិភាគ ក្នុងបករណ៍

អភិធម្មត្ថសង្គហៈ ដែលព្រះអនុរុទ្ធាចារ្យរចនា បានចប់ស្រេចហើយ

ដោយប្រការយ៉ាងនេះឯង ៕

ដោយចេតនាដែលជាកុសលសម្បទា បំពេញកុសលជាធម្មទាន ក្នុងឱកាសនេះ សូមចូរជាបច្ច័យបញ្ញាបារមី ឲ្យសាធុជនទាំងឡាយ ដល់នូវសេចក្ដីសុខក្សេមក្សាន្តសំរាន្ត ស្រួល ផុតចាកទុក្ខភ័យទាំងពួង អស់កាលជានិច្ចតទៅហោង ៕

ប្រែចប់ ថ្ងៃទី ១៣ ខែ មិថុនា ពស ២៥៤១

បណ្ឌិតធម្មាចារ្យ **រស់ សុផាត**

# មាតិកា


| រឿង | ទំព័រ |
|---|---|
| សង្គហគាថា.................................. | ១ |
| លក្ខណាទិចតុករបស់ចេតសិក......................... | ២ |
| អំពីចេតសិក ៥២ ដួង.............................. | ៣ |
| អញ្ញសមានាចេតសិក ១៣............................ | ៣ |
| សព្វចិត្តសាធារណចេតសិក ៧...................... | ៣ |
| បកិណ្ណកចេតសិក ៦.............................. | ៤ |
| អកុសលចេតសិក ១៤............................. | ៥ |
| មោចតុក ៤.................................... | ៥ |
| លោតិក ៣...................................... | ៥ |
| ទោចតុកៈ ៤..................................... | ៦ |
| ថីទុក ២........................................ | ៧ |
| វិចិកិច្ឆា ១..................................... | ៧ |
| សោភណចេតសិក ២៥............................. | ៧ |
| សោភណសាធារណចេតសិក ១៩.................... | ៧ |
| វិរតិចេតសិក ៣................................ | ៩ |
| អប្បមញ្ញាចេតសិក ២.............................. | ១០ |

## មាតិកា


| រឿង | ទំព័រ |
|---|---|
| បញ្ញិន្ទ្រីយ៍ចេតសិក ១................................ | ១០ |
| តារាងចេតសិក ៥២ ដួង............................ | ១១ |
| អធិប្បាយសព្វចិត្តសាធារណចេតសិក ៧................ | ១៣ |
| ផស្សចេតសិក......................................... | ១៣ |
| លក្ខណាទិចតុករបស់ផស្សៈ......................... | ១៣ |
| វេទនាចេតសិក...................................... | ១៥ |
| លក្ខណាទិចតុករបស់វេទនា........................ | ១៦ |
| លក្ខណាទិចតុករបស់សុខវេទនា.................... | ១៦ |
| លក្ខណាទិចតុករបស់ទុក្ខវេទនា..................... | ១៧ |
| លក្ខណាទិចតុករបស់សោមនស្សវេទនា.............. | ១៧ |
| លក្ខណាទិចតុករបស់ទោមនស្សវេទនា............... | ១៨ |
| លក្ខណាទិចតុករបស់ឧបេក្ខាវេទនា.................. | ១៨ |
| អំពីឧបេក្ខា ១០ យ៉ាង............................ | ១៩ |
| សញ្ញាចេតសិក....................................... | ២៣ |
| លក្ខណាទិចតុករបស់សញ្ញា........................ | ២៣ |
| ចេតនាចេតសិក........................................ | ២៤ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| លក្ខណាទិចតុករបស់ចេតនា........................ | ២៥ |
| ឯកគ្គតាចេតសិក.................................. | ២៥ |
| លក្ខណាទិចតុករបស់ឯកគ្គតា........................ | ២៦ |
| ជីវិតិន្ទ្រីយ៍........................................... | ២៦ |
| លក្ខណាទិចតុករបស់ជីវិតិន្ទ្រីយ៍..................... | ២៧ |
| មនសិការចេតសិក............................... | ២៧ |
| លក្ខណាទិចតុករបស់មនសិការ..................... | ២៨ |
| អំពីមនសិការ ៣ យ៉ាង.......................... | ២៩ |
| អំពីចេតនា និងមនសិការចេតសិក................. | ២៩ |
| ចំណែកសព្វចិត្តសាធារណចេតសិកដោយន័យផ្សេងៗ. | ៣១ |
| អធិប្បាយចេតសិក ៦............................ | ៣៣ |
| លក្ខណាទិចតុករបស់វិតក្កៈ........................ | ៣៤ |
| វិចារចេតសិក..................................... | ៣៤ |
| លក្ខណាទិចតុករបស់វិចារៈ........................ | ៣៥ |
| អធិមោក្ខចេតសិក................................ | ៣៥ |

# មាតិកា


| រឿង | ទំព័រ |
| --- | --- |
| លក្ខណាទិចតុករបស់អធិមោក្ខ...................... | ៣៦ |
| វិរិយចេតសិក........................................ | ៣៦ |
| លក្ខណាទិចតុករបស់វិរិយៈ........................ | ៣៧ |
| សង្វេគវត្ថុ ៨........................................ | ៣៧ |
| បីតិចេតសិក........................................ | ៣៨ |
| លក្ខណាទិចតុករបស់បីតិ.......................... | ៣៨ |
| បីតិមាន ៥ យ៉ាង.................................. | ៣៩ |
| ឆន្ទចេតសិក........................................ | ៣៩ |
| លក្ខណាទិចតុករបស់ឆន្ទៈ.......................... | ៤០ |
| អធិប្បាយអកុសលចេតសិក ១៤.................. | ៤១ |
| អកុសលចេតសិក ១៤ មាន ៥ ន័យ............ | ៤១ |
| មោហចេតសិក...................................... | ៤២ |
| លក្ខណាទិចតុករបស់មោហៈ...................... | ៤២ |
| អហិរិកចេតសិក.................................... | ៤៥ |
| លក្ខណាទិចតុករបស់អហិរិកៈ...................... | ៤៥ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| អនោត្តប្បចេតសិក.................................. | ៤៦ |
| លក្ខណាទិចតុករបស់អនោត្តប្បៈ........................ | ៤៦ |
| ឧទ្ធច្ចចេតសិក.................................... | ៤៧ |
| លក្ខណាទិចតុករបស់ឧទ្ធច្ចៈ............................ | ៤៧ |
| លោភចេតសិក.................................. | ៤៨ |
| លក្ខណាទិចតុករបស់លោភចេតសិក............... | ៤៨ |
| ទិដ្ឋិចេតសិក...................................... | ៥០ |
| អំពីទិដ្ឋិ ២........................................ | ៥០ |
| លក្ខណាទិចតុករបស់ទិដ្ឋិ............................ | ៥៣ |
| មានៈចេតសិក..................................... | ៥៣ |
| អំពីមានៈ ២ យ៉ាង.............................. | ៥៤ |
| លក្ខណាទិចតុករបស់មានៈ.......................... | ៥៦ |
| ទោសចេតសិក.................................... | ៥៧ |
| លក្ខណាទិចតុករបស់ទោសៈ......................... | ៥៧ |
| អាឃាតវត្ថុ ១០.................................. | ៥៨ |

# មាតិកា

| រឿង | ទំព័រ |
|---|---|
| ឥស្សាចេតសិក.................................... | ៦០ |
| លក្ខណាទិចតុករបស់ឥស្សា............................ | ៦០ |
| មច្ឆរិយចេតសិក.................................. | ៦១ |
| មច្ឆរិយៈ ៥.......................................... | ៦១ |
| លក្ខណាទិចតុករបស់មច្ឆរិយៈ......................... | ៦២ |
| កុក្កុច្ចៈចេតសិក................................... | ៦២ |
| លក្ខណាទិចតុករបស់កុក្កុច្ចៈ.......................... | ៦៣ |
| ថីនចេតសិក........................................ | ៦៣ |
| លក្ខណាទិចតុករបស់ថីនៈ............................ | ៦៤ |
| មិទ្ធចេតសិក........................................ | ៦៤ |
| លក្ខណាទិចតុករបស់មិទ្ធៈ........................... | ៦៥ |
| វិចិកិច្ឆាចេតសិក.................................. | ៦៦ |
| លក្ខណាទិចតុករបស់វិចិកិច្ឆា........................ | ៦៦ |
| សោភណចេតសិក ២៥ ដួង....................... | ៦៧ |
| អធិប្បាយសោភណសាធារណចេតសិក ១៩......... | ៦៨ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| សទ្ធាចេតសិក.................................. | ៦៨ |
| លោកសន្និវាស ៤................................ | ៦៨ |
| លក្ខណាទិចតុករបស់សទ្ធា.......................... | ៦៩ |
| សតិចេតសិក..................................... | ៧០ |
| លក្ខណាទិចតុករបស់សតិ........................... | ៧១ |
| ហិរិចេតសិក..................................... | ៧២ |
| លក្ខណាទិចតុករបស់ហិរិ............................ | ៧២ |
| ឱត្តប្បចេតសិក.................................. | ៧៣ |
| លក្ខណាទិចតុករបស់ឱត្តប្បៈ........................ | ៧៣ |
| អលោភចេតសិក.................................. | ៧៤ |
| លក្ខណាទិចតុករបស់លោភៈ......................... | ៧៥ |
| អទោសចេតសិក.................................. | ៧៥ |
| លក្ខណាទិចតុករបស់អទោសៈ........................ | ៧៦ |
| តត្រមជ្ឈត្តតាចេតសិក............................ | ៧៦ |
| លក្ខណាទិចតុករបស់តត្រមជ្ឈត្តតា.................. | ៧៧ |

# មាតិកា

| រឿង | ទំព័រ |
| --- | --- |
| យុគលធម៌ ៦ គូ................................ | ៧៨ |
| យុគលធម៌គូទី១...................................... | ៧៨ |
| លក្ខណាទិចតុករបស់យុគលធម៌គូទី១............... | ៧៨ |
| យុគលធម៌គូទី២...................................... | ៧៩ |
| លក្ខណាទិចតុករបស់យុគលធម៌គូទី២............... | ៧៩ |
| យុគលធម៌គូទី៣................................. | ៨០ |
| លក្ខណាទិចតុករបស់យុគលធម៌គូទី៣.............. | ៨០ |
| យុគលធម៌គូទី៤.................................. | ៨១ |
| លក្ខណាទិចតុករបស់យុគលធម៌គូទី៤............... | ៨១ |
| យុគលធម៌គូទី៥.................................. | ៨២ |
| លក្ខណាទិចតុករបស់យុគលធម៌គូទី៥............... | ៨៣ |
| យុគលធម៌គូទី៦.................................... | ៨៣ |
| លក្ខណាទិចតុករបស់យុគលធម៌គូទី៦................ | ៨៤ |
| អធិប្បាយវិរតិចេតសិក ៣......................... | ៨៥ |
| សម្មាវាចាចេតសិក................................ | ៨៥ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| សម្មាវាចា ៤........................................ | ៨៥ |
| លក្ខណាទិចតុករបស់សម្មាវាចា....................... | ៨៦ |
| សម្មាកម្មន្តចេតសិក................................ | ៨៦ |
| សម្មាកម្មន្តៈ ៣........................................ | ៨៧ |
| លក្ខណាទិចតុករបស់សម្មាកម្មន្តៈ.................. | ៨៧ |
| សម្មាអាជីវៈចេតសិក.............................. | ៨៨ |
| សម្មាអាជីវៈ មាន ៧ យ៉ាង...................... | ៨៨ |
| លក្ខណាទិចតុករបស់សម្មាអាជីវៈ................... | ៨៨ |
| អធិប្បាយអប្បមញ្ញាចេតសិក ២.................... | ៩០ |
| ករុណាចេតសិក................................... | ៩១ |
| លក្ខណាទិចតុករបស់ករុណា....................... | ៩១ |
| មុទិតាចេតសិក.................................... | ៩២ |
| លក្ខណាទិចតុករបស់មុទិតា........................ | ៩៣ |
| អប្បមញ្ញា ៤...................................... | ៩៤ |
| អំពីមេត្តា............................................ | ៩៤ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| លក្ខណាទិចតុករបស់មេត្តា........................ | ៩៥ |
| អំពីឧបេក្ខា................................... | ៩៦ |
| លក្ខណាទិចតុករបស់ឧបេក្ខា...................... | ៩៦ |
| អធិប្បាយបញ្ញិន្ទ្រីយ៍ចេតសិក......................... | ៩៨ |
| លក្ខណាទិចតុករបស់បញ្ញា........................ | ៩៨ |
| កម្មស្សកតាបញ្ញា ១០ យ៉ាង..................... | ១០០ |
| អំពីសម្បយោគន័យ.............................. | ១០១ |
| សម្បយោគដោយសង្ខេប.......................... | ១០២ |
| សម្បយោគដោយពិស្តារ........................... | ១០៣ |
| អធិប្បាយសម្បយោគ សព្វចិត្តសាធារណចេតសិក.. | ១០៤ |
| សម្បយោគន័យបកិណ្ណកចេតសិក................. | ១០៤ |
| ចិត្តដែលបកិណ្ណកចេតសិកប្រកបនិងមិនប្រកប...... | ១០៦ |
| សម្បយោគន័យអកុសលចេតសិក................. | ១០៨ |
| សម្បយោគន័យសោភណចេតសិក.................. | ១០៩ |
| និយតយោគីចេតសិក និងអនិយតយោគីចេតសិក... | ១១៣ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| អំពីសង្គហន័យ....................................... | ១២០ |
| សង្គហន័យដោយសង្ខេប............................... | ១២០ |
| សង្គហន័យដោយពិស្តារ............................. | ១២១ |
| អធិប្បាយសង្គហន័យលោកុត្តរចិត្ត ៥ ន័យ............ | ១២២ |
| សង្គហន័យនៃមហគ្គតចិត្ត ៥ ន័យ............... | ១២៣ |
| សង្គហន័យនៃកាមាវចរសោភណចិត្ត ១២ ន័យ.... | ១២៤ |
| មហាកុសលសង្គហៈ ៤ ន័យ.................... | ១២៥ |
| មហាកិរិយាសង្គហៈ ៤ ន័យ..................... | ១២៦ |
| មហាវិបាកសង្គហៈ ៤ ន័យ...................... | ១២៧ |
| សង្គហន័យនៃអកុសលចិត្ត ៧ ន័យ.............. | ១២៨ |
| លោភមូលសង្គហៈ ៤ ន័យ...................... | ១២៩ |
| ទោសមូលសង្គហៈ ២ ន័យ...................... | ១៣២ |
| មោហមូលសង្គហៈ ១ ន័យ...................... | ១៣៣ |
| សព្វកុសលយោគីចេតសិក........................ | ១៣៣ |
| សង្គហន័យនៃអហេតុកចិត្ត ៤ ន័យ................ | ១៣៤ |

# មាតិកា

| រឿង | ទំព័រ |
|---|---|
| ចេតសិកដែលធ្វើឲ្យចិត្តផ្សេងគ្នា...................... | ១៣៥ |
| តទុភយមិស្សកន័យ.................................. | ១៣៦ |
| អញ្ញសមានាចេតសក.............................. | ១៣៧ |
| អកុសលចេតសិក.................................. | ១៣៩ |
| សោភណចេតសិក............................... | ១៤១ |
| ចំនួនចេតសិកដោយពិស្ដារ ៣.៤២៦ ដួង........ | ១៤៣ |
| អវសានគាថា.................................... | ១៤៥ |